# សុខដុមនីយកម្មច្បាប់ទាក់ទង
# និងដំណើរការវិមជ្ឈការនៅកម្ពុជា

ឯកសារពិភាក្សាលេខ ៣១

**Robert Oberndorf**

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ខែកក្កដា ឆ្នាំ២០០៤

**Law Harmonisation in Relation to the Decentralisation Process in Cambodia — Working Paper 31**

*July 2004*
*Robert Oberndorf*


**© រក្សាសិទ្ធិឆ្នាំ២០០៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។



**ISSN 1560 9812**


**សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា ~ ឯកសារពិភាក្សាលេខ ៣១**

*ខែកក្កដា ឆ្នាំ២០០៤*

Robert Oberndorf

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)**
**ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤**
**អ៊ីមែល:** cdri@camnet.com.kh **website:** http://www.cdri.org.kh

បកប្រែដោយ: អ៊ុំ ចាន់ថា
កែសម្រួល: យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព JSRC ស្ថិតនៅបរិវេណវិទ្យាល័យបឹងត្របែក រាជធានីភ្នំពេញ

# មាតិកា


បុព្វកថា ..... ១

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ..... ៣

សេចក្តីថ្លែងអំណរគុណ ..... ៥

សេចក្តីសង្ខេប ..... ៧

**សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា** ..... ១១

១. សេចក្តីផ្តើម និងការពិនិត្យជាទូទៅ ..... ១១

២. ការវិវត្តន៍ជាប្រវត្តិសាស្ត្រនៃវិសហមជ្ឈការនៅកម្ពុជា ..... ១១

៣. ប្រវត្តិ និងស្ថានភាពបច្ចុប្បន្ននៃវិសហមជ្ឈការនៅកម្ពុជា ..... ១៣

៤. គោលនយោបាយវិមជ្ឈការ ..... ១៤

៤.១ ការពិនិត្យមើលជាទូទៅនៃគោលនយោបាយវិមជ្ឈការមានស្រាប់នានា ..... ១៤

៤.២ អង្គភាពនានាដែលជាប់ទាក់ទិននៅក្នុងការអភិវឌ្ឍន៍គោលនយោបាយវិមជ្ឈការ ..... ១៥

៤.៣ គោលនយោបាយអភិវឌ្ឍន៍វិមជ្ឈការសព្វថ្ងៃ ..... ១៧

៤.៤ អនុសាទ៍សំរាប់ការអភិវឌ្ឍន៍គោលនយោបាយ ..... ១៧

៥. ក្របខ័ណ្ឌច្បាប់ ..... ១៧

៥.១ ការពិនិត្យមើលជាទូទៅនៃប្រព័ន្ធច្បាប់នៅកម្ពុជា ..... ១៧

៥.២ ច្បាប់ និងបទប្បញ្ញត្តិដំបូងដែលបានអនុម័តដើម្បីទ្រទ្រង់ដល់វិមជ្ឈការ ..... ២១

៦. រចនាសម្ព័ន្ធរដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីទ្រទ្រង់ដល់វិមជ្ឈការ ..... ២២

៦.១ កំរិតជាតិ ..... ២៤

៦.២ កំរិតខេត្ត ស្រុក និងឃុំ ..... ២៧

៧. តួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ ..... ៣៣

៨. ការអធិប្បាយពីច្បាប់ និងបទប្បញ្ញត្តិវិមជ្ឈការបច្ចុប្បន្ន ..... ៣៤

៨.១ បញ្ហាទាក់ទិននឹងការបកស្រាយច្បាប់ ..... ៣៥

៨.២ បញ្ហាសំខាន់ៗដែលរកឃើញ ..... ៣៦

៨.៣ ច្បាប់ និងបទដ្ឋានសំខាន់ៗដែលនៅខ្វះសព្វថ្ងៃ ..... ៣៨

៨.៤ ការពិនិត្យឡើងវិញនៃច្បាប់ និងបទប្បញ្ញត្តិរបស់ NCSC ..... ៣៩

៩. ការកំរិតព្រំដែនឃុំឡើងវិញ.......... ៤០
១០. វិសហមជ្ឈការ .......... ៤២
១០.១ វិសហមជ្ឈការនៅតាមបណ្ដាក្រសួង.......... ៤២
១០.២ វិសហមជ្ឈការខេត្ត ស្រុក.......... ៤៥
១១. កំណែទំរង់តុលាការដោយសារវាទាក់ទងដល់វិមជ្ឈការ.......... ៤៦
១២. ការគ្រប់គ្រងធនធានធម្មជាតិ/ការប្រើប្រាស់ដី និងវិមជ្ឈការ .......... ៤៧
១២.១ LAMC និង ច្បាប់និងបទប្បញ្ញត្តិដែលទាក់ទិននានា.......... ៤៧
១២.២ ច្បាប់ភូមិបាល និង ច្បាប់និងបទប្បញ្ញត្តិដែលទាក់ទិននានា.......... ៤៨
១២.៣ ច្បាប់និងបទប្បញ្ញត្តិដែលទាក់ទិននានាដែលទាក់ទិននឹងធនធានធម្មជាតិ និងបរិស្ថាន.......... ៤៨
១២.៤ គំលាតនៅក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់នានា.......... ៤៨
១២.៥ ការបង្កើតរចនាសម្ព័ន្ធរដ្ឋាភិបាលជាទូទៅ.......... ៥០
១៣. បញ្ហាគ្រប់គ្រងសារពើពន្ធនានាទាក់ទិននឹងវិមជ្ឈការ.......... ៥០
១៤. ការកសាងសមត្ថភាពដើម្បីទ្រទ្រង់ដល់វិមជ្ឈការ.......... ៥០
១៥. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍.......... ៥១

ឯកសារយោង.......... ៥១
ឧបសម្ព័ន្ធ ក. ក្រាហ្វិកដែនសមត្ថកិច្ច និងពេលវេលា.......... ៥៣
ឧបសម្ព័ន្ធ ខ. បញ្ជីច្បាប់ និងបទប្បញ្ញត្តិនានា .......... ៥៥
បញ្ជីឯកសារពិភាក្សារបស់ វបសអ.......... ៥៩

# បុព្វកថា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បានបង្កើតកម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយខាងវិមជ្ឈការ (PORDEC) នៅខែវិច្ឆិកា ២០០២ ដោយមានជំនួយឧបត្ថម្ភពី SIDA និង DFID ។ PORDEC មានគោលដៅផ្តល់ពត៌មានជាប់ទាក់ទិននឹងគោលនយោបាយ និងការវិភាគ ទៅឱ្យអ្នកធ្វើសេចក្តីសំរេច និងអ្នកជាប់ពាក់ព័ន្ធផ្សេងៗ នៅក្នុងដំណើរការធ្វើវិមជ្ឈការនៅកម្ពុជា ដើម្បីជួយពួកគេឱ្យធ្វើសេចក្តីសំរេចដោយមានពត៌មានច្បាស់លាស់គ្រប់គ្រាន់។ ក្នុងដំណើរការពិគ្រោះយោបល់នៅមុនពេលបង្កើត PORDEC, អ្នកជាប់ពាក់ព័ន្ធជាច្រើននាក់បានបញ្ជាក់ពីតំរូវការកសាងក្របខ័ណ្ឌច្បាប់សំរាប់កំណែទំរង់វិមជ្ឈការ ដោយពិនិត្យពីចំណុចផ្សេងៗដែលត្រួតគ្នា នៅចន្លោះប្រហោង ឬ មិនស៊ីសង្វាក់គ្នា ។

ការសិក្សាមានគោលដៅស្វែងរកមើលពីបញ្ហាប្រឈមចំបងៗដែលចោទឡើងដោយក្របខ័ណ្ឌច្បាប់ និងផ្តល់មតិយ៉ាងជាក់លាក់ពីវិធីផ្សេងៗដែលអាចធ្វើទៅបានដើម្បីឈានទៅមុខ ។ ការសិក្សាបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាអនុវត្តបានជឿនលឿនទៅមុខច្រើនណាស់ហើយ បើពិនិត្យតាមបញ្ហាខាងសមត្ថភាព និងវប្បធម៌ ដែលកំណែទំរង់ត្រូវប្រឈមមុខ ។ ទីប្រឹក្សាបានលើកបង្ហាញពីច្បាប់ និងបទប្បញ្ញត្តិនានា ដែលត្រូវដាក់អនុវត្តជាអាទិភាព ហើយនិងច្បាប់ផ្សេងៗទៀតដែលត្រូវដោះស្រាយឱ្យបានមុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់លើកក្រោយ ។ អ្នកនិពន្ធបានកត់សំគាល់ដែរថា ថ្វីបើមានបញ្ហាចោទខ្លះៗនៅក្នុងច្បាប់ និងបទប្បញ្ញត្តិនានាដែលអនុម័តហើយក្តី ក៏សព្វថ្ងៃវាមិនបានប៉ះពាល់អ្វីធ្ងន់ធ្ងរដល់ការអនុវត្តន៍ទេ ហើយអាចទុកយកទៅដោះស្រាយនៅក្នុងដំណាក់កាលក្រោយទៀតនៃកំណែទំរង់បាន ។

ការសិក្សានេះ បានផ្តល់មតិដ៏មានប្រយោជន៍ និងជំរើសគោលនយោបាយមួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជា ហើយ វបសអ សង្ឃឹមថា វានឹងជួយបង្ហាញទិសខ្លះៗលើទិដ្ឋភាពខាងច្បាប់នៃការអនុវត្តន៍កំណែទំរង់ក្នុងរយៈពេលខ្លី និងមធ្យម ។ ខ្ញុំសូមឆ្លៀតឱកាសនេះជំនួសមុខឱ្យ វបសអ ថ្លែងអំណរគុណដល់ លោក Robert Oberndorf ចំពោះការចូលរួមវិភាគទានជាលក្ខណៈស្ថាបនា និងជាប់ទាក់ទងល្អ ដល់ការពិភាក្សាវែកញែកពីអនាគតនៃកំណែទំរង់វិមជ្ឈការនៅកម្ពុជា ។

ការសិក្សា ត្រូវបានតាក់តែងរចនាឡើង និងផ្តល់ហិរញ្ញវត្ថុ ក្រោមកិច្ចសហការរវាង PORDEC និង ក្រុមទីប្រឹក្សាអចិន្ត្រៃយ៍នៃកម្មវិធីសិលា (PAT) ដែលទទួលមូលនិធិពី DFID/SIDA ។

*ឡារី ស្ត្រេនទ្ធ*

*នាយកប្រតិបត្តិ*

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

*ភ្នំពេញ ឧសភា ២០០៤*

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (Council for Administrative Reform) |
| CARERE | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/គំរោងស្តារ និងបង្កើតតំបន់ឡើងវិញ<br>(Cambodia Area Rehabilitation and Regeneration Project) |
| CAU | ផ្នែកគ្រប់គ្រងកិច្ចសន្យា (Contract Administration Unit) |
| CDRI/វិបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Research Institute) |
| CDRI PORDEC | កម្មវិធីស្រាវជ្រាវផ្តោតលើគោលនយោបាយខាងវិមជ្ឈការរបស់ វិបសអ<br>(CDRI Policy Oriented Research for Decentralisation) |
| CCSP | គំរោងគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ (Commune Council Support Project) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CoM | ទីស្តីការគណៈរដ្ឋមន្ត្រី (Council of Ministers) |
| CRDB | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា<br>(Cambodian Rehabilitation and Development Board) |
| DFID | នាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ<br>(Department for International Development) |
| DFT | ក្រុមសំរបសំរួលស្រុក (District Facilitation Team) |
| DOLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (Department of Local Administration) |
| ExCom | គណៈកម្មាធិការប្រតិបត្តិ<br>Executive Committee (PRDC) |
| GAP | ផែនការសកម្មភាពអភិបាលកិច្ច (Governance Action Plan) |
| GTZ | ទីភ្នាក់ងារអាល្លឺម៉ង់សំរាប់សហប្រតិបត្តិការបច្ចេកទេស<br>Gessellschaft fur Technische Zusammenarbeit (German Agency for Technical Cooperation) |
| LAMC | ច្បាប់ស្តីពីការគ្រប់គ្រង និងរដ្ឋបាលឃុំ/សង្កាត់<br>(Law on the Administration and Management of the Commune) |
| LAU | ផ្នែករដ្ឋបាលមូលដ្ឋាន (Local Administration Unit) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>(Ministry of Agriculture, Forestry and Fisheries) |

| | |
|---|---|
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (Ministry of Industry, Mines and Energy) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>(Ministry of Economy and Finance) |
| MoI | ក្រសួងមហាផ្ទៃ (Ministry of Interior) |
| MoP | ក្រសួងផែនការ (Ministry of Planning) |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម<br>(Ministry of Water Resources and Meteorology) |
| MWVA | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន<br>(Ministry of Women's and Veterans' Affairs) |
| MLMUPC | ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់<br>(Ministry of Land Management, Urban Planning & Construction) |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ (Ministry of Rural Development) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Governmental Organisation) |
| NCSC | គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់<br>(National Committee for Support to Communes) |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ<br>(National Poverty Reduction Strategy) |
| NREM | ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន<br>(Natural Resources and Environmental Management) |
| PFT | ក្រុមសំរបសំរួលខេត្ត (Provincial Facilitation Team) |
| POLA | អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង<br>(Provincial Office of Local Administration) |
| PRDC | គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត<br>(Provincial Rural Development Committee) |
| SEILA | ភ្នាក់ងារមូលដ្ឋានដើម្បីកែលំអសេដ្ឋកិច្ចសង្គម<br>(Social Economic Improvement Local Agency) |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត<br>(Swedish International Development Agency) |
| STF | គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (SEILA Task Force) |
| TSU | អង្គភាពគាំទ្របច្ចេកទេស (Technical Support Unit) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme) |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ (Village Development Committee) |

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានចុះកិច្ចសន្យាឱ្យកសាងឡើងដោយ កម្មវិធីស្រាវជ្រាវផ្តោតខាងគោលនយោបាយស្តីពីវិមជ្ឈការ (PORDEC) នៃ វិបសអ និង ក្រុមទីប្រឹក្សាអចិន្ត្រៃយ៍របស់ សិលា ដែលបង្កើតឡើងដោយ SIDA និង DFID ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់បណ្ឌិត Caroline Rusten ដែលបានផ្តល់ឱកាសឱ្យខ្ញុំធ្វើកិច្ចការមួយដ៏មានប្រយោជន៍ និងពោរពេញដោយបញ្ហាប្រឈម ។ ចំពោះអ្នកនៅក្នុងជួររដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណដល់ បណ្ឌិត ហុក បេងសែ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង លោក ឡេង វី នៃ DOLA ដែលបានផ្តល់ការពិភាក្សាយ៉ាងចំហ និងត្រង់ទៅត្រង់មក ស្តីពីស្ថានភាពនៃកិច្ចប្រឹងប្រែងធ្វើវិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល ។ សូមអរគុណដល់ Shelly នៃ GTZ និង Shyam Bhurtel នៃ UNDP ដែលអនុញ្ញាតឱ្យខ្ញុំបានទទួលសេចក្តីព្រាងឯកសារសំខាន់ៗដែលត្រូវបានពិនិត្យឡើងវិញ និងដែលមិនទាន់បានផ្សព្វផ្សាយចេញ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ Scott Leiper និង Joanne Morrison នៃការិយាល័យអង្គការសហប្រជាជាតិសំរាប់សេវាបំរើគំរោង ដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន, ចំពោះការជួយផ្តល់ពត៌មាន មតិយោបល់ និងការយកចិត្តទុកដាក់ស្តាប់ជាបន្តបន្ទាប់ដោយសន្តោស ។ នៅមានជាច្រើននាក់ទៀតដែលបានជួយធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅបាន និងដែលមិនបានរៀបរាប់ឈ្មោះនៅក្នុងរបាយការណ៍នេះ ហើយខ្ញុំសូមសំដែងជូននូវការគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ។ ខ្ញុំសូមអរគុណផងដែរដល់អ្នកជួយផ្ទៀងផ្ទាត់មិនចេញឈ្មោះដែលបានផ្តល់យោបល់ដ៏ល្អវិសេសនៅលើសេចក្តីព្រាងរបាយការណ៍ ។

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់បុគ្គលណាផ្សេងរបស់រដ្ឋាភិបាល ឬរបស់ វិបសអ ទេ ហើយកំហុសឆ្គងផ្សេងៗក្នុងការវិភាគក៏ជារបស់អ្នកនិពន្ធដែរ ។

# សេចក្តីសង្ខេប

វិមជ្ឈការ និងវិសហមជ្ឈការ គឺជាផ្នែកមួយនៃកំណែទំរង់របស់រដ្ឋាភិបាល ដើម្បីលើកកំពស់លទ្ធិប្រជាធិបតេយ្យ, កែលំអឱកាសអភិវឌ្ឍន៍, កាត់បន្ថយភាពក្រីក្រ, និង ធានានូវការអភិវឌ្ឍន៍មានចីរភាព ។

រដ្ឋាភិបាល កំពុងអនុវត្តកំណែទំរង់វិមជ្ឈការ ដើម្បីផ្ទេរអំណាចទៅឱ្យអាជ្ញាធរជាប់ឆ្នោតពាក់កណ្តាលស្វយ័ត[១] នៅកំរិតឃុំ/សង្កាត់ និងឈានទៅបង្កើនតួនាទីរបស់ខេត្ត និងក្រុង ក្នុងឋានៈជាអង្គភាពមជ្ឈិមដែលត្រូវបានធ្វើវិសហមជ្ឈការ ។ នៅខែមីនា ២០០១, RGC បានចាប់ផ្តើមការសាកល្បងដ៏ក្លាហានមួយនៃការធ្វើវិមជ្ឈការរដ្ឋអំណាចតាមការអនុមតិច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC) និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់, ដែលបន្តដោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅខែកុម្ភៈ ២០០២ ។ មុខងារ សិទ្ធិអំណាចចំណាយ និងធនធានជាច្រើន ត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរមូលដ្ឋាន ហើយអភិបាលខេត្តនានាបានទទួលភារកិច្ចជួយគាំទ្រ និងធ្វើការត្រួតពិនិត្យលើក្រុមប្រឹក្សាឃុំ/សង្កាត់។ ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងនេះ ច្បាប់និងបទប្បញ្ញត្តិជាច្រើន ត្រូវបានអនុម័តចេញក្នុងរយៈពេលមួយដ៏ខ្លី ។ តើច្បាប់និងបទប្បញ្ញត្តិទាំងនេះវាស៊ីសង្វាក់គ្នាយ៉ាងណាជាមួយនឹងច្បាប់ដែលមានស្រាប់ និង តើការប្រឹងប្រែងធ្វើវិមជ្ឈការសព្វថ្ងៃរបស់រដ្ឋាភិបាល វាស៊ីសង្វាក់គ្នាប៉ុណ្ណាជាមួយនឹងរចនាសម្ព័ន្ធទាំងនេះ, គឺសុទ្ធតែជាចំណុចផ្តោតនៅក្នុងរបាយការណ៍ ។ គេអាចធ្វើការសង្កេតពីដំបូងៗជាច្រើន តាមរយៈការវិភាគលើស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ។

១. គួរលើកសរសើរដល់រដ្ឋាភិបាលដែលបានអនុម័តច្បាប់ និងបទប្បញ្ញត្តិជាច្រើន ក្នុងរយៈពេលមួយដ៏ខ្លីបែបនេះ ដើម្បីជួយគាំទ្រដល់វិមជ្ឈការ ។

២. នៅពេលតាក់តែងសេចក្តីព្រាងច្បាប់សំខាន់ៗ រដ្ឋាភិបាលមិនទាន់បានអនុម័តឯកសារខាងគោលនយោបាយអ្វីសោះ ហេតុនេះគឺពុំមានសេចក្តីណែនាំអ្វីច្បាស់លាស់ទេ សំរាប់ការតាក់តែងច្បាប់ ។ សរុបមក LAMC ក៏បានក្លាយជាឯកសារគោលនយោបាយមួយ។ រឿងនេះ គួបផ្សំនឹងរយៈពេលដ៏ខ្លីផង បានធ្វើឱ្យប្រព័ន្ធច្បាប់មានលក្ខណៈស្មុគស្មាញបន្តិច ហើយវិធាននិងបទប្បញ្ញត្តិផ្សេងៗមានចំណុចត្រួតគ្នាយ៉ាងច្រើន និងមានខ្លឹមសារមិនច្បាស់លាស់ ដោយសារការតាក់តែងមានលក្ខណៈទន់ខ្សោយ ។ ប៉ុន្តែច្បាប់ និងបទប្បញ្ញត្តិទាំងនេះ មានគុណភាពប្រហាក់ប្រហែលគ្នានឹងកំរិតគុណភាពដែលឃើញមានជាធម្មតានៅកម្ពុជា, ហើយអាចដាក់អនុវត្តបាន ។

៣. ទោះបីមានបញ្ហាចោទមួយចំនួននៅក្នុងប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិក្តី ក៏វាមិនឃើញមានផលប៉ះពាល់អ្វីធ្ងន់ធ្ងរទៅលើការអនុវត្តន៍នៅផ្ទាល់កន្លែងទេ ដោយសារមានការប្រើប្រកាសសំរាប់ដាក់អនុវត្តន៍ច្បាប់។ ប៉ុន្តែដល់យូរៗទៅ នៅពេលមានបញ្ហាផុសឡើង គេចាំបាច់ត្រូវតែដោះស្រាយវា ។

[១] ក្នុងឯកសារនេះគេពណ៌នាក្រុមប្រឹក្សាឃុំថា ពាក់កណ្តាលស្វយ័ត ដោយសារមានការត្រួតពិនិត្យច្រើនគួរសម ពីឋានានុក្រមរដ្ឋាភិបាលដែលនៅខាងលើ ។

៤. ល្បឿនវិមជ្ឈការសព្វថ្ងៃ ហាក់ដូចបានស្របគ្នានឹងបំណងរបស់រដ្ឋាភិបាល, ហើយបើតាមយោបល់របស់អ្នកធ្វើអត្ថាអធិប្បាយជាច្រើននាក់ គឺហាក់ដូចបានលឿនសមស្របល្អ ពិនិត្យតាមបរិបទខាងវប្បធម៌ និងសមត្ថភាពនៅកម្ពុជា។

៥. មុនដល់អាណត្តិលើកក្រោយនៃក្រុមប្រឹក្សាឃុំ គេត្រូវមានគោលនយោបាយច្បាស់លាស់សំរាប់ណែនាំដល់ការព្រាងច្បាប់និងបទប្បញ្ញត្តិថ្មីៗ និងការធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ ទាំងក្នុងផ្នែកវិមជ្ឈការដែលជាប់ទាក់ទិននឹងក្រុមប្រឹក្សាឃុំ និងក្នុងផ្នែកវិសហមជ្ឈការដែលជាប់ទាក់ទិននឹងអាជ្ញាធរកំរិតខេត្ត និងស្រុក (ច្បាប់រៀបចំអង្គការ) ។ ការតាក់តែងគោលនយោបាយទាំងនេះ ត្រូវតែធ្វើឱ្យបានសមស្របជាមួយគ្នាទៅវិញទៅមក ពីព្រោះវិមជ្ឈការ និងវិសហមជ្ឈការ ជំពាក់ជាប់វាក់វិនគ្នាខ្លាំងណាស់មិនអាចកាត់ផ្តាច់ពីគ្នាបានទេ ។

៦. បើគិតដល់ចន្លោះប្រហោងក្នុងច្បាប់បច្ចុប្បន្ន ចំណុចលេចធ្លោបំផុតគឺ កង្វះច្បាប់រៀបចំអង្គការសំរាប់អាជ្ញាធរកំរិតខេត្ត និងស្រុក ។ ក្រៅពីនេះ ច្បាប់សំខាន់ៗដែលចាំបាច់ត្រូវដាក់អនុវត្តក្នុងរយៈពេលខ្លី និងមធ្យម រួមមានៈ ច្បាប់និងបទប្បញ្ញត្តិស្តីពីការកំនត់ ប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកំរៃសេវាផ្សេងៗសំរាប់ក្រុមប្រឹក្សាឃុំ (ច្បាប់នេះ ត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌការធ្វើសុខដុមនីយកម្មការគ្រប់គ្រងសារពើពន្ធនៅគ្រប់កំរិតនៃរដ្ឋាភិបាល), ច្បាប់ស្តីពីកំរៃរដ្ឋបាលសំរាប់មុខងារទីភ្នាក់ងារដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សាឃុំ, នីតិវិធីសំរាប់ការជ្រើសរើស ការចូលកាន់មុខតំណែង និងការផ្លាស់ប្តូរមេភូមិ, ការតែងតាំងជំនួយការមេភូមិ និង របៀបរបបធ្វើការងារ និងភារកិច្ចរបស់មេភូមិ, សេចក្តីណែនាំសំរាប់ឱ្យក្រុមប្រឹក្សាឃុំជ្រើសជួលបុគ្គលិកតាមតំរូវការ, ការតាក់តែងជីកាឃុំ (បទប្បញ្ញត្តិថ្នាក់មូលដ្ឋាន), សេចក្តីណែនាំពីការបង្កើតគណៈកម្មាធិការផ្សេងៗសំរាប់ជួយដល់ក្រុមប្រឹក្សាឃុំក្នុងការអនុវត្តន៍ភារកិច្ច, សេចក្តីណែនាំពីតួនាទី និងការទទួលខុសត្រូវរបស់ឃុំច្រើនដែលធ្វើការជាមួយគ្នា ។

៧. បញ្ហាពន្យាអាណត្តិរបស់ NCSC ត្រូវលើកយកមកដោះស្រាយក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីវិមជ្ឈការ ដូចមានបញ្ជាក់ក្នុងចំណុច៤ ខាងលើ។ បើសិនត្រូវពន្យាអាណត្តិនេះ, LAMC និងបទប្បញ្ញត្តិជាប់ទាក់ទិនផ្សេងៗក៏ត្រូវធ្វើវិសោធនកម្មតាមនោះដែរ ។

៨. ត្រូវមានការពិនិត្យឡើងវិញជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយលើប្រព័ន្ធថវិកា/ហិរញ្ញវត្ថុ បើសិនគេចង់ឱ្យក្រុមប្រឹក្សាឃុំអាចចាប់ផ្តើមរកចំណូលពន្ធបានពិតៗ ដែលមិនមែនត្រឹមតែជាកំរៃសេវាដូចមានចែងនៅក្នុង LAMC នោះទេ ។ ត្រូវមានប្រព័ន្ធដ៏ច្បាស់លាស់មួយថា តើចំណូលប្រភេទណាត្រូវប្រមូលដោយរតនាគារជាតិ ឬខេត្ត ឬឃុំ ដើម្បីចៀសវាងបញ្ហាប្រមូលពន្ធច្រើនហួស ឬប្រមូលពន្ធត្រួតគ្នា លើប្រជាពលរដ្ឋ ។

៩. គេនៅមិនទាន់បានធ្វើអ្វីសោះក្នុងរឿងកំនត់ព្រំដែនឃុំឡើងវិញ ប៉ុន្តែទិសដៅគឺត្រូវដោះស្រាយបញ្ហានេះឱ្យរួចរាល់នៅមុនពេលបោះឆ្នោតឃុំ/សង្កាត់លើកក្រោយនាឆ្នាំ២០០៧ ។

១០. ការតាក់តែងច្បាប់រៀបចំអង្គការ នឹងមានផលប៉ះពាល់ដោយជៀសមិនរួច ទៅលើច្បាប់និងបទប្បញ្ញត្តិមានស្រាប់នានាដែលជាប់ទាក់ទិននឹងវិមជ្ឈការ ។ យោងតាមព្រឹត្តិការណ៍ និងបញ្ហាផ្សេងទៀត ដែលមានផលប៉ះពាល់ដល់ច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ន គេប្រហែលចាំបាច់ត្រូវតាក់តែងឡើងវិញឱ្យបានសព្វគ្រប់នូវ LAMC ព្រមទាំងអនុក្រឹត្យ និងប្រកាសសំរាប់គាំទ្រនានា ។ បើដូច្នោះមែន បញ្ហានេះត្រូវដោះស្រាយយ៉ាងប្រុងប្រយ័ត្ន ដោយមានឯកសារគោលនយោបាយច្បាស់លាស់សំរាប់ជួយតំរង់ទិសដល់ការតាក់តែងច្បាប់។ បើសិនគោលដៅគឺត្រូវអនុម័តច្បាប់រៀបចំអង្គការឱ្យបានមុនការបោះឆ្នោតឃុំលើកក្រោយ (រដ្ឋាភិបាលបានប្រកាសថា មានគោលដៅនេះមែន)

ដូច្នេះការតាក់តែងឡើងវិញនូវ LAMC និងបទប្បញ្ញត្តិផ្សេងៗដូចខាងលើក៏ត្រូវតែបញ្ចប់ឱ្យបានមុនពេលបោះឆ្នោត ឃុំលើកក្រោយដែរ ។ បញ្ហាទាំងពីរនេះជំពាក់ជំពិនគ្នាបេះមិនដាច់ ហើយត្រូវដោះស្រាយក្នុងពេលជាមួយគ្នា ។ រឿងនេះត្រូវការកិច្ចសំរបសំរួល និងសហប្រតិបត្តិការរវាងអង្គភាពកសាងគោលនយោបាយសំខាន់ៗដែលជាប់ទាក់ទិន (NCSC, CAR, MoI, និង សិលា) ព្រមទាំងការប្តេជ្ញាចិត្តខាងនយោបាយដ៏ខ្លាំងក្លាពីសំណាក់រដ្ឋាភិបាល ។

១១. ច្បាប់រៀបចំអង្គការគួរដោះស្រាយបញ្ហាការសំរបសំរួលវិសហមជ្ឈការតាមខ្សែផ្តេក រវាងក្រសួងជំនាញនានានៅកំរិតខេត្ត និងស្រុក ។

១២. NCSC ពុំមានពេលវេលាដើម្បីពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិដែលមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាឃុំ ដូចជា អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដែលទើបអនុម័តហើយថ្មីៗ ជាដើមនោះទេ។ បញ្ហាចោទគឺ មុខងារភ្នាក់ងារ ត្រូវបានធ្វើប្រតិភូកម្ម ដោយគ្មានការដាក់អនុវត្តន៍យន្តការដ៏ចាំបាច់នានាដើម្បីធានាថា ធនធានដ៏ចាំបាច់ផ្សេងៗ (សមត្ថភាព និង ហិរញ្ញវត្ថុ) ក៏ត្រូវបានផ្តល់ឱ្យដែរ ។

១៣. ក្រុមប្រឹក្សាឃុំ ត្រូវបំពេញតួនាទីដ៏សំខាន់មួយក្នុងការគ្រប់គ្រងការប្រើប្រាស់ ដី និងធនធានធម្មជាតិ ថ្វីបើក្នុងពេលបច្ចុប្បន្ន ពួកគេមិនទាន់មានសិទ្ធិអំណាចធ្វើសេចក្តីសំរេចអារកាត់ដោយផ្ទាល់ នៅក្នុងវិស័យខ្លះៗ ដូចជាខាងព្រៃឈើ ជាដើមក្តី ។

# សុខដុមនីយកម្មច្បាប់ទាក់ទងនឹង ដំណើរការវិមជ្ឈការនៅកម្ពុជា

## ១. សេចក្តីផ្តើម និងការពិនិត្យជាទូទៅ

គោលដៅចំបងនៃរបាយការណ៍នេះ គឺធ្វើការពិនិត្យជាទូទៅថា តើប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិបច្ចុប្បន្ន បានជួយទ្រទ្រង់ប៉ុណ្ណាដល់ការប្តេជ្ញាចិត្តធ្វើវិមជ្ឈការរបស់រដ្ឋាភិបាលកម្ពុជា[២] ។ របាយការណ៍ក៏ស្រាវជ្រាវដែរថា តើប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិនានាជាប់ទាក់ទិននឹងវិមជ្ឈការ វាផ្សារភ្ជាប់យ៉ាងណាដែរជាមួយនឹងបញ្ហាអភិបាលកិច្ចផ្សេងៗទៀត ដូចជា វិសហមជ្ឈការ, កំណែទំរង់តុលាការ និងហិរញ្ញវត្ថុ, និង ការគ្រប់គ្រងធនធានធម្មជាតិ/ការប្រើប្រាស់ដី ។

របាយការណ៍នេះនឹងផ្តល់ជូនអ្នកអាននូវពត៌មានស្តីពីការវិវត្តន៍ក្នុងប្រវត្តិសាស្ត្រនៃវិសហមជ្ឈការនៅកម្ពុជា, ការពិភាក្សាពីការវិវត្តន៍នៃគោលនយោបាយខាងវិសហមជ្ឈការ, ការពន្យល់ស្តីពីប្រព័ន្ធច្បាប់នៅកម្ពុជា ព្រមទាំងពីច្បាប់និងបទប្បញ្ញត្តិនានាដែលបានអនុម័តហើយ និងដែលជាប់ទាក់ទងនឹងវិសហមជ្ឈការ, ការពិនិត្យជាទូទៅនូវរចនាសម្ព័ន្ធរដ្ឋាភិបាលដែលបានបង្កើតឡើង ឬបានកែលំអ ដើម្បីជួយទ្រទ្រង់ដល់វិសហមជ្ឈការ (រួមទាំងការផ្តល់មតិពីចំណុចខ្សោយនានានៅក្នុងរចនាសម្ព័ន្ធនេះ), ការពិនិត្យត្រួសៗពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងផ្តល់យោបល់ពីច្បាប់និងបទប្បញ្ញត្តិដែលបានអនុម័តហើយ ដោយផ្តោតលើបញ្ហាចោទចំបងៗដែលបានរកឃើញ និងចន្លោះប្រហោងសំខាន់ៗដែលត្រូវបំពេញក្នុងរយៈពេលខ្លី ។ លើសពីនេះទៀត របាយការណ៍នឹងពិនិត្យពិភាក្សាពីបញ្ហានានានៅជុំវិញ ការកំណត់ព្រំប្រទល់ឃុំ, ចំណងទាក់ទងរវាងគំនិតផ្តួចផ្តើមផ្សេងៗខាងវិសហមជ្ឈការ, កំណែទំរង់ហិរញ្ញវត្ថុ និងតុលាការ, និង ការគ្រប់គ្រងធនធានធម្មជាតិ/ការប្រើប្រាស់ដី ។ ការកសាងសមត្ថភាពនឹងត្រូវបានពិនិត្យដោយសង្ខេប ពីព្រោះប្រធានបទនេះមានអធិប្បាយយ៉ាងទូលំទូលាយហើយនៅក្នុងឯកសារជាច្រើនដែលមានស្រាប់ ។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ នឹងមានរៀបរាប់ពីលទ្ធផលរកឃើញ និងអនុសាសន៍សំខាន់ៗ ។

## ២. ការវិវត្តន៍ក្នុងប្រវត្តិសាស្ត្រនៃវិសហមជ្ឈការនៅកម្ពុជា

នៅកម្ពុជា ប្រព័ន្ធរដ្ឋបាលក្នុងស្រុកបច្ចុប្បន្ន គឺជាកេរ្តិ៍តំណែលនៃបទពិសោធន៍ក្នុងប្រវត្តិសាស្ត្រដែលកើតមានតាំងពីមុនពេលពួកបារាំងមកដល់ក្នុងសតវត្សរ៍ទី១៩ ម្លេះ ។ ព្រះរាជាអនុវត្តសិទ្ធិអំណាចកំពូលនៅលើទឹកដីកម្ពុជាតាមរយៈប្រព័ន្ធមួយដែល តភ្ជាប់ភូមិនានាតាមរយៈមេភូមិទៅនឹងអាជ្ញាធរថ្នាក់លើ ។ ឃុំដែលមានរចនាសម្ព័ន្ធច្បាស់លាស់ជាអង្គភាពរដ្ឋបាលដាច់ដោយ

---

[២] ពាក្យ "ច្បាប់ និងបទប្បញ្ញត្តិ" រួមមាន ច្បាប់ អនុក្រឹត្យ ប្រកាស និង ឧបករណ៍ខាងច្បាប់ផ្សេងៗទៀតដែលមានលក្ខណៈត្រូវប្រតិបត្តិតាម ក្នុងនេះមានទាំង សេចក្តីណែនាំ និង សៀវភៅណែនាំអនុវត្តន៍នានា ដែលជារឿយៗមានលក្ខណៈត្រូវប្រតិបត្តិតាម ។ គេគួរកត់សំគាល់ថា សេចក្តីណែនាំជាច្រើនត្រូវបានអនុម័តចេញតាមរយៈប្រកាស អាស្រ័យហេតុនេះវាមានលក្ខណៈត្រូវប្រតិបត្តិតាម ។

ឡើកក្នុងរូបភាពដូចគេបានដឹងបានស្គាល់នាបច្ចុប្បន្ន គឺមិនទាន់មានទេនៅមុនពេលពួកបារាំងមកដល់ ។ រាជក្រឹត្យចុះថ្ងៃ០៥ មិថុនា ១៩០៨ គឺជាឫសគល់ដើមនៃច្បាប់ស្តីពីឃុំនៅកម្ពុជា ។ រាជក្រឹត្យបានបង្កើតក្របខ័ណ្ឌរដ្ឋបាលយ៉ាងសាមញ្ញមួយ ដោយគួបឯកត្តាគ្រួសារបញ្ចូលគ្នាឱ្យទៅជាឃុំ និងបានចែងពីការបោះឆ្នោតជ្រើសរើសមេឃុំ ដោយពួកអ្នករស់នៅក្នុងឃុំ ។

ដើម្បីធ្វើឱ្យរដ្ឋបាលខិតចូលទៅជិតប្រជាជន និងរំដោះការងារទុកឱ្យអាជ្ញាធរមជ្ឈិមបំពេញភារកិច្ចផ្សេងៗទៀត រដ្ឋបាលអាណានិគមនិយមបារាំង (ពីឆ្នាំ១៩១៩ ដល់ ១៩៤៣) បានណែនាំឱ្យប្រើរាជក្រឹត្យពីរ ។ រាជក្រឹត្យចុះថ្ងៃ២៤ កញ្ញា ១៩១៩ បានអនុញ្ញាតឱ្យឃុំមានហិរញ្ញវត្ថុ និងថវិកាផ្ទាល់, និងបង្កើនសិទ្ធិអំណាចរបស់មេឃុំ, ហើយជាលទ្ធផល ឃុំក៏មានតួនាទីកាន់តែធំខាងអភិបាលកិច្ច ។ នៅឆ្នាំជាបន្តបន្ទាប់ទៀត អាជ្ញាធរមជ្ឈិមត្រូវបានពង្រឹងតាមរយៈការចាប់ផ្តើមធ្វើកំណែទំរង់រដ្ឋបាលមជ្ឈិម។ បន្តមកទៀតមានចេញរាជក្រឹត្យចុះថ្ងៃ ១៥ វិច្ឆិកា ១៩២៥ ដែលបានផ្តល់នូវបទបញ្ជាយ៉ាងច្បាស់លាស់ស្តីពីការរៀបចំ រដ្ឋបាល តុលាការ និងហិរញ្ញវត្ថុរបស់ឃុំ ។ រាជក្រឹត្យបានបង្កើតឡើងនូវក្រុមប្រឹក្សាឃុំដែលត្រូវជ្រើសតាំងតាមការបោះឆ្នោត និងមានលក្ខណៈសម្បត្តិជាអង្គភាពសមូហភាពមួយដែលត្រូវជ្រើសរើសមេឃុំម្នាក់ពីក្នុងចំណោមសមាជិកខ្លួន ដើម្បីទទួលរ៉ាប់រងភារកិច្ចអនុវត្តសេចក្តីសំរេចនានារបស់ក្រុមប្រឹក្សា ។

នៅឆ្នាំ១៩៤៣ ដោយសារសភាពការណ៍នៃសង្គ្រាមលោកលើកទី២ជាសំខាន់ ក៏មានការរៀបចំឃុំនានាឡើងវិញ ។ ប្រព័ន្ធបោះឆ្នោតឃុំត្រូវបានលុបចោល ហើយអភិបាលខេត្តគឺជាអ្នកតែងតាំងមេឃុំនិងជំទប់ ដោយមានការយល់ព្រមពីអាណាព្យាបាលបារាំង ។ នៅឆ្នាំ១៩៥៥ មានការព្យាយាមរៀបចំការបោះឆ្នោតឃុំឡើងវិញ ប៉ុន្តែមិនបានដាក់អនុវត្តជាក់ស្តែងទេ ។

នៅឆ្នាំ១៩៥៩ មានចេញរាជក្រឹត្យមួយដែលចែងពី "ការសើរើកែតំរូវទាំងស្រុងនូវច្បាប់ស្តីពីការរៀបចំដែនដី និងរដ្ឋបាលឃុំកម្ពុជាឡើងវិញ..." ។ ច្បាប់នេះមានគោលដៅស្តារឡើងវិញនូវភាពស្របច្បាប់ជាស្ថាប័ននៃឃុំនានា និងការបោះឆ្នោតជ្រើសរើសមេឃុំ និងក្រុមប្រឹក្សាឃុំ តាមបែបបទដូចក្នុងរាជក្រឹត្យឆ្នាំ១៩២៥ ។ ប៉ុន្តែបទប្បញ្ញត្តិទាំងនេះ ត្រូវផ្អាកសិទ្ធក្នុងរយៈពេលមួយគ្មានកំណត់ ក្រោយពីការធ្វើប្រជាមតិនៅឆ្នាំ១៩៥៩ ។ ជាលទ្ធផល គ្មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំទេ ហើយមេឃុំនៅតែត្រូវបានតែងតាំងដោយអភិបាលខេត្តជាបន្តទៀត ។ ស្ថានភាពនេះនៅដដែលរហូតដល់ឆ្នាំ១៩៧០ ទើបមានធ្វើការផ្លាស់ប្តូរជាមូលដ្ឋានមួយចំនួននៅក្នុងប្រព័ន្ធនយោបាយរបស់ប្រទេស ។

ពីឆ្នាំ១៩៧០ ដល់ ១៩៩២ កម្ពុជាបានធ្លាក់ក្នុងការរីករាលធ្ងន់ធ្ងរខាងនយោបាយ ដែលបន្តដោយវិបត្តិខាងមនុស្សធម៌ដ៏ធំធេង ហើយសព្វថ្ងៃប្រទេសកម្ពុជាទើបតែចាប់ផ្តើមងើបឡើងវិញទេ ។ ក្នុងរយៈពេលនោះ រដ្ឋធម្មនុញ្ញកម្ពុជាមានការផ្លាស់ប្តូរ ៥ដង ។ នៅឆ្នាំ១៩៧០ កម្ពុជាប្តូរពីរបបរាជានិយម ទៅជារបបសាធារណរដ្ឋនិយម ដោយមានការអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយនៅថ្ងៃ១០ ឧសភា ១៩៧២ ។ តាមការអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយទៀតនៅថ្ងៃ០៥ មករា ១៩៧៦ កម្ពុជាប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងក្រោមរបបខ្មែរក្រហម ។ រដ្ឋបាលមូលដ្ឋាន ត្រូវបានរៀបចំជា ៣កំរិតគឺ តំបន់ឬខេត្ត, ស្រុក, និងសហករណ៍ដែលចែកចេញជាសហករណ៍ឃុំ និង សហករណ៍ភូមិ ។ ការរៀបចំ ៣កំរិតបែបនេះ មិនមែនជារឿងរដ្ឋបាលមូលដ្ឋានសុទ្ធសាធនោះទេ ប៉ុន្តែវាក៏ជាប់ទាក់ទងទៅនឹងយុទ្ធសាស្ត្រខាងយោធា និងការដឹកនាំផងដែរ ។

ក្រោយការដួលរលំរបបខ្មែរក្រហម រដ្ឋធម្មនុញ្ញថ្មីមួយត្រូវអនុម័តនៅថ្ងៃ២៥ មិថុនា ១៩៨១ ដោយបានបង្កើតឡើងនូវសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រដ្ឋធម្មនុញ្ញថ្មីបានតំរូវឱ្យមានការរៀបចំប្រទេសឡើងវិញទៅតាមរបៀបរបបចាស់ដែលបែងចែកខេត្តជា ស្រុក និងឃុំ និងបែងចែកក្រុងជា សង្កាត់ ។ ការបែងចែកនេះតំរូវឱ្យមានការបោះឆ្នោតមេឃុំ និងចៅសង្កាត់, រីឯខេត្តនានាបានតែងតាំងគណៈកម្មការខេត្ត និងអភិបាលខេត្ត ។

រដ្ឋធម្មនុញ្ញចុះថ្ងៃ១៣ មេសា ១៩៨៩ បានបង្កើត "រដ្ឋកម្ពុជា" និងបានកំណត់ពីការបែងចែកដែនដីតាមរបៀបថ្មី ។ នៅកំរិតខេត្ត រដ្ឋធម្មនុញ្ញបានបង្កើតទីរួមខេត្ត (ដូចទីក្រុងដែរ ដោយមានសង្កាត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន) និង ទីរួម

ស្រុក (ដូចទីប្រជុំជនជនបទ ដោយមានឃុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន) ។ ទីរួមខេត្ត គឺជាទីតាំង ឬ ធានីរបស់ខេត្ត ។ រដ្ឋធម្មនុញ្ញតំរូវឱ្យមានការបោះឆ្នោតមេឃុំ និងចៅសង្កាត់ ។ ប៉ុន្តែមានការបោះឆ្នោតតែមួយលើកគត់ដែលបានធ្វើឡើងនៅក្រោម ការអនុញ្ញាតផ្នែកនយោបាយនេះ ។ អភិបាលខេត្តនានាបន្តអនុវត្តសិទ្ធិអំណាចធ្វើការតែងតាំង និងដកតំណែង មេឃុំដដែល ។

ក្រោយពីការចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅខែតុលា ១៩៩១ រដ្ឋធម្មនុញ្ញបច្ចុប្បន្នត្រូវបានអនុម័តនៅថ្ងៃ២១ កញ្ញា ១៩៩៣ ដោយកំណត់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញបានបែងចែកទឹកដីព្រះរាជាណាចក្រកម្ពុជា ទៅជាខេត្ត និងក្រុង ហើយបច្ចុប្បន្នគឺមាន ២០ខេត្ត និង ៤ក្រុង។ ខេត្តនីមួយៗចែកចេញជាស្រុក ហើយស្រុកនីមួយៗចែកចេញជាឃុំ, ឯក្រុងនីមួយៗចែកចេញជាខ័ណ្ឌ ហើយខ័ណ្ឌនីមួយៗចែកចេញជាសង្កាត់[៣] ។ រដ្ឋធម្មនុញ្ញកំណត់ថា ខេត្ត ស្រុក និង ឃុំ ត្រូវបានគ្រប់គ្រងស្របទៅតាម ច្បាប់រៀបចំអង្គការ ដែលជាច្បាប់មួយអនុម័តដោយរដ្ឋសភា និងចែងពីការបង្កើត ឬការរៀបចំស្ថាប័នរដ្ឋ និងរចនាសម្ព័ន្ធរបស់វា ។

គួរកត់សំគាល់ដែរថា ទោះបីមានការអនុម័តច្បាប់ និងបទប្បញ្ញត្តិជាច្រើនដែលជាប់ទាក់ទងនឹងអាជ្ញាធរកំរិតមូលដ្ឋានក្តី ក៏កិច្ចប្រឹងប្រែងពីមុនៗ ភាគច្រើនគឺសំដៅពង្រឹងការត្រួតត្រារបស់រដ្ឋបាលមជ្ឈិម និងការត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ ។ ម្យ៉ាងទៀតនៅមិនទាន់មានច្បាប់ណាមួយដែលកំណត់ឱ្យបានសព្វគ្រប់ពី សិទ្ធិអំណាច មុខងារ និង ទំនាក់ទំនងរវាង ខេត្ត ស្រុក និងឃុំ ទេ។ លើកលែងតែមានច្បាប់រៀបចំអង្គការដែលកំណត់នូវ តួនាទី ភារកិច្ច និងមុខងារ របស់ឃុំ និងក្រុមប្រឹក្សាឃុំ, ថ្នាក់ខេត្ត និងស្រុក នៅតែមាន "ភាពស្រពិចស្រពិលខាងផ្លូវច្បាប់" ហើយនេះជាបញ្ហាសំខាន់បំផុតមួយដែលត្រូវដោះស្រាយនៅក្នុងកំណែទំរង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់កម្ពុជា ។ ដូចមានពិភាក្សាលំអិតនៅខាងក្រោយទៀត ច្បាប់រៀបចំអង្គការស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច នៃរដ្ឋបាលកំរិតខេត្ត ស្រុក នៅមិនទាន់បានតាក់តែងទេ ប៉ុន្តែរដ្ឋាភិបាលហាក់ដូចមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីអនុម័តវាឱ្យបានមុនការបោះឆ្នោតឃុំលើកក្រោយនៅឆ្នាំ២០០៧ ។

## ៣. ប្រវត្តិ និងស្ថានភាពបច្ចុប្បន្ននៃវិសហមជ្ឈការនៅកម្ពុជា

កម្ពុជា អនុវត្តវិធីសាស្ត្រធ្វើវិមជ្ឈការ ប្លែកដាច់ពីគេ ។ ក្នុងករណីភាគច្រើន គេគិតថា វិមជ្ឈការបែងចែកចេញជា ៣ ចំណែកតូចៗគឺ : វិមជ្ឈការនយោបាយ (ការផ្ទេរសិទ្ធិអំណាច), វិមជ្ឈការរដ្ឋបាល (ជារឿយៗគេហៅថា វិសហមជ្ឈការ), ហើយនិង វិមជ្ឈការហិរញ្ញវត្ថុ និងទីផ្សារ (ឯកជនភាវូបនីយកម្មនៃសេវារបស់រដ្ឋាភិបាល)។ កម្ពុជាបានកសាងវិមជ្ឈការនយោបាយ ក្នុងលក្ខណៈជាគោលនយោបាយនិងការផ្តួចផ្តើមគំនិតធ្វើកំណែទំរង់ដាច់ដោយឡែកមួយ ដែលផ្តោតលើអភិបាលកិច្ចកំរិតមូលដ្ឋាន និងដែលក្នុងនេះ អំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ត្រូវបានផ្ទេរទៅឱ្យកំរិតមូលដ្ឋានតាមរយៈក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតតាមលក្ខណៈប្រជាធិតេយ្យ ។ ខុសប្លែកពីទស្សនះស្តីពីវិមជ្ឈការខាងលើ គឺ វិសហមជ្ឈការដែលអ្នកនៅក្នុងជួររដ្ឋាភិបាលច្រើនយល់ឃើញថាជាការធ្វើប្រតិភូកម្មមុខងារ និងការធ្វើសេចក្តីសំរេចខាងរដ្ឋបាល ពីអាជ្ញាធរថ្នាក់មជ្ឈឹម ទៅឱ្យថ្នាក់ខេត្ត ស្រុក និងឃុំ ។ ជាទូទៅ វិសហមជ្ឈការ ផ្តោតទៅលើអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់ស្រុក, រីឯវិសហមជ្ឈការរដ្ឋបាលធ្វើរហូតដល់ថ្នាក់ឃុំ ដូចជា ការផ្តល់មុខងារទីភ្នាក់ងារផ្សេងៗ ដែលមន្ត្រីជាច្រើនក្នុងរដ្ឋាភិបាលតែងហៅថា វិមជ្ឈការ ។ មនុស្សជាច្រើនក្នុងជួររដ្ឋាភិបាលតែងសំគាល់ថា វិមជ្ឈការគឺជាអ្វីៗដែលជាប់ទាក់ទងនឹងការគ្រប់គ្រង និងសិទ្ធិអំណាចរបស់ឃុំ រីឯវិសហមជ្ឈការ គឺជាអ្វីៗដែលជាប់ទាក់ទងនឹងកំណែទំរង់អភិបាលកិច្ចនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ។

[៣] ក្នុងឯកសារនេះទាំងមូល ពាក្យ ខេត្ត មានរាប់បញ្ចូល ក្រុង, ពាក្យ ស្រុក មានរាប់បញ្ចូល ខ័ណ្ឌ, ពាក្យ ឃុំ មានរាប់បញ្ចូល សង្កាត់ ។ នៅពេលមានការចាំបាច់ ពាក្យ ក្រុង ខ័ណ្ឌ និង សង្កាត់ ក៏ត្រូវបានប្រើប្រាស់ដែរ ។

ការកាត់ផ្តាច់រវាងវិមជ្ឈការ និងវិសហមជ្ឈការ បានចោទបញ្ហាខាងផ្លូវច្បាប់ ដោយសាររឿងទាំងពីរជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយត្រូវលើកមកពិចារណាដោយផ្សារភ្ជាប់ពីមួយទៅមួយនៅពេលអនុម័តច្បាប់និងបទប្បញ្ញត្តិនានា។ ជាអកុសល កង្វះឯកសារគោលនយោបាយច្បាស់លាស់ស្តីអំពីវិមជ្ឈការនិងវិសហមជ្ឈការ រឹតតែបានបង្កនូវការភ័ន្តច្រឡំថែមទៀតនៅក្នុងជួររដ្ឋាភិបាល ពីអត្ថន័យពិតនៃពាក្យទាំងពីរ ។ ការបារម្ភនៅពេលនេះគឺ ច្បាប់និងបទប្បញ្ញត្តិដែលនឹងត្រូវអនុម័តជាប់ទាក់ទងនឹងវិសហមជ្ឈការ ដូចជាច្បាប់រៀបចំអង្គការជាដើម, នឹងមិនចងភ្ជាប់ជាមួយច្បាប់/បទប្បញ្ញត្តិនានាជាប់ទាក់ទងនឹងវិសហមជ្ឈការដែលបានអនុម័តហើយ ឬនឹងត្រូវបានអនុម័ត ឬក៏ត្រូវធ្វើវិសោធនកម្មនោះទេ ។

នៅកម្ពុជា ដំណើរការវិមជ្ឈការបច្ចុប្បន្នបានរីកលូតលាស់ចេញពីគំនិតផ្តួចផ្តើមរបស់ CARERE/SEILA ដែលបានចាប់ផ្តើមនៅឆ្នាំ១៩៩៦ និងពីរបៀបវារៈពីខាងដើមរបស់រដ្ឋាភិបាលនៅឆ្នាំ១៩៩៩ ដែលក្នុងនេះជំហានដំបូងគឺការអនុម័តក្របខ័ណ្ឌច្បាប់សំរាប់អភិបាលកិច្ចបែបវិមជ្ឈការ ។ តាមរយៈការអនុមតិច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ (១៤ កុម្ភៈ ២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (១៩ មីនា ២០០១) រដ្ឋាភិបាលបានចាប់អនុវត្តជាផ្លូវការនូវដំណើរការវិមជ្ឈការ ។ ឯកសារច្បាប់ដ៏សំខាន់ៗទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏មាំសំរាប់ធ្វើការបោះឆ្នោតឃុំនៅខែកុម្ភៈ ២០០២ ដែលតាមនេះ ១៦២១ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើង ។

ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ ត្រូវបានមើលឃើញថាមានជោគជ័យយ៉ាងច្រើន ហើយវាជាជំហានមួយដ៏សំខាន់ឆ្ពោះទៅសំរេចគោលដៅនៃកំណែទំរង់ ។ តាំងពីពេលបោះឆ្នោតនោះមក រដ្ឋាភិបាលបានធ្វើការងារជាច្រើន ដើម្បីទ្រទ្រង់ដំណើរការវិមជ្ឈការដែលប្រព្រឹត្តទៅ ។ រដ្ឋាភិបាលបានអនុម័តចេញហើយនូវឧបករណ៍ខាងច្បាប់មួយភាគធំ (តែមិនទាន់អស់ទេ), បានរៀបចំបណ្តាញអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង (POLA) ក្នុងគ្រប់ខេត្ត/ក្រុង[៤] បានបង្កើតប្រព័ន្ធទ្រទ្រង់ក្រុមប្រឹក្សាឃុំ, បានកសាងកម្មវិធីផ្សេងៗសំរាប់អភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សាឃុំ, បានរៀបចំឯកសារបណ្តុះបណ្តាលផ្សេងៗ, បានបង្កើតក្រុមអ្នកបណ្តុះបណ្តាលបង្គោល (គឺគ្រូបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល), និងបានពង្រីកការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំពីទស្សនៈនៃវិមជ្ឈការ, ការកសាងផែនការឃុំ, ហិរញ្ញវត្ថុឃុំ, និងការរចនាតាក់តែងការអនុវត្តន៍ និងការវាយតំលៃគំរោងនានារបស់ឃុំ ។ ការប្រឹងប្រែងមកទល់សព្វថ្ងៃបានជោគជ័យគួរឱ្យកោតសរសើរ ប៉ុន្តែវិមជ្ឈការគឺជាដំណើរការបន្តជាប់រហូត ហើយនៅមានកិច្ចការត្រូវធ្វើច្រើនទៀត បើសិនគេចង់ឱ្យកំណែទំរង់ចាក់ឫសមាំល្អ និងមានចីរភាពពិតប្រាកដ ។

## ៤. គោលនយោបាយវិមជ្ឈការ

### *៤.១ ការពិនិត្យមើលជាទូទៅនូវគោលនយោបាយវិមជ្ឈការមានស្រាប់នានា*

ជាទស្សនៈ គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល ដើរស្របតាមគោលការណ៍បន្ទាប់បន្សំនៃអភិបាលកិច្ចល្អ ។ រដ្ឋាភិបាលមានជំនឿថា វិមជ្ឈការគឺជាប្រព័ន្ធមួយដែលរដ្ឋផ្ទេរសិទ្ធិអំណាច (ព្រមទាំងការទទួលខុសត្រូវ) ទៅឱ្យថ្នាក់ក្រោម (ឃុំ) ដើម្បីធ្វើការរៀបចំនិងគ្រប់គ្រងនៅក្នុងមូលដ្ឋាន ក្នុងទិសដៅអនុញ្ញាតឱ្យប្រជាពលរដ្ឋជួយទ្រទ្រង់ និងរ៉ាប់រងការទទួលខុសត្រូវគ្រប់គ្រងកិច្ចការរបស់ខ្លួនឯងផ្ទាល់ *(ផែនការសកម្មភាពអភិបាលកិច្ច, មេសា ២០០១)* ។

ក្នុងពេលបច្ចុប្បន្ន នៅកម្ពុជាមិនទាន់មានឯកសារគោលនយោបាយច្បាស់លាស់ស្តីពីវិមជ្ឈការដែលរដ្ឋាភិបាលបានអនុម័តជាផ្លូវការទេ គឺមានតែសេចក្តីថែងនៅក្នុងផែនការសកម្មភាពរដ្ឋាភិបាលរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR), ផែនការ

---

[៤] POLA មិនមែនជាការិយាល័យពិតៗដែលមានរចនាសម្ព័ន្ធរដ្ឋបាលនៅផ្ទាល់កន្លែងទេ គឺគ្រាន់តែជាកន្លែងទំនាក់ទំនងកណ្តាលរបស់ DOLA នៅក្នុងខេត្តប៉ុណ្ណោះ ។

អភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច ៥ឆ្នាំ លើកទី២ (២០០១-២០០៥), ក្របខ័ណ្ឌគោលនយោបាយដីធ្លីរបស់ក្រុមប្រឹក្សាយុទ្ធសាស្ត្រគោលនយោបាយដីធ្លី (កញ្ញា ២០០២,) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥), ប៉ុន្តែឯកសារទាំងនេះមិនបានផ្តល់ការណែនាំច្បាស់លាស់ទេអំពី វិសាលភាព និងទិសដៅនៃវិមជ្ឈការ[៥] ។ ជាការគួរឱ្យសោកស្តាយមួយដែលរដ្ឋាភិបាលមិនទាន់មានគោលនយោបាយច្បាស់លាស់ស្តីពីវិមជ្ឈការ ពីព្រោះសព្វថ្ងៃនេះក៏គ្មានការណែនាំអ្វីជាក់លាក់ដែរអំពីការបកស្រាយច្បាប់ ឬការចង្អុលទិសថាតើច្បាប់ត្រូវអភិវឌ្ឍន៍ ធ្វើវិសោធនកម្ម ឬផ្សព្វផ្សាយថែមទៀត... យ៉ាងដូចម្តេច ។

ទោះជាមិនទាន់មានគោលនយោបាយច្បាស់លាស់ក្តី ក៏មានការទទួលស្គាល់ថា កម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាលមានគោលដៅចំបងៗ ៣ គឺៈ

- លើកកំពស់របបប្រជាធិបតេយ្យមានការចូលរួមពហុបក្សនៅកំរិតមូលដ្ឋាន (រួមទាំងរបបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅកំរិតមូលដ្ឋាន) ដោយបង្កើតឡើងនូវរដ្ឋបាលមូលដ្ឋានស្វយ័តដែលមានអាណត្តិជាក់លាក់ (ឃុំ), មានការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ, តំណាងផលប្រយោជន៍ប្រជាពលរដ្ឋ, និងធ្វើសេចក្តីសំរេចចិត្តលើការផ្គត់ផ្គង់សេវានិងទំនិញសាធារណៈ ។
- លើកកំពស់វប្បធម៌ និងរបៀបរបបធ្វើការអភិវឌ្ឍន៍ដោយមានការចូលរួម (កសាងផែនការ, គ្រប់គ្រង, កេណ្ឌប្រមូលធនធាន) នៅកំរិតមូលដ្ឋានតាមរយៈក្រុមប្រឹក្សាឃុំ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រជាជន, និង
- រួមចំនែកកាត់បន្ថយភាពក្រីក្រក្នុងប្រទេស តាមរយៈការកែលំអលក្ខខណ្ឌផ្តល់សេវា និងបង្កើតព្រមទាំងផ្តល់ឱកាសល្អដល់អ្នកក្រនិងអ្នកខ្វះខាត នៅក្នុងការរីកលូតលាស់និងការផ្តល់សេវានៅក្នុងមូលដ្ឋាន (ការអនុវត្តន៍ជាក់ស្តែងនូវការរាប់បញ្ចូល)[៦] ។

ជាអកុសល ទិសដៅដ៏ខ្ពង់ខ្ពស់ទាំងនេះ បានជួយតិចតួចណាស់ដល់ការកសាងច្បាប់និងបទប្បញ្ញត្តិច្បាស់លាស់និងគ្រប់ជ្រុងជ្រោយដែលជាប់ទាក់ទងនឹងវិមជ្ឈការ ឬក៏ជួយដល់ការបកស្រាយច្បាប់និងបទប្បញ្ញត្តិនានាដែលបានអនុម័តហើយ ។

ដោយសារពុំមានឯកសារគោលនយោបាយច្បាស់លាស់ស្តីពីដំណើរការវិមជ្ឈការនៅកម្ពុជា រដ្ឋាភិបាលត្រូវពឹងផ្អែកតែទៅលើសេចក្តីថ្លែងក្នុងរដ្ឋធម្មនុញ្ញ[៧] ស្តីពីការគ្រប់គ្រងរបស់រដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់, និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់, តែប៉ុណ្ណោះ ។

### *៤.២ អង្គភាពនានាជាប់ទាក់ទិនក្នុងការកសាងគោលនយោបាយវិមជ្ឈការ*

ទាក់ទិននឹងការកសាងគោលនយោបាយវិមជ្ឈការ រួមទាំងការកសាងច្បាប់ដែលមានមុខងារដូចគោលនយោបាយដែរ (ដោយសារគ្មានគោលនយោបាយ) មានអង្គភាពជាច្រើនដែលជាប់ទាក់ទងក្នុងកំរិតខុសៗគ្នា ជាពិសេស ៣អង្គភាពពហុក្រសួង គឺក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR), ក្រុមការងារសិលា (STF) និងគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) ។ ការទាក់ទិនរបស់ CAR មានលក្ខណៈប្រយោល តាមរយៈគំនិតផ្តួចផ្តើមខាងកំណែទំរង់អភិបាលកិច្ចជាទូទៅ និងការជះឥទ្ធិពលទៅលើវិមជ្ឈការ ។ STF មានអាណត្តិ "រចនាតាក់តែងយន្តការ និងប្រព័ន្ធផ្សេងៗខាងវិមជ្ឈការនិង វិសហមជ្ឈការសំរាប់គ្រប់គ្រងការអភិវឌ្ឍន៍មូលដ្ឋានមានចីរភាព" និងសំរាប់ "វាយតំលៃពីភាពសក្តិសិទ្ធិនៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការក្នុងការរួម

---

[៥] ក្រសួងមហាផ្ទៃ បានចេញអនុស្សារណៈមួយបញ្ជាក់គ្រួសៗពីវិសាលភាព និងខ្លឹមសារនៃវិមជ្ឈការនៅកម្ពុជា (មេសា ២០០០) ប៉ុន្តែរដ្ឋាភិបាលមិនទាន់អនុម័តយកឯកសារនេះធ្វើជាគោលនយោបាយផ្លូវការទេ ។

[៦] យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ទំព័រ ១០៨ ។

[៧] មាត្រា ១៤៥ និង ១៤៦ ។

ចំណែកអនុវត្តគោលដៅនានារបស់ជាតិ និងចងក្រងបទពិសោធន៍ដែលរៀនសូត្របានដើម្បីផ្តល់ជូនស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល សំរាប់រៀបចំគោលនយោបាយ និងបទប្បញ្ញត្តិផ្សេងៗ"[៨] ។ NCSC មានភារកិច្ចចំបងជួយមើលខុសត្រូវលើការកសាងគោលនយោបាយវិមជ្ឈការនៅមុនពេលបោះឆ្នោតលើកក្រោយ ដោយមានអាណត្តិដែល ចែងយ៉ាងជាក់លាក់ឱ្យទទួលខុសត្រូវលើ "ការរៀបចំ និងអនុវត្តន៍គោលនយោបាយវិមជ្ឈការ"[៩] ។

ក្រៅពីអង្គភាពទាំងនេះ ក្រសួងជំនាញនានាក៏បានផ្តល់ធាតុចូលទៅដល់ការកសាងគោលនយោបាយ និងច្បាប់នានា ទៅតាមដែនសមត្ថកិច្ចរបស់ពួកគេ ។ ក្រសួងពាក់ព័ន្ធចំបងបំផុតគឺ MoI ដែលមានសមត្ថកិច្ចគ្រប់គ្រងលើអាជ្ញាធរកំរិតខេត្ត/ស្រុក នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DOLA) អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង (POLA), និងដែលទទួលខុសត្រូវធ្វើការចាត់តាំង និងគ្រប់គ្រងពួកស្មៀនឃុំទៀតផង ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) ក៏ដើរតួនាទីសំខាន់ដែរ ដោយមានសិទ្ធិអំណាចចំបងគេក្នុងការត្រួតពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុឃុំ ព្រមទាំងត្រូវកសាង និងធ្វើច្បាប់គ្រប់គ្រងប្រព័ន្ធប្រភពចំណូលផ្ទាល់របស់ឃុំ ។ ក្រសួងផែនការទទួលខុសត្រូវកសាងនីតិវិធីធ្វើផែនការអភិវឌ្ឍន៍ឃុំ ។ ក្រសួងអភិវឌ្ឍន៍ជនបទដែលមានប្រពៃណីជួយទ្រទ្រង់ដល់ ការកសាងផែនការភូមិ និងអន្តរកម្មរបស់ភូមិជាមួយឃុំ, នឹងមានសិទ្ធិផ្តល់មតិនៅក្នុងច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹង តួនាទីរបស់ភូមិនៅក្នុងអភិបាលកិច្ចបែបវិមជ្ឈការ ។ ក្រសួងជំនាញក្នុងវិស័យច្រើនទៀតដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ជាដើម អាចផ្តល់ធាតុចូលទៅតាមវិស័យ ជំនាញរបស់ខ្លួន ហើយក៏អាចផ្ទេរមុខងារទីភ្នាក់ងារផ្សេងៗទៅឱ្យឃុំ ដើម្បីជួយគាំទ្រដល់គោលនយោបាយវិមជ្ឈការផងដែរ[១០] ។

ដោយមានភាគីជាច្រើនដែលអាចជួយផ្តល់ធាតុចូលសំរាប់គោលនយោបាយវិមជ្ឈការ វាការសំខាន់ដែលត្រូវមានរចនាសម្ព័ន្ធសំរបសំរួលចំបងមួយសំរាប់មើលខុសត្រូវលើការកសាងគោលនយោបាយ រួមទាំងការកសាងច្បាប់និងបទប្បញ្ញតិនានា ពីព្រោះជារឿយៗច្បាប់ត្រូវបានប្រើជំនួសឱ្យគោលនយោបាយ នៅពេលមិនទាន់មានឯកសារគោលនយោបាយច្បាស់លាស់ ។ តួនាទីនេះត្រូវបានប្រគល់ទៅឱ្យ NCSC ប៉ុន្តែនៅមានចម្ងល់ថា តើការសំរបសំរួលធ្វើបានល្អប៉ុណ្ណា ។ ឧទាហរណ៍ NCSC ជាប់រវល់ខ្លាំងក្នុងការដោះស្រាយភារកិច្ចផ្សេងៗទៀត ដូចជា ជួយតាក់តែងច្បាប់និងបទប្បញ្ញត្តិមួយចំនួនដែលប៉ះពាល់ផ្ទាល់ដល់រដ្ឋបាលឃុំ ហើយមានពេលតិចតួចណាស់សំរាប់ពិនិត្យមើលឡើងវិញនូវ ច្បាប់និងបទប្បញ្ញត្តិឯទៀតៗដែលអាចជះឥទ្ធិពលដល់ឃុំ ដូចជា អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដែលបានផ្ទេរភារកិច្ចដ៏ស្មុគស្មាញទៅឱ្យក្រុមប្រឹក្សាឃុំ ប៉ុន្តែហាក់ដូចពុំមានចែងអ្វីសោះពីការផ្តល់ជំនួយទ្រទ្រង់ខាងហិរញ្ញវត្ថុ ឬសមត្ថភាព ស្របទៅតាមការតំរូវក្នុងច្បាប់[១១] ។

ក្រៅពីមានបន្ទុកច្រើនពេកក្នុងអាណត្តិបច្ចុប្បន្នរបស់ខ្លួន, តាមការតំរូវក្នុង LAMC អង្គភាពសំរបសំរួលគោលនយោបាយវិមជ្ឈការដ៏សំខាន់នេះនឹងត្រូវចប់អាណត្តិ ៩ខែមុនថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំលើកក្រោយ[១២] ។ ការកសាងគោលនយោបាយនិងច្បាប់នានា នឹងត្រូវបន្តធ្វើនៅក្រោយថ្ងៃនោះទៀត ហើយតើនរណានឹងបន្តតួនាទីបច្ចុប្បន្នរបស់ NCSC? បើសិន NCSC ត្រូវបន្តអាណត្តិរបស់ខ្លួន ដូច្នេះរដ្ឋសភាត្រូវធ្វើវិសោធនកម្ម LAMC ទៅតាមនោះ ។ យោងតាមរយៈពេលដែលត្រូវចំណាយដើម្បីអនុម័ត ឬធ្វើវិសោធនកម្មច្បាប់, ការសំរេចថាត្រូវ បន្ត ឬមិនបន្ត អាណត្តិរបស់ NCSC ត្រូវតែធ្វើឡើងយ៉ាងយូរ

---

[៨] អនុក្រឹត្យ STF មាត្រា ៣ ។

[៩] រាជក្រឹត្យ NCSC មាត្រា ៣ ។

[១០] MLMUPC បានអនុវត្តការងារនេះមួយតាមរយៈការអនុមតិ អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។

[១១] សូមអានផ្នែក ១០.១.១ ស្តីពីការផ្តល់មុខងារទីភ្នាក់ងារដល់ក្រុមប្រឹក្សាឃុំ សំរាប់ការពិភាក្សាលំអិតថែមទៀតលើបញ្ហាដ៏សំខាន់នេះ ។

[១២] LAMC មាត្រា ៨៧ កថាខ័ណ្ឌ ៣ ។

បំផុតត្រឹមដើមឆ្នាំ២០០៥[១៣] ។

### *៤.៣ ការកសាងគោលនយោបាយវិមជ្ឈការសព្វថ្ងៃ*

ដូចបានបញ្ជាក់រួចហើយ ក្រៅពីច្បាប់និងបទប្បញ្ញត្តិដែលបានដាក់អនុវត្ត និងសេចក្តីប្រកាសបែបទូលំទូលាយមួយចំនួនស្តីពីគោលគំនិត, សព្វថ្ងៃនៅមិនទាន់មានគោលនយោបាយអ្វីច្បាស់លាស់ទេសំរាប់តំរង់ទិសដំណើរការវិមជ្ឈការ ។ ក្នុងកិច្ចសន្ទនាជាមួយបុគ្គលដែលធ្វើការនៅក្នុង DOLA មានសេចក្តីរាយការណ៍ថា បច្ចុប្បន្នរដ្ឋាភិបាលកំពុងពិនិត្យមើលឡើងវិញពីបទពិសោធន៍ និងមេរៀនដែលទទួលបានមកទល់ពេលនេះ ក្នុងគោលដៅបង្កើតយុទ្ធសាស្ត្រអនុវត្តន៍គោលនយោបាយវិមជ្ឈការរយៈពេលវែងមួយ ។ គេរាយការណ៍ថា NCSC បានផ្តួចផ្តើមគំនិតកេណ្ឌប្រមូលជំនួយទ្រទ្រង់បច្ចេកទេស ដើម្បីកសាងយុទ្ធសាស្ត្រអនុវត្តន៍រយៈពេលវែងខាងលើ ដោយគ្រោងបញ្ចប់ការងារនេះក្នុងឆ្នាំ២០០៤ ។ ស្របតាមរបាយការណ៍ទាំងនេះដែរ ក្នុងសុន្ទរកថាបិទសន្និបាតជាតិលើកទី១ នៃក្រុមប្រឹក្សាឃុំ/សង្កាត់នៅខែឧសភា ២០០៣ សម្តេចនាយករដ្ឋមន្ត្រីដោយបានថ្លែងថា ត្រូវកសាងយុទ្ធសាស្ត្រអនុវត្តន៍គោលនយោបាយមួយដ៏ច្បាស់លាស់ ដែលដោះស្រាយនូវវិស័យសំខាន់ៗ ក្នុងនេះមានទាំងការបង្កើតឡើងនូវរចនាសម្ព័ន្ធអភិបាលកិច្ចខេត្ត-ក្រុង ផង ។ សេចក្តីថ្លែងនេះបង្ហាញពីការប្តេជ្ញាចិត្តខាងនយោបាយស្តីពីការកសាងគោលនយោបាយវិមជ្ឈការជាយុទ្ធសាស្ត្រមានរយៈពេលវែង និងចំណងទាក់ទងដ៏សំខាន់រវាងវិមជ្ឈការ និងវិសហមជ្ឈការ ។

### *៤.៤ អនុសាសន៍សំរាប់ការកសាងគោលនយោបាយ*

ត្រូវដាក់អនុវត្តគោលនយោបាយវិមជ្ឈការមួយដ៏ច្បាស់លាស់ ដែលមិនគ្រាន់រៀបរាប់ត្រួសៗពីវិធានការត្រូវអនុវត្តក្នុងពេលអនាគតប៉ុណ្ណោះទេ ប៉ុន្តែមានបញ្ជាក់ច្បាស់ផងដែរពីតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អង្គភាពផ្សេងៗ និងពីបែបបទដែលត្រូវអនុវត្តនីតិវិធីឱ្យបានសមស្រប ។ គឺបានន័យថា ត្រូវតាក់តែងឯកសារគោលនយោបាយមួយដែលប្រើភាសាយ៉ាងសាមញ្ញងាយយល់ ដើម្បីបញ្ជាក់ពីរចនាសម្ព័ន្ធនានាដែលត្រូវបង្កើត, អ្នកណាមានសិទ្ធិអំណាច, អ្នកណាត្រូវធ្វើអ្វីខ្លះនិង នៅពេលណា, ហើយនិងនីតិវិធីកែតំរូវសំរាប់ដាក់ប្រើនៅពេលមានបញ្ហារាំងស្ទះនៅក្នុងប្រព័ន្ធ ។ តាមវិធីនេះ គោលនយោបាយដើរតួនាទីជាសេចក្តីណែនាំដ៏ច្បាស់មួយសំរាប់ប្រើប្រាស់នៅពេលតាក់តែង និងធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិនានា ហើយក៏អាចប្រើប្រាស់ផងដែរសំរាប់គោលដៅនៃការងារបកស្រាយ និងអប់រំច្បាប់ ។

ព្រមគ្នានឹងការកសាងឯកសារគោលនយោបាយវិមជ្ឈការ, ការកសាងឯកសារគោលនយោបាយប្រហាក់ប្រហែលគ្នាទាក់ទងនឹងវិសហមជ្ឈការ តួនាទី និងរចនាសម្ព័ន្ធអាជ្ញាធរកំរិតខេត្ត និងស្រុក (ដែលនឹងនាំឱ្យមានការតាក់តែង និងការអនុមតិជាក់ស្តែងនូវច្បាប់រៀបចំអង្គការ) គឺត្រូវតែធ្វើឱ្យស្រេច ។ ហើយសំខាន់បំផុតគឺត្រូវមានការសំរបសំរួល និងសហប្រតិបត្តិការជិតស្និទ្ធរវាងអង្គភាពផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ឯកសារគោលនយោបាយទាំងនេះ ព្រមទាំងការតាក់តែងច្បាប់និងបទប្បញ្ញត្តិជាប់ទាក់ទិន ។

## ៥. ក្របខ័ណ្ឌច្បាប់

ផ្នែកនេះពិនិត្យមើលជាទូទៅពីប្រព័ន្ធច្បាប់នៅកម្ពុជា ព្រមទាំងច្បាប់និងបទប្បញ្ញត្តិចំបងៗដែលបានអនុម័តកន្លងមកដើម្បីទ្រទ្រង់ដល់គោលនយោបាយស្តីពីវិមជ្ឈការដែលមានស្រាប់ ។

### *៥.១ ការពិនិត្យមើលជាទូទៅពីប្រព័ន្ធច្បាប់នៅកម្ពុជា*

នៅកម្ពុជា ប្រព័ន្ធច្បាប់ឃើញមានក្នុងគ្រប់រចនាសម្ព័ន្ធអភិបាលកិច្ចដែលត្រូវបានបង្កើតឡើងនៅក្រោមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស ។ ប្រព័ន្ធរដ្ឋអំណាចមានគោលដៅរក្សាការបែងចែកអំណាចយ៉ាងច្បាស់លាស់រវាង នីតិបញ្ញត្តិ

[១៣] សូមអានផ្នែកទី ៥.១ ការពិនិត្យមើលពីប្រព័ន្ធច្បាប់នៅកម្ពុជា ដើម្បីស្វែងយល់ពីពេលវេលាជាប់ទាក់ទិននឹងដំណើរការធ្វើច្បាប់ ។

នីតិប្រតិបត្តិ និងតុលាការ ។ "ការបែងចែកអំណាចធានាថា ពុំមានសមាសភាគ ឬផ្នែកណាមួយនៃរដ្ឋអំណាច ដែលអាចក្តោបក្តាប់អំណាចទាំងអស់ ឬអំណាចផ្តាច់ការបានឡើយ ហើយវាក៏ជារបាំងការពារប្រជាជនប្រឆាំងនឹងការរំលោភបំពានពីសំណាក់រដ្ឋអំណាច"[១៤] ។ យោងតាមកំសោយ និងកង្វះសមត្ថភាពខាងនីតិបញ្ញត្តិ និងតុលាការ, ការបែងចែកអំណាចនេះពុំមានដំណើរការសក្តិសិទ្ធិល្អគ្រប់គ្រាន់ទេ ដោយខាងនីតិប្រតិបត្តិដែលដឹកនាំដោយនាយករដ្ឋមន្ត្រី បានកាន់កាប់អំណាចភាគច្រើន និងមានឥទ្ធិពលនៅក្នុងការធ្វើសេចក្តីសំរេចផ្សេងៗនៅក្នុង ២ផ្នែកផ្សេងទៀត ។ ក្នុងចំណោមអំណាចទាំងបី ផ្នែកតុលាការនៅទន់ខ្សោយជាងគេ ប៉ុន្តែសព្វថ្ងៃមានការប្រឹងប្រែងជាច្រើនដើម្បីកែតំរូវស្ថានភាពវិញ ដូចជា ការអនុម័តក្នុងពេលថ្មីៗនូវគោលនយោបាយកំណែទំរង់តុលាការនិងប្រព័ន្ធច្បាប់ ដែលតាក់តែងឡើងដោយក្រុមប្រឹក្សាកំណែទំរង់តុលាការ និងច្បាប់ ។

ផ្នែកនីតិបញ្ញត្តិចែកចេញជា រដ្ឋសភា និង ព្រឹទ្ធសភា ដែលមានអំណាចអនុម័តយល់ព្រម និងធ្វើវិសោធនកម្មលើច្បាប់ដាក់ស្នើឡើងដោយស្ថាប័នទាំងពីរ ឬដោយរដ្ឋាភិបាល ។ អំណាចនីតិប្រតិបត្តិ រួមមាន នាយករដ្ឋមន្ត្រី, គណៈរដ្ឋមន្ត្រី (ឬរាជរដ្ឋាភិបាលកម្ពុជា), និងក្រសួងជំនាញនានា ។ អំណាចតុលាការ រួមមាន តុលាការខេត្ត ១៩, តុលាការក្រុង ២, តុលាការយោធា ១, សាលាឧទ្ធរណ៍ ១ និង តុលាការកំពូល ១ នៅភ្នំពេញ ។ ក្រសួងយុត្តិធម៌ និង អង្គការអយ្យការ អនុវត្តច្បាប់និងនីតិវិធីខាងព្រហ្មទណ្ឌ និងទទួលខុសត្រូវលើប៉ូលីសយុត្តិធម៌ ក្នុងការដាក់ពង្រឹងការអនុវត្តន៍ច្បាប់ទាំងអស់តាមរយៈតុលាការ[១៥] ។

ច្បាប់ និងបទប្បញ្ញត្តិនានារបស់កម្ពុជា មានលំដាប់ឋានានុក្រម ហើយឯកសារច្បាប់នីមួយៗមានសុពលភាព និងកំលាំងអនុវត្ត ចេញមកពីច្បាប់ដែលស្ថិតនៅខាងលើវា ។ ឋានានុក្រមច្បាប់មានរៀបរាប់ត្រួសៗដូចតទៅ:

១. រដ្ឋធម្មនុញ្ញ

២. ច្បាប់

៣. រាជក្រឹត្យ

៤. អនុក្រឹត្យ

៥. ប្រកាស (សេចក្តីសំរេចរបស់ក្រសួង)

៦. សារាចរ

៧. ដីកា (បទប្បញ្ញត្តិក្នុងមូលដ្ឋាន)

តាមឋានានុក្រមនេះ គេអាចធ្វើការសង្កេតជាទូទៅមួយចំនួនពីពេលវេលា និងវិសាលភាព។ បើឧបករណ៍ច្បាប់ត្រូវអនុម័តមានកំរិតកាន់តែខ្ពស់កាលណា គេនឹងត្រូវចំនាយពេលកាន់តែច្រើនកាលនោះ ដោយសារមានការត្រួតពិនិត្យនៅតាមកំរិតផ្សេងៗដែលត្រូវឆ្លងកាត់ ។ ឧទាហរណ៍ ច្បាប់មួយដែលតាក់តែងនៅកំរិតរដ្ឋាភិបាល ត្រូវឆ្លងកាត់ដំណើរការត្រួតពិនិត្យនៅគណៈរដ្ឋមន្ត្រី រដ្ឋសភា និងព្រឹទ្ធសភា ជាចុងបញ្ចប់ ប៉ុន្តែ ប្រកាសត្រូវបានពិនិត្យឡើងវិញយ៉ាងសាមញ្ញតែនៅក្នុងក្រសួងដែលអនុម័តវាចេញប៉ុណ្ណោះ[១៦] ។

---

[១៤] គោលនយោបាយកំណែទំរង់តុលាការ និងច្បាប់ ទំព័រ៨ ដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រី (២០ មិថុនា ២០០៣) ។

[១៥] រដ្ឋធម្មនុញ្ញ ជំពូក ៧-១១ ។

[១៦] បន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នានាអាចត្រូវបានពិនិត្យឡើងវិញពីធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែលុះត្រាតែមានសំណើពីព្រះមហាក្សត្រ, ប្រធានព្រឹទ្ធសភា, ប្រធានរដ្ឋសភា, នាយករដ្ឋមន្ត្រី, ១ភាគ៤ នៃសមាជិកព្រឹទ្ធសភា, ១ភាគ១០ នៃសមាជិករដ្ឋសភា, ឬ

ទិដ្ឋភាពមួយទៀតដែលគួរពិចារណាគឺ វិសាលភាពនៃឯកសារច្បាប់/បទប្បញ្ញត្តិ ។ ច្បាប់មានវិសាលភាពទូលំទូលាយ និងអនុវត្តលើគ្រប់អង្គភាពរដ្ឋាភិបាល និងទីតាំងភូមិសាស្ត្រនៅក្នុងប្រទេស លើកលែងតែនៅក្នុងអត្ថបទច្បាប់នោះ មានសេចក្តីចែងជាក់លាក់ពីការកាត់បន្ថយវិសាលភាព ។ ប្រកាសមានលក្ខណៈត្រូវប្រតិបត្តិតាមតែនៅក្នុងក្រសួងដែលអនុម័តវាចេញ ហើយដីកាក៏មានកំលាំងបង្ខំអនុវត្តតែនៅក្នុងតំបន់ភូមិសាស្ត្រនៃខេត្ត ឬឃុំដែលអនុម័តវាចេញដូចគ្នា។ បញ្ហាពេលវេលា និងវិសាលភាពនេះ មានបញ្ជាក់លំអិតក្នុងការពន្យល់ពីឯកសារច្បាប់ដូចខាងក្រោម និងមានបង្ហាញក្នុងក្រាហ្វិច "ដែនអនុវត្តឯកសារច្បាប់ធៀបនឹងចន្លោះពេលអនុម័ត" ក្នុងឧបសម្ព័ន្ធ ក ។

ច្បាប់: នេះជាប្រភពចំបងគេនៃបទប្បញ្ញត្តិផ្លូវការនៅកម្ពុជា ។ ច្បាប់ត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ។ ជាញឹកញយ គេច្រឡំច្បាប់ ជាមួយនឹង ក្រម ដែលជាទំរង់មួយនៃរាជក្រឹត្យសំរាប់ការប្រកាសឱ្យប្រើច្បាប់ដោយព្រះមហាក្សត្រ ឬប្រមុខរដ្ឋ ។ ដំណើរការប្រកាសឱ្យប្រើច្បាប់មួយដែលស្នើឡើងដោយរដ្ឋាភិបាល ត្រូវការពេលច្រើនដូចបានបញ្ជាក់នៅខាងលើ ហើយតាមធម្មតាវាប្រព្រឹត្តទៅតាមនីតិវិធីដូចខាងក្រោម[១៧]:

១. ការរៀបចំសេចក្តីព្រាងច្បាប់ដោយក្រសួងជំនាញបច្ចេកទេសមួយ ដូចជា ក្រសួងមហាផ្ទៃ ជាដើម ។

២. ការពិភាក្សាលើសេចក្តីព្រាងច្បាប់ក្នុងកិច្ចប្រជុំអន្តរក្រសួង (ឬបើសិនជាចាំបាច់នៅក្នុងសាមីក្រសួងជាប់ទាក់ទិនខ្លួនឯង) ។ ជារឿយៗ ក៏មានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ (ម្ចាស់ជំនួយ សង្គមស៊ីវិល វិស័យឯកជន។ល។) ផងដែរ ។

៣. ការសិក្សាសេចក្តីព្រាងច្បាប់ដោយក្រុមប្រឹក្សាអ្នកច្បាប់ ដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យបញ្ជាក់ពីភាពស្របតាមរដ្ឋធម្មនុញ្ញ, ភាពរលូនគ្នាជាមួយនឹងច្បាប់ដែលមានស្រាប់ ។ល។

៤. ការពិភាក្សាពីសេចក្តីព្រាងច្បាប់នៅកំរិតអន្តរក្រសួង ដែលស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី ។

៥. ការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

៦. ការដាក់សេចក្តីព្រាងច្បាប់ ជូនរដ្ឋសភា ។ សេចក្តីព្រាងច្បាប់ ត្រូវបានដាក់ស្នើឡើងក្នុងទំរង់ជាលាយលក្ខណ៍អក្សរ អមដោយ "សេចក្តីប្រកាសពីគោលបំណង" មួយ ទៅជូនគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីចែកចាយទៅដល់គ្រប់សមាជិករដ្ឋសភា ។ គណៈកម្មការអចិន្ត្រៃយ៍ បញ្ជូនសេចក្តីព្រាងច្បាប់ ទៅឱ្យគណៈកម្មការជំនាញដើម្បីត្រួតពិនិត្យ ។ ក្រោយពិនិត្យរួច ប្រធានគណៈកម្មការបង្ហាញមតិរបស់គណៈកម្មការជូនរដ្ឋសភា ។

៧. ការពិនិត្យ និងពិភាក្សាដេញដោលលើសេចក្តីព្រាងច្បាប់ រួមទាំងការកែតំរូវផ្សេងៗ ក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា ។

៨. ការបោះឆ្នោតលើសេចក្តីព្រាងច្បាប់ដោយរដ្ឋសភា (តាមមតិភាគច្រើនដោយប្រៀប) ។

៩. ដាក់ជូនច្បាប់ដែលបានអនុម័តដូចខាងលើ ទៅព្រឹទ្ធសភា ដែលត្រូវពិនិត្យ និងផ្តល់អនុសាសន៍ ក្នុងរយៈពេលមិនលើសពី ១ខែ ។ ចំពោះបញ្ហាបន្ទាន់ រយៈពេលត្រូវកាត់បន្ថយមកត្រឹម ៧ថ្ងៃ ។ បើសិនព្រឹទ្ធសភា មិនបានផ្តល់

តុលាការ ។ ក្រុមប្រឹក្សាធម្មនុញ្ញ គ្មានសិទ្ធិអំណាចសើរើពិនិត្យច្បាប់លើបញ្ហាដែលមិនជាប់ទាក់ទងនឹងរដ្ឋធម្មនុញ្ញទេ ហើយក៏គ្មានសិទ្ធិអំណាចសើរើពិនិត្យឧបករណ៍ច្បាប់ផ្សេងៗទៀតដូចជា អនុក្រឹត្យ ឬប្រកាស ដែរ ។

[១៧] នីតិវិធីនេះ អនុវត្តដូចគ្នាចំពោះការធ្វើវិសោធនកម្មច្បាប់ ។

អនុសាសន៍ក្នុងរយៈពេលតាមកំរិតកំណត់នេះទេ ច្បាប់នោះនឹងត្រូវបានប្រកាសឱ្យប្រើ ។ បើសិនព្រឹទ្ធសភា ស្នើឱ្យមានការផ្លាស់ប្តូរ រដ្ឋសភាត្រូវលើកមកពិនិត្យជាបន្ទាន់ ។ ក្នុងពេលពិនិត្យឡើងវិញជាលើកទី ២ នៃច្បាប់ដែលបានអនុម័តម្តងហើយ រដ្ឋសភាត្រូវធ្វើការអនុម័តតាមមតិភាគច្រើនដាច់ខាត ។

១០. ការប្រកាសឱ្យប្រើច្បាប់ដោយព្រះមហាក្សត្រ ឬប្រមុខរដ្ឋ (ក្រម) ។

សេចក្តីសំរេចណាមួយដើម្បីធ្វើវិសោធនកម្ម LAMC ត្រូវតែគិតគូរពីនីតិវិធី និងកំហិតខាងពេលវេលាដែលជាប់ទាក់ទិន។

រាជក្រឹត្យៈ រដ្ឋធម្មនុញ្ញចែងថា "តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច មន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា..."[១៨] ។ បទប្បញ្ញត្តិនេះ ត្រូវបានរដ្ឋាភិបាលប្រើប្រាស់ដើម្បីបង្កើតអង្គភាពកំរិតពហុក្រសួង ដូចជា NCSC និង ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

*អនុក្រឹត្យៈ* គឺជាឯកសារច្បាប់ដែលជាទូទៅត្រូវបានប្រើប្រាស់ដើម្បីដាក់អនុវត្ត និងផ្តល់ការបំភ្លឺលើបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងច្បាប់ ប៉ុន្តែក៏មានប្រើផងដែរដើម្បីបញ្ជាក់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពរដ្ឋ (ក្រសួង-មន្ទីរ) ឬដើម្បីតែងតាំងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ។ អនុក្រឹត្យច្រើនតាក់តែងឡើងដោយក្រសួងមួយ ឬក្រសួងច្រើនរួមគ្នា ដែលមានសមត្ថកិច្ចនៅក្នុងវិស័យត្រូវធ្វើអនុក្រឹត្យនេះ។ នៅពេលតាក់តែងរួច អនុក្រឹត្យត្រូវដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងអនុម័ត[១៩] ។ នៅពេលគណៈរដ្ឋមន្ត្រីបានអនុម័តយល់ព្រមហើយ អនុក្រឹត្យត្រូវបានចុះហត្ថលេខាដោយ នាយករដ្ឋមន្ត្រី និងចុះហត្ថលេខាអមដោយរដ្ឋមន្ត្រីម្នាក់ ឬច្រើននាក់ដែលទទួលបន្ទុកអនុវត្ត និងពង្រឹងការអនុវត្តន៍។ សិទ្ធិអំណាចដើម្បីបង្កើតអនុក្រឹត្យទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ត្រូវចេញមកពីបទប្បញ្ញត្តិជាផ្លូវការដែលមានកំរិតខ្ពស់ជាង ដូចជា ច្បាប់ ជាដើម ។ ដោយសារអនុក្រឹត្យត្រូវបានអនុម័តនៅកំរិតគណៈរដ្ឋមន្ត្រី ដូច្នេះវិសាលភាពរបស់វាមានលក្ខណៈធំទូលាយគួរសម ។

*ប្រកាសៈ* គឺជាបទប្បញ្ញត្តិរបស់ក្រសួង ឬអន្តរក្រសួង ដែលត្រូវបានប្រើប្រាស់ដូចអនុក្រឹត្យដែរ ដើម្បីអនុវត្ត និងផ្តល់ការបំភ្លឺនូវបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងឯកសារច្បាប់កំរិតខ្ពស់ជាង។ ជារឿយៗគេប្រើប្រកាសដើម្បីផ្តល់សេចក្តីណែនាំដ៏ចាំបាច់នានាសំរាប់ការដាក់អនុវត្តន៍ច្បាប់ ឬអនុក្រឹត្យ ។ តាមធម្មតា ប្រកាសត្រូវបានតាក់តែងនៅកំរិតនាយកដ្ឋានបច្ចេកទេស ហើយបន្ទាប់មកចុះហត្ថលេខាឱ្យមានប្រសិទ្ធភាពប្រើប្រាស់ដោយរដ្ឋមន្ត្រីម្នាក់ (ឬច្រើននាក់) នៃក្រសួងដែលត្រូវអនុវត្តប្រកាសនោះ។ គួរកត់សំគាល់ថា នៅកម្ពុជា ប្រកាសភាគច្រើនត្រូវបានប្រើប្រាស់ដើម្បីអនុវត្តច្បាប់ ហើយមេរៀនដែលរៀនសូត្របាន អាចដាក់បញ្ចូលយ៉ាងឆាប់ ពីព្រោះដំណើរការអនុម័តប្រកាសមានលក្ខណៈសាមញ្ញ និងលឿន ។ គុណវិបត្តិនៃប្រកាស គឺដែនអនុវត្តមានកំរិតព្រំដែនត្រឹមតែសាមីក្រសួងអ្នកអនុម័តវាចេញប៉ុណ្ណោះ ហើយក្រសួង និងអង្គភាពរដ្ឋឯទៀតៗពុំមានអារម្មណ៍ថាខ្លួនមានកាតព្វកិច្ចត្រូវគោរពតាមប្រកាសនោះជានិច្ចជាកាលទេ ។

*សារាចរៈ* គឺជាឯកសារច្បាប់ចេញដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ដើម្បីពន្យល់ ឬបំភ្លឺនូវវិធានការខាងច្បាប់ ឬក៏ដើម្បីដាក់បទបញ្ជា ។ ដូចប្រកាសដែរ សារាចរមានដែនអនុវត្តតូច ប៉ុន្តែងាយអនុម័តចេញ ។

*ដីកាៈ* គឺជាបទបញ្ជាចេញដោយអភិបាលខេត្ត ឬក្រុមប្រឹក្សាឃុំសង្កាត់ ដែលមានកំលាំងជាច្បាប់នៅក្នុងដែនភូមិសាស្ត្រ

[១៨] រដ្ឋធម្មនុញ្ញ មាត្រា ២១ ។

[១៩] ដំណាក់កាលផ្សេងៗសំរាប់ការអនុមតិអនុក្រឹត្យ មានដូចគ្នានឹងចំណុច ១-៥ សំរាប់ការអនុមតិច្បាប់ ។

ឬសិទ្ធិអំណាចជាអាជ្ញាធរដែនដីនៃថ្នាក់ដឹកនាំទាំងនេះ ។ ដីកាមិនអាចប្រឆាំងនឹងច្បាប់ ឬបទប្បញ្ញត្តិ នៅកំរិតជាតិទេ ។ ដីកាកំរិតឃុំ ក៏មិនអាចផ្ទុយគ្នាពីដីកាខេត្តដែរ ។

### ៥.២ ច្បាប់ និងបទប្បញ្ញត្តិចំបងៗបានអនុម័តរួចហើយដើម្បីទ្រទ្រង់ដល់វិមជ្ឈការ

ដូចមានបង្ហាញក្នុងបញ្ជីនៃច្បាប់និងបទប្បញ្ញត្តិបានអនុម័តកន្លងមក (ចុះក្នុងឧបសម្ព័ន្ធ ខ) មានឯកសារខាងច្បាប់យ៉ាងច្រើន ដែលស្មុគស្មាញ និងពិបាកតាមដាន និងដែលត្រូវបានអនុម័តក្នុងរយៈពេលមួយដ៏ខ្លី ដើម្បីជួយទ្រទ្រង់ដល់វិមជ្ឈការ ។ គួរលើកសរសើរដល់រដ្ឋាភិបាលដែលអាចកសាងបាននូវក្របខ័ណ្ឌច្បាប់នេះក្នុងរយៈពេលមួយដ៏ខ្លី ជាពិសេសបើពិនិត្យតាមការពិតជាក់ស្តែងដែលរចនាសម្ព័ន្ធទាំងអស់នេះ បានធ្វើឱ្យគោលនយោបាយវិមជ្ឈការនៅកម្ពុជាអាចអនុវត្តទៅបាន ។ នៅខាងក្រោមគឺជាបញ្ជីនៃច្បាប់និងបទប្បញ្ញត្តិចំបងៗ ដែលបានអនុម័តកន្លងមក ។

<u>ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC):</u> នេះជាច្បាប់ដែលដើរតួនាទីជាឯកសារគោលនយោបាយគន្លឹះ និងជាគំរោងផែនការសំរាប់កម្មវិធីវិមជ្ឈការ ។ LAMC បានកំនត់ពីចំណុចសំខាន់ៗជាប់ទាក់ទងដល់តួនាទី ភារកិច្ច និងមុខងារនៃអង្គភាពផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងវិមជ្ឈការ ព្រមទាំងបានបើកការអនុញ្ញាតចំពោះឯកសារច្បាប់សំរាប់ជួយគាំទ្រផ្សេងៗដែលមានតំរូវការអនុម័តចេញ, ប៉ុន្តែមិនបានកំណត់ពីរយៈពេលដែលត្រូវអនុម័តឯកសារទាំងនេះទេ ។ ដូចច្បាប់នានាជាទូទៅនៅកម្ពុជាដែរ, LAMC មានខ្លឹមសារទូលំទូលាយណាស់ ហើយបទប្បញ្ញត្តិខ្លះមានន័យស្រពិចស្រពិលទៀតផង ដូច្នេះត្រូវមានសេចក្តីបញ្ជាក់លំអិតដូចធម្មតានៅក្នុងអនុក្រឹត្យ និងប្រកាស សំរាប់ជួយគាំទ្រនានា ។

<u>ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់:</u> ច្បាប់នេះកំណត់ពីវិធាន និងបទប្បញ្ញត្តិទាំងអស់ សំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំនៅកម្ពុជា ។ ខុសប្លែកពីច្បាប់ឯទៀតៗ ច្បាប់នេះមានលក្ខណៈលំអិត និងវែងខ្លាំងណាស់ ហើយរឿងនេះកើតចេញពីការពិតជាក់ស្តែងដែលត្រូវមានវិធាននិងបទប្បញ្ញត្តិទាំងអស់និងស្រេចបាច់ មុនពេលធ្វើការបោះឆ្នោតក្រុមប្រឹក្សាឃុំលើកទី១ នៅខែកុម្ភៈ ២០០២ ។ ការអនុមតិច្បាប់ក្នុងទំរង់នេះ គឺជាសញ្ញាបង្ហាញពីការប្តេជ្ញាចិត្តខាងនយោបាយដ៏រឹងមាំចំពោះដំណើរការធ្វើវិមជ្ឈការ ។

<u>រាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC):</u> រាជក្រឹត្យនេះបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់ NCSC ។

<u>អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់:</u> អនុក្រឹត្យនេះបំពេញបន្ថែមនូវចំណុចលំអិតជាច្រើនដែលនៅខ្វះចន្លោះនៅក្នុង LAMC និងណែនាំពីទស្សនៈមួយចំនួនដែលនឹងមានពន្យល់យ៉ាងពេញលេញថែមទៀតនៅក្នុងឯកសារគាំទ្រផ្សេងៗ ដូចជា ប្រកាសស្តីពីស្មៀនឃុំ/សង្កាត់ ជាដើម ។

<u>អនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ/សង្កាត់:</u> អនុក្រឹត្យនេះចែងពីចំណុចលំអិតនានាដើម្បីបង្កើត និងគ្រប់គ្រងមូលនិធិឃុំ រួមទាំងវិធានជាមូលដ្ឋានសំរាប់ការផ្ញើមូលនិធិឃុំនៅក្នុងរតនាគារខេត្ត និងវិធានបញ្ជាក់ពីតួនាទី និងភារកិច្ច របស់អភិបាលខេត្ត និងរតនាគារខេត្ត ។

<u>អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់:</u> អនុក្រឹត្យនេះចែងពីចំណុចលំអិតនានាសំរាប់គ្រប់គ្រងហិរញ្ញវត្ថុឃុំរួមទាំងវិធានស្តីពីការកសាង ការអនុមតិ និងការអនុវត្តន៍ ថវិកាឃុំ, ប្រព័ន្ធគណនេយ្យ និងការទូទាត់, របាយការណ៍ហិរញ្ញវត្ថុ, ការគ្រប់គ្រងចំណូលចំណាយ, ការគ្រប់គ្រងទ្រព្យជាប់លាប់, និងសវនកម្មលើគណនេយ្យនិងប្រតិបត្តិការ ។ ឯកសារនេះជាគន្លឹះ

មួយដ៏សំខាន់ ពីព្រោះការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាតួនាទីមួយក្នុងចំណោមតួនាទីមួយចំនួនតូចរបស់ក្រុមប្រឹក្សាឃុំ ដែលត្រូវបានកំណត់យ៉ាងច្បាស់ ។

ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃអង្គភាពរដ្ឋបាលមូលដ្ឋាននៅតាមខេត្ត (DOLA): ធាតុសំខាន់ (ជារឿយៗមានការកែច្រឡំ) នៃប្រកាសនេះគឺ វាបញ្ជាក់ពីការធ្វើប្រតិភូកម្មភារកិច្ចជាច្រើននៃការប្រស្រ័យទាក់ទង ការឃ្លាំមើល និងការវាយតំលៃ, ពី NCSC និងក្រសួងមហាផ្ទៃ (MoI) ទៅ DOLA ។

ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់: ប្រកាសនេះគឺជាដំណោះស្រាយបណ្តោះអាសន្ន រហូតដល់ ច្បាប់រៀបចំអង្គការ (organic law) ស្តីពីការគ្រប់គ្រងខេត្ត និងស្រុក ត្រូវបានតាក់តែង និងអនុម័ត[២០] ។ ប្រកាសនេះក៏ណែនាំពីការធ្វើប្រតិភូកម្មថែមទៀតនូវតួនាទីធ្វើការ ប្រស្រ័យទាក់ទង ឃ្លាំមើល និងវាយតំលៃពីថ្នាក់ជាតិ ជាពិសេស NCSC, MoI និង DOLA, ទៅថ្នាក់ខេត្ត ។ មានការយល់ច្រឡំម្តងម្កាលដែរ ប៉ុន្តែតាមពិតការធ្វើប្រតិភូកម្មនេះ មិនមែនទៅឱ្យអភិបាលខេត្តតែម្នាក់ទេ តែទៅឱ្យអាជ្ញាធរថ្នាក់ខេត្ត ពីព្រោះបុគ្គលតែម្នាក់មិនអាចដោះស្រាយបានទេនូវភារកិច្ចនានាដែលត្រូវបានធ្វើប្រតិភូកម្មមកនោះ ។

ប្រកាសស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុងនៃកម្មវិធីសិលា: ដូចប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុងខាងលើដែរ ប្រកាសនេះគឺជាដំណោះស្រាយបណ្តោះអាសន្ន រហូតដល់ច្បាប់រៀបចំអង្គការត្រូវបានតាក់តែង និងអនុម័ត ។

ប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ/សង្កាត់: ប្រកាសនេះ បញ្ជាក់ពីមុខងារជាទូទៅរបស់ស្មៀនឃុំ ដែលបំរើការសំខាន់ជាលេខានៃក្រុមប្រឹក្សាឃុំ ។

ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់: ប្រកាសនេះបញ្ជាក់ពីរចនាសម្ព័ន្ធ និងនីតិវិធីជាទូទៅសំរាប់ដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ ។ ដូចអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំដែរ ប្រកាសនេះសំខាន់ណាស់ ពីព្រោះវាស្ថិតក្នុងចំណោមបទប្បញ្ញត្តិមួយចំនួនតូច ដែលបានកំនត់ច្បាស់ និងអាចយល់បានល្អ ពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ ។

## ៦. រចនាសម្ព័ន្ធរដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីទ្រទ្រង់ដល់វិមជ្ឈការ

ផ្នែកនេះមានគោលដៅធ្វើការពិនិត្យជាទូទៅពីរចនាសម្ព័ន្ធរដ្ឋាភិបាល ដែលបានបង្កើតឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ តាមការអនុវត្តន៍គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល ជាពិសេសរចនាសម្ព័ន្ធដែលជាប់ទាក់ទងជាមួយក្រុមប្រឹក្សាឃុំ និងកំរិតផ្សេងៗទៀតនៃរដ្ឋអំណាច ។ ការវិភាគនេះផ្តោតទៅលើរចនាសម្ព័ន្ធ និងខ្សែរយៈទាក់ទងនានា ដែលបានបង្កើតឡើងនៅក្រោម LAMC ព្រមទាំងច្បាប់និងបទប្បញ្ញត្តិជាប់ទាក់ទិននានា, និងរចនាសម្ព័ន្ធដែលបង្កើតឡើងនៅកំរិតខេត្ត និងស្រុក ទៅតាម "ប្រកាសស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុងនៃកម្មវិធីសិលា" (PRDC Prakas) ។ ក្នុងនេះ គឺមានរចនាសម្ព័ន្ធ និងអង្គភាព ដែលបានបង្កើតរួចហើយនៅកំរិតជាតិ ខេត្ត ស្រុក ឃុំ និង ភូមិ, ទៅតាមឯកសារច្បាប់នានាដែលត្រូវបានកសាងឡើង, ហើយនិង បណ្តាអង្គភាពដែលមានពីមុនស្រាប់ និងដែលមានការទទួលខុសត្រូវ

[២០] សូមអានផ្នែកទី៦ ស្តីពីរចនាសម្ព័ន្ធរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រវិមជ្ឈការ ។

ថ្មីៗជាប់ទាក់ទងដោយផ្ទាល់ទៅនឹងក្រុមប្រឹក្សាឃុំ[២១] ។

[២១] ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មិនត្រូវបានដាក់បញ្ចូលក្នុងការវិភាគនេះទេ ពីព្រោះវាជាក្រុមប្រឹក្សាខាងគោលនយោបាយមួយដាច់ដោយឡែក ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងដែលមិនគួរចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋាភិបាលទើបបង្កើតថ្មីនោះទេ។

ផ្នែកនេះមិនគ្រាន់តែផ្តល់ដល់អ្នកអាននូវការពិនិត្យត្រួសៗ និងការយល់ដឹងពីរចនាសម្ព័ន្ធទូទៅដែលត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិមួយដ៏ស្មុគស្មាញងាយភ័ន្តច្រឡំនោះទេ ប៉ុន្តែក៏ចង្អុលបង្ហាញផងដែរពី វិស័យនានាដែលមានចន្លោះប្រហោងខាងរដ្ឋបាល ឬមានទំនាស់ នៅក្នុងរចនាសម្ព័ន្ធទើបបង្កើតថ្មីនេះ ។ ដូចបានលើកពីខាងដើមរួចហើយ ច្បាប់និងបទប្បញ្ញត្តិមានស្រាប់នានា ត្រូវបានអនុម័តចេញក្នុងរយៈពេលមួយដ៏ខ្លី ដូច្នេះប្រព័ន្ធនេះមិនអាចរំពឹងថា បានល្អឥតខ្ចោះនោះទេ ។

## *៦.១ កំរិតជាតិ*

រដ្ឋបាលនៅថ្នាក់ជាតិទាំងមូល រួមទាំង នាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី បណ្តាក្រសួងនិងអង្គភាពរដ្ឋ (ដូចជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាៈ CDC), មានជាប់ទាក់ទងនៅក្នុងកម្មវិធីវិមជ្ឈការក្នុងកំរិតខុសៗគ្នា ។ ផ្នែកនេះផ្តោតទៅលើតែអង្គភាពណាដែលមានជាប់ពាក់ព័ន្ធផ្ទាល់ក្នុងការអនុវត្តន៍កម្មវិធី ឬដែលត្រូវបានបង្កើតឡើងជាពិសេសសំរាប់គោលដៅនេះ ។

### *៦.១.១ គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC)*

គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងដោយរាជក្រឹត្យ ស្របតាមគោលការណ៍អនុញ្ញាតនៅក្នុងច្បាប់ឃុំ/សង្កាត់ ។ NCSC គឺជាគណៈកម្មាធិការពហុក្រសួង មានលក្ខណៈបណ្តោះអាសន្ន[២២] ដែលទទួលខុសត្រូវ កសាងច្បាប់និងគោលនយោបាយ, ឃ្លាំមើល សំរបសំរួល ផ្តល់ការណែនាំ ជួយទ្រទ្រង់ និងពង្រឹងការអនុវត្តន៍ច្បាប់និងគោលនយោបាយនានា[២៣] ដែលជាប់ទាក់ទងនឹងក្រុមប្រឹក្សាឃុំ និងវិមជ្ឈការ ។ លើសពីនេះ NCSC ទទួលខុសត្រូវបញ្ជាក់ថា តើច្បាប់និងបទប្បញ្ញត្តិនានាស្របគ្នាល្អឬទេ ជាមួយនឹងច្បាប់ឃុំ/សង្កាត់ និងគោលនយោបាយវិមជ្ឈការ ក្នុងនេះគឺមានទាំងការផ្តល់ច្បាប់អនុញ្ញាតជាមុនដល់ក្រសួង ឬស្ថាប័នរដ្ឋណាមួយ ដែលចង់ធ្វើប្រតិភូកម្មសិទ្ធិអំណាច ឬការទទួលខុសត្រូវ ទៅឱ្យក្រុមប្រឹក្សាឃុំ (ការផ្តល់មុខងារទីភ្នាក់ងារ)[២៤] ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[២៥] គឺជាប្រធាន NCSC, រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីគឺជាសហប្រធាន, ហើយក្នុង NCSC មានតំណាងថ្នាក់ក្រសួងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ក្រសួងផែនការ, ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។ មានខ្សែរយៈទាក់ទងតាមឋានានុក្រមផ្ទាល់រវាង NCSC និង DOLA ដែលដើរតួជាលេខាធិការដ្ឋានឱ្យ NCSC ។ ម្យ៉ាងទៀត មានចំណងប្រស្រ័យទាក់ទង និងសំរបសំរួលតាមខ្សែផ្តេករវាង NCSC និងក្រសួងផ្សេងៗទៀត ។

នៅក្នុង NCSC មាន ៥អនុគណៈកម្មការពហុក្រសួងដែលធ្វើការសិក្សា វាយតំលៃ និងធ្វើរបាយការណ៍អំពីកិច្ចការ និងការទទួលខុសត្រូវរបស់ខ្លួន ជូនដល់ NCSC ។ ការសំរបសំរួល និងការគាំទ្រដល់អនុកម្មការត្រូវបានផ្តល់ឱ្យដោយ DOLA ដែលបំពេញមុខងារធ្វើជាលេខាធិការដ្ឋានឱ្យ NCSC ។ អនុគណៈកម្មការដែលបានបង្កើតឡើងទាំង ៥ មានដូចខាងក្រោមៈ

- អនុគណៈកម្មការផែនការ និងអភិឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឃុំ/សង្កាត់
- អនុគណៈកម្មការកិច្ចការហិរញ្ញវត្ថុឃុំ/សង្កាត់
- អនុគណៈកម្មការនគររូបនីយកម្ម និងព្រំប្រទល់ឃុំ/សង្កាត់

---

[២២] អាណត្តិ NCSC ត្រូវចប់ ៩ខែ មុនការបោះឆ្នោតក្រុមប្រឹក្សាឃុំលើកក្រោយនៅឆ្នាំ២០០៦ ។

[២៣] ដើម្បីធានាឱ្យមានការអនុវត្តន៍ និងការប្រតិបត្តិតាមយ៉ាងត្រឹមត្រូវនូវបទប្បញ្ញត្តិនានាដែលជាប់ទាក់ទិន ។

[២៤] មុខងារពិនិត្យឯកសារច្បាប់ឡើងវិញរបស់ NCSC មិនទាន់បានអនុវត្តនៅឡើយទេមកទល់សព្វថ្ងៃ ។ NCSC ទទួលបន្ទុកដ៏ធ្ងន់ក្នុងដំណើរការដាក់អនុវត្តច្បាប់និងបទប្បញ្ញត្តិជាច្រើនដែលជាប់ទាក់ទិននឹងក្រុមប្រឹក្សាឃុំ និងវិមជ្ឈការ, ហើយក៏ពុំមានពេលសំរាប់ដោះស្រាយភារកិច្ចបន្ថែមនេះទេ ។ បញ្ហានេះត្រូវតែដោះស្រាយ ពីព្រោះកន្លងមកឯកសារច្បាប់ដែលផ្តល់មុខងារទីភ្នាក់ងារទៅឱ្យឃុំ ដូចជាអនុក្រឹត្យសម្បទានដីសង្គមកិច្ចជាដើម ត្រូវបានអនុម័តដោយគ្មានការពិនិត្យឡើងវិញដ៏ត្រឹមត្រូវពី NCSC ទេ ។

[២៥] ក្នុងករណីមានសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីទាំងពីរនាក់គឺជាសហប្រធាននៃ NCSC ។

- អនុគណៈកម្មការរចនាសម្ព័ន្ធ និងមុខងារឃុំ/សង្កាត់
- អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព

គួរកត់សំគាល់ថា គេត្រូវតែធ្វើអ្វីមួយទាក់ទិននឹងបញ្ហាអាណត្តិមានកំរិតកំណត់របស់ NCSC នេះ នៅមុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំលើកក្រោយ ។ រចនាសម្ព័ន្ធអចិន្ត្រៃយ៍មួយ គួរតែបង្កើតឡើងដើម្បីទទួលយកភារកិច្ចសព្វថ្ងៃរបស់ NCSC, គឺថាគេគួរផ្ទេរភារកិច្ចទាំងនេះទៅឱ្យរចនាសម្ព័ន្ធដែលមានស្រាប់ដូចជា DOLA ជាដើម ឬក៏ពន្យារអាណត្តិរបស់ NCSC ។ ទោះយកជំរើសណាក៏ដោយ, LAMC ព្រមទាំង ច្បាប់និងបទប្បញ្ញត្តិជាប់ទាក់ទិននានាដែលត្រូវប៉ះពាល់ គឺត្រូវតែធ្វើវិសោធនកម្ម ។

### *៦.១.២ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DOLA)*

DOLA ត្រូវបានបង្កើតឡើងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ តាមការអនុញ្ញាតមានចែងនៅក្នុងច្បាប់ឃុំ/សង្កាត់ ។ DOLA ដើរតួនាទីជាជំនួយការសំរាប់ការងារវិមជ្ឈការ និងរដ្ឋបាលឃុំ ដល់អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងដើរតួនាទីជាលេខាធិការដ្ឋានឱ្យ NCSC ផងដែរ ។

DOLA បានទទួលតួនាទី និងភារកិច្ចមួយបញ្ជីយ៉ាងវែងដែលជាប់ទាក់ទិននឹងរដ្ឋបាលឃុំ/សង្កាត់នៅកំរិតជាតិ និងការដាក់អនុវត្តន៍ជាទូទៅនូវកម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាល ។ តួនាទី និងភារកិច្ចទាំងនេះមានជាអាទិ៍ (នៅមានច្រើនទៀត) ការធានាឱ្យមានការអនុវត្តន៍សេចក្តីសំរេចរបស់ NCSC, ការឃ្លាំមើល និងការវាយតំលៃពីការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងសកម្មភាពនានាដែលបានផ្ទេរមកឱ្យឃុំ, ការគាំទ្រនិងសំរបសំរួលសកម្មភាពអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាពសំរាប់ឃុំ, ការបង្កើតនិងគាំទ្រយន្តការដោះស្រាយទំនាស់ដែលជាប់ទាក់ទងនឹងឃុំ, ការថែរក្សានិងពង្រីកច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំជាប់ទាក់ទងនឹងវិមជ្ឈការ, ការសំរបសំរួលដើម្បីទប់ស្កាត់ការជ្រៀតជ្រែកទៅក្នុងកិច្ចការ ឬការគ្រប់គ្រងរបស់ឃុំ ។ល។

រចនាសម្ព័ន្ធជាទូទៅនៃ DOLA បែងចែកចេញជា ៦ការិយាល័យ ដែលមានតួនាទី និងភារកិច្ចជាក់លាក់ដូចខាងក្រោម:

- ការិយាល័យរដ្ឋបាល
- ការិយាល័យ តាមដាន ត្រួតពិនិត្យ និងគាំទ្រឃុំ/សង្កាត់
- ការិយាល័យអប់រំ និងកសាងសមត្ថភាព
- ការិយាល័យផែនការ ស្ថិតិ និងពត៌មាន
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យស្រាវជ្រាវបច្ចេកទេស

ទាក់ទិននឹងខ្សែរយៈទាក់ទងនៅក្នុងរចនាសម្ព័ន្ធមានឋានានុក្រមនៃរដ្ឋអំណាច, DOLA ដើរតួជាច្រកទំនាក់ទំនងចំបងរវាងក្រសួងមហាផ្ទៃ/NCSC ហើយនិងអាជ្ញាធរកំរិតខេត្ត[២៦] (ដែលក្រោយមក មានចុះរហូតដល់កំរិតស្រុក ឃុំ និងភូមិ), រវាងក្រសួងមហាផ្ទៃ/NCSC ហើយនិងក្រសួង/ស្ថាប័នរដ្ឋផ្សេងៗទៀត លើបញ្ហានានាជាប់ទាក់ទិននឹងឃុំ និងវិមជ្ឈការ, និងរវាងក្រសួងមហាផ្ទៃ/NCSC ហើយនិងអង្គការអន្តរជាតិ សង្គមស៊ីវិល (NGOs) និងវិស័យឯកជន ។

[២៦] ក្រសួងមហាផ្ទៃបានបង្កើត អង្គភាពរដ្ឋបាលមូលដ្ឋាននៅតាមខេត្ត (POLA) ។ អង្គភាពទាំងនេះដែលតាមពិតគ្រាន់តែជាកន្លែងទំនាក់ទំនងរបស់ DOLA នៅកំរិតខេត្ត, សព្វថ្ងៃមានបុគ្គលិកមិនគ្រប់គ្រាន់ទេ ប៉ុន្តែបានទទួលកំលាំងបន្ថែមពីបុគ្គលិកមកពី ផ្នែករដ្ឋបាលមូលដ្ឋាន (LAU) ។ DOLA ត្រូវបានអនុញ្ញាតតាមប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ ។ តួនាទី និងភារកិច្ចរបស់ ផ្នែករដ្ឋបាលមូលដ្ឋាន (LAU) មានបញ្ជាក់បំភ្លឺនៅក្នុង ប្រកាសស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុង ។

*៦.១.៣ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (STF)*

STF គឺជាអង្គភាពរដ្ឋាភិបាលនៅកំរិតជាតិ ដែលត្រូវបានបង្កើតឡើងតាម អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីផ្តល់ការទ្រទ្រង់ខាងរចនាសម្ព័ន្ធដល់កម្មវិធីសិលារបស់រដ្ឋាភិបាល ។ គោលដៅចំបងនៃកម្មវិធីសិលា គឺការរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈអភិបាលកិច្ចល្អ, ការបង្កើតយុទ្ធសាស្ត្រនិងប្រព័ន្ធវិមជ្ឈការ សំរាប់គ្រប់គ្រងការអភិវឌ្ឍន៍មូលដ្ឋានឱ្យមានចីរភាព និងដើរតួជាក្របខ័ណ្ឌសំរាប់កេណ្ឌប្រមូលនិងសំរបសំរួលជំនួយដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តធ្វើវិមជ្ឈការរបស់រដ្ឋាភិបាល ។

អនុក្រឹត្យ STF កំណត់ពីភារកិច្ចចំបងរបស់ STFក្នុងនេះមាន ការអនុវត្តន៍កម្មវិធីសិលាជាទូទៅ, ការសំរបសំរួលកិច្ចពិភាក្សា និងការកសាងគោលនយោបាយជាប់ទាក់ទិននឹងវិមជ្ឈការរបស់រដ្ឋាភិបាល, ការឃ្លាំមើល និងវាយតំលៃ ពីភាពសក្តិសិទ្ធនៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ, និងការកសាងសមត្ថភាពនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល ។ ភារកិច្ចទាំងនេះ មានតាំងពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន ដោយវាជាប់ទាក់ទងនឹងការអនុវត្តន៍កំណែទំរង់វិមជ្ឈការ ។ នៅកំរិតជាតិ STF មានទំនាក់ទំនងតាមខ្សែផ្តេកជាមួយ NCSC, DOLA, និងក្រសួងជាប់ទាក់ទិនផ្សេងៗទៀត ។ តាមខ្សែបញ្ឈរ STF មានទំនាក់ទំនងជាមួយគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុង (PRDC) ។

ដូច NCSC ដែរ, STF គឺជារចនាសម្ព័ន្ធពហុក្រសួង ដែលមានសមាជិកដូចខាងក្រោម:

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥. អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦. អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៧. អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ | សមាជិក |
| ៨. អគ្គលេខាធិការ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ៩. អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | សមាជិក |
| ១០. អគ្គលេខាធិការរងនៃ CDC, អគ្គលេខាធិការ CRDB | អគ្គលេខាធិការ |

STF មានលេខាធិការដ្ឋានមួយ មានទីតាំងក្នុងបរិវេណ CDC ដែលរួមមានពីរអង្គភាពគឺ អង្គភាពប្រតិបត្តិការកម្មវិធី និង អង្គភាពឃ្លាំមើលនិងវាយតំលៃខាងគោលនយោបាយ ។ អង្គភាពទាំងពីរដំណើរការក្នុងកំរិតស្មើគ្នានឹងនាយកដ្ឋានក្នុងក្រសួងជំនាញ និងទទួលខុសត្រូវជាសំខាន់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ និងការអនុវត្តន៍កម្មវិធីសិលា ។

គេគួរកត់សំគាល់ថា STF ក៏ដូច NCSC ដែរ គឺមានលទ្ធភាព តាក់តែងអនុក្រឹត្យសំរាប់ដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី និងចេញប្រកាសដោយផ្ទាល់ ។ រឿងនេះអាចមើលឃើញយ៉ាងច្បាស់ តាមការណ៍ដែល STF បានតាក់តែង និងអនុម័តចេញនូវ "ប្រកាសស្តីពីការរៀបចំរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត/ក្រុង នៃកម្មវិធីសិលា" (ប្រកាស PRDC) ។

### ៦.២ កំរិតខេត្ត ស្រុក និងឃុំ

### ៦.២.១ ប្រវត្តិរចនាសម្ព័ន្ធ

វាជាការសំខាន់ដែលត្រូវយល់ដឹងថា រចនាសម្ព័ន្ធរដ្ឋបាលបច្ចុប្បន្ននៅកំរិតខេត្ត និងស្រុក គឺកំពុងស្ថិតក្នុងដំណើរការដាក់អនុវត្ត ។ ច្បាប់មានស្រាប់ដែលកំណត់ពីតួនាទីដ៏ចំបង១របស់អាជ្ញាធរកំរិតខេត្ត គឺ "ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធអង្គការចាត់តាំងរបស់អាជ្ញាធរខេត្ត/ក្រុង" ដែលបានអនុម័តនៅឆ្នាំ១៩៩៤ គឺយូរឆ្នាំមុនពេលរដ្ឋាភិបាលបានអនុម័តយកគោលគំនិតនៃវិមជ្ឈការ ។ ភស្តុតាងមួយដែលបង្ហាញថា តើប្រកាសមានស្រាប់នេះវាឃ្លាតចាកពីកម្មវិធីវិមជ្ឈការបច្ចុប្បន្នប៉ុណ្ណា គឺប្រកាសបានកំណត់ពី "ការិយាល័យមជ្ឈការ" មួយនៅក្នុងក្របខ័ណ្ឌដែលវាបានចែងឡើង ។

ដំណោះស្រាយប្រសើរបំផុតចំពោះបញ្ហានេះ គឺការអនុមតិច្បាប់រៀបចំអង្គការស្តីពីអាជ្ញាធរថ្នាក់ខេត្ត និងស្រុក ដែលនឹងលុបចោលវិញនូវប្រកាសខាងលើ[២៧] ។ ក្រុមការងារមួយត្រូវបានបង្កើតឡើងក្នុងក្រសួងមហាផ្ទៃ ដើម្បីតាក់តែងច្បាប់នេះ ហើយគេសង្ឃឹមថានឹងអាចចេញសេចក្តីព្រាងច្បាប់មួយនៅឆ្នាំខាងមុខ ។ ច្បាប់នេះនឹងកំណត់ជាប់រហូតនូវរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច នៅកំរិតខេត្ត និងស្រុក ដែលនឹងជួយទ្រទ្រង់ដល់ និងចងភ្ជាប់ជាមួយក្របខ័ណ្ឌវិមជ្ឈការបច្ចុប្បន្ន ។

រដ្ឋាភិបាលបានទទួលស្គាល់ថា ការដាក់ដំណើរការរចនាសម្ព័ន្ធអចិន្ត្រៃយ៍នេះមុនការបង្កើតក្រុមប្រឹក្សាឃុំថ្មី មិនមែនជាយុទ្ធសាស្ត្រល្អទេ ពីព្រោះគេត្រូវការពេលដើម្បីសាកល្បងរចនាសម្ព័ន្ធបណ្តោះអាសន្ននានា និងស្រាវជ្រាវរកមើលប្រព័ន្ធណាដែលដំណើរការបានជាក់ស្តែងក្នុងការជួយទ្រទ្រង់ប្រព័ន្ធវិមជ្ឈការ ។ ការបង្កើតរចនាសម្ព័ន្ធសាកល្បងបណ្តោះអាសន្នទាំងនេះកន្លងមកត្រូវបានដោះស្រាយតាមរយៈការអនុមតិ "ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត/ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ " (ប្រកាសអភិបាលខេត្ត អនុម័តដោយក្រសួងមហាផ្ទៃ) និងប្រកាស PRDC[២៨] ។

មានការភ័ន្តច្រឡំជាច្រើនទាក់ទិននឹងប្រកាស PRDC ដោយអ្នកខ្លះបានបកស្រាយខុសពីរចនាសម្ព័ន្ធនានាដែលប្រកាសនេះបានបង្កើតឡើង ដោយលើកថា គឺជារចនាសម្ព័ន្ធដែលត្រូវមានទទឹមគ្នាជាមួយនឹងរចនាសម្ព័ន្ធឯទៀតក្នុងរដ្ឋបាលនៅកំរិតខេត្ត និងស្រុក ។ ប៉ុន្តែតាមពិតសព្វថ្ងៃគ្មានរចនាសម្ព័ន្ធណាផ្សេងសំរាប់ដើរទទឹមគ្នាទេ ហើយនេះជាមូលហេតុដែលគេត្រូវបង្កើតវាឡើង ។ រចនាសម្ព័ន្ធទាំងនេះដើរតួជា "ការជួសជុល" បណ្តោះអាសន្នដែលដាក់អនុវត្តក្នុងទូទាំងប្រទេស ហើយមេរៀននានាដែលទទួលបានពីរឿងនេះ នឹងដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងគោលនយោបាយជាតិស្តីពីវិមជ្ឈការ និងការព្រាងច្បាប់រៀបចំអង្គការ ។ ក្រោយការអនុមតិច្បាប់រៀបចំអង្គការ ពួកអ្នកបំរើការនៅក្នុងរចនាសម្ព័ន្ធ PRDC ប្រហែលនឹងបញ្ចូលទៅក្នុងរចនាសម្ព័ន្ធបង្កើតថ្មីនានា ហើយរចនាសម្ព័ន្ធចាស់នឹងលែងមានទៀតហើយ ។ ក្នុងពេលនោះដែរ PRDC និងរចនាសម្ព័ន្ធនានាដែលបានបង្កើតឡើងក្នុងនោះ គួរចាត់ទុកចំណែកមួយដ៏ពេញលេញនៃរចនាសម្ព័ន្ធរដ្ឋអំណាចនៅកំរិតខេត្ត និងស្រុក ។

### ៦.២.២ សាលាខេត្ត

ប្រកាសអភិបាលខេត្ត បានធ្វើប្រតិភូកម្មមុខងារ ឃ្លាំមើល វាយតំលៃ កសាងសមត្ថភាព និងជួយគាំទ្ររបស់ NCSC ក្រសួងមហាផ្ទៃ និង DOLA ទៅឱ្យអាជ្ញាធរកំរិតខេត្ត ។ មានការភ័ន្តច្រឡំខ្លះ១ដោយសារពាក្យពេចន៍ដែលចែងពីការធ្វើប្រតិភូកម្ម បានដៅចំទៅលើអភិបាលខេត្តតែម្នាក់ ។ ការធ្វើប្រតិភូកម្មនេះ (ដែលទូលំទូលាយ និងមានភារកិច្ច/មុខងារច្រើន) មិនអាចដោះស្រាយដោយមនុស្សតែម្នាក់បានទេ ដូច្នេះគេគួរបកស្រាយថា មានការធ្វើប្រតិភូកម្មទៅឱ្យបុគ្គលិក និងមន្ទីរផ្សេង១

---

[២៧] រដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា អាជ្ញាធរកំរិតខេត្ត និង ស្រុក ត្រូវបានគ្រប់គ្រងស្របទៅតាមច្បាប់រៀបចំអង្គការ ។

[២៨] គេគួរកត់សំគាល់ថា ប្រកាស PRDC ត្រូវតាក់តែងឡើងវិញជាច្រើនលើក (ដើម្បីជំនួសប្រកាសពីមុន) ដោយផ្អែកលើមេរៀនដែលបានរៀនសូត្រនៅក្នុងដំណើរការសាកល្បងដែលកំពុងបន្តទៅមុខ ហើយប្រកាសចុងក្រោយត្រូវបានអនុម័តនៅខែវិច្ឆិកា ២០០២ ។ *ប្រកាស* នេះ ព្រមទាំងប្រកាសអភិបាលខេត្ត នឹងត្រូវជំនួសដោយច្បាប់រៀបចំអង្គការស្តីពីអាជ្ញាធរខេត្ត និងស្រុក ។

នៅកំរិតខេត្តដែរ ដោយអភិបាលខេត្តដើរតួជាជនបង្គោល ។ រឿងនេះអាចមើលឃើញយ៉ាងច្បាស់តាមការដែលប្រកាសអភិបាលខេត្ត បានបង្កើតឱ្យមានអង្គភាពរដ្ឋបាលមូលដ្ឋានចំណុះសាលាខេត្តដែលគេច្រើនហៅជាទូទៅថា POLA[២៩] ។ អង្គភាពនេះស្ថិតនៅក្នុងសាលាខេត្ត និងដើរតួជាលេខាធិការដ្ឋានរបស់អភិបាលខេត្តសំរាប់ការអនុវត្តន៍គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល ។ ការផ្ទេរភារកិច្ចនានា ក៏បានអនុវត្តចុះទៅដល់អង្គភាពគ្រប់គ្រងផ្សេងៗដែលបង្កើតឡើងតាមប្រកាស PRDC[៣០] ។

តួនាទីសំខាន់គួរលើកឡើងមួយទៀតរបស់សាលាខេត្តគឺ រតនាគារខេត្តដោះស្រាយរាល់ចំណូលមូលនិធិឃុំ មកពីកំរិតជាតិ និងការបើកផ្តល់ទៅឱ្យឃុំ ។ រតនាគារខេត្តដែលជាផ្នែកបច្ចេកទេសមួយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ដើរតួជាគណនេយ្យករ និងជាធនាគាររបស់ក្រុមប្រឹក្សាឃុំ ។ វិធានជាមូលដ្ឋានសំរាប់ ការផ្ញើទុកមូលនិធិឃុំនៅរតនាគារខេត្ត និងការកំនត់ពីតួនាទីនិងភារកិច្ចរបស់រតនាគារខេត្ត មានចែងក្នុងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ/សង្កាត់ (អនុក្រឹត្យមូលនិធិឃុំ) និងប្រកាស PRDC, រីឯតួនាទី ភារកិច្ច និងមុខងារបន្ថែមរបស់រតនាគារខេត្ត មានចែងនៅក្នុងអនុក្រឹត្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ ដែលបានបង្ហាញជូនពីខាងដើម ។ នៅក្នុងអនុក្រឹត្យមូលនិធិឃុំ មានចែងពីការផ្តល់សិទ្ធិឱ្យក្រុមប្រឹក្សាឃុំបើកគណនីនៅក្នុងធនាគារពាណិជ្ជ ដើម្បីផ្ញើទុកមូលនិធិឃុំ ប៉ុន្តែជំរើសនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនទាន់អនុញ្ញាតឱ្យប្រើទេ។ បច្ចុប្បន្នរតនាគារខេត្តគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុ សឹងតែទាំងអស់របស់ឃុំ រួមទាំង ការប្រមូល និងការបញ្ជាក់ថាបានទទួលនូវចំណូលរបស់ឃុំ (ក្រោយមានការផ្ទេរពីឃុំ ទៅរតនាគារខេត្ត), ការទូទាត់បញ្ជាចំណាយចេញដោយមេឃុំ, ការគ្រប់គ្រង និងបញ្ចេញមូលនិធិ, ការកត់ត្រាប្រតិបត្តិការទៅតាមបែបបទរបស់រដ្ឋ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំ ខែ ឆមាស និង ឆ្នាំ ដែលត្រូវផ្ទៀងផ្ទាត់ (ជាក់ស្តែងដោយស្មៀនឃុំ) និងអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ (ចុះហត្ថលេខាដោយមេឃុំ), និងការថែទាំប្រព័ន្ធទុកដាក់ឯកសារ និងកំណត់ត្រាហិរញ្ញវត្ថុទាំងអស់របស់ឃុំ ។ ដោយសាររតនាគារខេត្តមានចូលពាក់ព័ន្ធយ៉ាងច្រើននៅក្នុងកិច្ចការហិរញ្ញវត្ថុឃុំ ដូច្នេះវិមជ្ឈការនៃការគ្រប់គ្រងហិរញ្ញវត្ថុ អាចចាត់ទុកថានៅខ្សោយបន្តិចក្នុងពេលសព្វថ្ងៃ[៣១] ។

បើគិតពីខ្សែរយៈទំនាក់ទំនង និងឋានានុក្រម អភិបាលខេត្តគឺជាខ្សែទំនាក់ទំនងផ្លូវការរវាង DOLA, MoI, NCSC, នៅកំរិតជាតិ ហើយនិងអាជ្ញាធរថ្នាក់ក្រោមនៅកំរិត ស្រុក ឃុំ និងភូមិ ។ គេគួរកត់សំគាល់ដែរថា តាមគោលការណ៍ទំនាក់ទំនងពីថ្នាក់ក្រោមៗត្រូវធ្វើតាមរយៈ POLA[៣២] ។ នៅមានការភ័ន្តច្រឡំមួយចំនួនទៀតពីរឿងថា តើសាលាខេត្ត ធ្វើទំនាក់ទំនងយ៉ាងដូចម្តេច ទៅ STF នៅកំរិតជាតិ ។ ដោយសារអភិបាលខេត្ត គឺជាប្រធានទាំង PRDC និង គណៈកម្មការប្រតិបត្តិ នៃ PRDC ដូច្នេះអភិបាលខេត្តធ្វើទំនាក់ទំនងទៅ STF ដោយផ្ទាល់តាមរយៈរចនាសម្ព័ន្ធទាំងនេះ ។

---

[២៩] ប្រកាសអភិបាលខេត្តចែងថា ការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គភាពរដ្ឋបាលមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ។ កិច្ចការនេះធ្វើឡើងតាមរយៈ ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៏ឃុំ/សង្កាត់ ដែលបានប្រើពាក្យ "អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង" និងដែលបង្កការភ័ន្តច្រឡំមួយចំនួនដោយសារ *ប្រកាស* PRDC បានបង្កើតអង្គភាពមួយហៅថា "ផ្នែករដ្ឋបាលមូលដ្ឋាន (LAU)" ដែលត្រូវដំណើរការក្រោមការគ្រប់គ្រងរបស់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង (POLA)(សូមអានផ្នែក ៦.២.៤) ។ តាមធម្មតាគេច្រើនប្រើពាក្យ POLA ហើយនេះជាពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារនេះ ។ ការច្រឡំគ្នានេះ នឹងត្រូវបំភ្លឺយ៉ាងច្បាស់តាមការអនុមតិច្បាប់រៀបចំអង្គការ ដូចបានលើករួចហើយ ។

[៣០] សូមអានផ្នែក ៦.២.៣ ។

[៣១] មិនមែនបានន័យថា កំរិតវិមជ្ឈការហិរញ្ញវត្ថុសព្វថ្ងៃមិនត្រឹមត្រូវនោះទេ ។ ចំណុចសំខាន់ក្នុងរឿងនេះគឺ ក្រុមប្រឹក្សាឃុំបច្ចុប្បន្នមិនទាន់មានសមត្ថភាពចាត់ចែងកិច្ចការហិរញ្ញវត្ថុដ៏ស្មុគស្មាញទាំងនេះបានទេ ។

[៣២] ប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៏ឃុំ ចែងថា POLA ត្រូវផ្តល់នូវច្រកទំនាក់ទំនងតែមួយទៅឱ្យក្រុមប្រឹក្សាឃុំ ដើម្បីធ្វើទំនាក់ទំនងជាមួយរដ្ឋបាលខេត្ត ។

### ៦.២.៣ គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត

ដូចបានបង្ហាញពីខាងដើម ប្រកាស PRDC បានបង្កើតគណៈកម្មការនេះឡើង ។ តួនាទី និងមុខងារចំបងៗរបស់ PRDC គឺជាប់ទាក់ទងនឹងសកម្មភាពធ្វើផែនការនិងជួយទ្រទ្រង់របស់ខេត្ត ដែលឧបត្ថម្ភគាំទ្រដោយកម្មវិធីសិលា. ប៉ុន្តែរចនាសម្ព័ន្ធនានាដែលត្រូវបានបង្កើតឡើងនៅខាងក្រោម PRDC គឺផ្តល់ការទ្រទ្រង់ដោយផ្ទាល់ដល់ក្រុមប្រឹក្សាឃុំតាមរយៈអាជ្ញាធរក៏រិតខេត្ត និង ស្រុក ។ PRDC ក៏បំពេញតួនាទីធ្វើសហការ និងសំរបសំរួលដ៏សំខាន់រវាងក្រសួងជំនាញ/ស្ថាប័នរដ្ឋ, វិស័យឯកជន, សង្គមស៊ីវិល, និងទីភ្នាក់ផ្តល់ជំនួយជាតិ/អន្តរជាតិ, ដោយសារវាជាប់ទាក់ទងនឹងការធ្វើផែនការ និងការគ្រប់គ្រងការអភិវឌ្ឍន៍នៅក៏រិតខេត្ត ។

សមាសភាព PRDC គឺមាន អភិបាលខេត្ត, អភិបាលខេត្តរង, ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ និងផែនការ, ប្រធានមន្ទីរជំនាញផ្សេងៗ និងអភិបាលស្រុក ។

ការអនុវត្តន៏ផែនការការងារ និងថវិកាប្រចាំឆ្នាំរបស់ PRDC ឬក៏អ្វីដែលអាចចាត់ទុកជាការងារប្រចាំថ្ងៃរបស់ PRDC ត្រូវបានធ្វើឡើងដោយគណៈកម្មការប្រតិបត្តិ (ExCom) ។ សមាសភាព ExCom ត្រូវមានយ៉ាងហោចណាស់ អភិបាលខេត្ត អភិបាលខេត្តរង ប្រធាន១នៃមន្ទីរអភិវឌ្ឍន៏ជនបទ ផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ធនធានទឹកនិងឧតុនិយម, កិច្ចការនារីនិងអតីតយុទ្ធជន, រតនាគារខេត្ត, និងប្រធាននៃផ្នែករដ្ឋបាលមូលដ្ឋាន (LAU)[៣៣] ។ អភិបាលខេត្ត គឺជាប្រធាន ExCom ហើយអាចតែងតាំងសមាជិកណាម្នាក់ជាសមាជិកអចិន្ត្រៃយ៍ ព្រមទាំងអាចតែងតាំងប្រធានមន្ទីរជំនាញផ្សេងៗទៀតជាសមាជិកបន្ថែម ទៅតាមតំរូវការការងារ ។

ដើម្បីជួយ ExCom បំពេញភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តន៏ផែនការការងារ និងថវិកាប្រចាំឆ្នាំ, ប្រកាស PRDC បានបង្កើតផ្នែកគ្រប់គ្រងចំនួន ៤ ដែលរាយការណ៏ផ្ទាល់ទៅ ExCom គឺមានផ្នែកគ្រប់គ្រងកិច្ចសន្យា (CAU), ផ្នែករដ្ឋបាលមូលដ្ឋាន (LAU), ផ្នែកគាំទ្របច្ចេកទេស (TSU) និង ផ្នែកហិរញ្ញវត្ថុ (FU) ។ វត្តមាននៃផ្នែកគ្រប់គ្រងទាំងនេះ បង្កភាពស្មុគស្មាញដល់ខ្សែរយៈទាក់ទងរវាងក្រុមប្រឹក្សាឃុំ និងអភិបាលខេត្ត ព្រមទាំងអាចធ្វើឱ្យមានទំនាស់ផ្នែកច្បាប់ទៀតផង[៣៤] ។ ផ្ទុយពី POLA ដែលត្រូវដើរតួនាទីជាកន្លែងទំនាក់ទំនងកណ្តាល និងជាខ្សែរយៈទាក់ទងដោយផ្ទាល់រវាងក្រុមប្រឹក្សាឃុំ និងអភិបាលខេត្ត វត្តមាននៃផ្នែកទាំងនេះ បង្កើតនូវខ្សែរយៈទាក់ទងពីក្រុមប្រឹក្សាឃុំ ទៅផ្នែកគ្រប់គ្រងនានាដែលក្រោយមករាយការណ៏ទៅ ExCom ដោយបានរំលងចោល POLA ទាំងស្រុង ។ ស្ថានភាពនេះមានច្រើនជាពិសេសជាមួយ TSU ដោយសារការជាប់ទាក់ទិនរបស់វាផ្ទាល់នៅក្នុងការចុះកិច្ចសន្យាខាងសេវាកម្មដែលជាប់ទាក់ទងនឹងគំរោងហេដ្ឋារចនាសម្ព័ន្ធ/សំណង់នានា ។ រឿងនេះប្រហែលមិនធ្ងន់ធ្ងរទេ ដោយសារអភិបាលខេត្ត គឺជាប្រធាន ExCom ហើយបញ្ហានានាដែលជាប់ទាក់ទិននឹងខ្សែរយៈទាក់ទង និងអប្រសិទ្ធភាពនៅក្នុងប្រព័ន្ធ គឺអាចយកមកគិតគូរដោះស្រាយនៅក្នុងការកសាង ច្បាប់រៀបចំអង្គការ ។

#### ៦.២.៣.១ ផ្នែកគ្រប់គ្រងកិច្ចសន្យា(CAU)

CAU ត្រូវដំណើរការក្រោមការគ្រប់គ្រងរបស់មន្ទីរផែនការខេត្ត ហើយទទួលបន្ទុកបំពេញភារកិច្ចជាច្រើន ជាអាទិ៍ (នៅមានច្រើនទៀត) ជួយទ្រទ្រង់ដល់ការកសាងផែនការការងារ និងថវិកាប្រចាំឆ្នាំ, ឃ្លាំមើល និងវាយតំលៃលើផែនការការងារ និងថវិកា, ដោះស្រាយរាល់បញ្ហាជាប់ទាក់ទងនឹងការគ្រប់គ្រងកិច្ចសន្យានៅក៏រិតអាជ្ញាធរថ្នាក់ខេត្ត និងស្រុក (រួមទាំងសកម្មភាពចុះកិច្ចសន្យារបស់បណ្តាមន្ទីរជាបណ្តាញក្រសួងជំនាញ), គ្រប់គ្រងកិច្ចសន្យាបុគ្គលិករបស់ ExCom និងគ្រប់គ្រងរចនាសម្ព័ន្ធ និងសំភារៈ ។ បើនិយាយពីរបៀបដែល CAU ជាប់ទាក់ទងផ្ទាល់ជាមួយនឹងវិមជ្ឈការនៅក៏រិតឃុំ គឺវាធ្វើការសំរបសំរួលជាមួយនឹង LAU ដើម្បីធានាភាពរលូនគ្នាល្អរវាងប្រព័ន្ធឃ្លាំមើល និងវាយតំលៃ នៅក៏រិតឃុំ និងខេត្ត, និងសហការជាមួយ LAU ក្នុងការរៀប

[៣៣] ក្នុងតំបន់ជាច្រើននៅកម្ពុជា, ប្រធាន LAU គឺជាជនបង្គោលរបស់ POLA/DOLA នៅក៏រិតខេត្ត ។

[៣៤] សូមអាន កំណត់សំគាល់ទី២៨ នៅខាងលើ ។

ចំងកសារផ្សេងៗដែលអ្នកភូមិអាចមើលយល់ ដើម្បីលើកកំពស់ការយល់ដឹងពីគោលការណ៍វិមជ្ឈការ និងការជ្រួតជ្រាបនៅក្នុងមូលដ្ឋានអំពីសកម្មភាពផ្សេងៗដែលក្រុមប្រឹក្សាឃុំត្រូវអនុវត្ត និងអំពីផែនការអភិវឌ្ឍន៍ឃុំ ។

### *៦.២.៣.២ ផ្នែករដ្ឋបាលមូលដ្ឋាន (LAU)*

LAU ត្រូវដំណើរការក្រោមការគ្រប់គ្រងរបស់ POLA និងរួមមាន ក្រុមសំរបសំរួលខេត្ត/ក្រុង (PFT) និង ក្រុមសំរបសំរួលស្រុក/ខ័ណ្ឌ (DFT) ។ LAU គឺជារចនាសម្ព័ន្ធចំបងនៅក្រោម ExCom ដែលចូលពាក់ព័ន្ធផ្ទាល់ក្នុងការទ្រទ្រង់វិមជ្ឈការនៅកំរិតឃុំ ។ LAU មានមុខងារចំបងពីរ: ការកសាងសមត្ថភាពឱ្យដល់ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ, និង ការឃ្លាំមើល ការវាយតំលៃ និងការប្រមូលទិន្នន័យលើសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ ។ មុខងារកសាងសមត្ថភាពត្រូវបានអនុវត្តដោយមានជំនួយពី PFT និង DFT ហើយតួនាទីមានចែងច្បាស់មួយនៃ LAU គឺការបណ្តុះបណ្តាល PFTនិង DFT (ការបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល) រួមទាំងកិច្ចសហការជាមួយពួកមន្ទីរបណ្តាញក្រសួងជំនាញ និងអង្គភាពរដ្ឋឯទៀតដែលមានសមត្ថកិច្ចក្នុងវិស័យដ៏ជាក់លាក់[៣៥] ។

### *៦.២.៣.៣ ផ្នែកគាំទ្របច្ចេកទេស (TSU)*

TSU ត្រូវដំណើរការក្រោមការគ្រប់គ្រងរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងផ្តល់សេវាកម្មផ្នែកបច្ចេកទេសដល់រដ្ឋបាលកំរិតឃុំ និងខេត្ត លើបញ្ហាផ្សេងៗជាប់ទាក់ទងនឹងគំរោងហេដ្ឋារចនាសម្ព័ន្ធ/សំណង់ ដូចជា ការផ្តល់យោបល់ឱ្យក្រុមប្រឹក្សាឃុំអំពីបែបបទប្រកួតប្រជែងដេញថ្លៃ, បែបបទធ្វើកិច្ចសន្យា (procurement of contract), និងការឃ្លាំមើលការអនុវត្តន៍គំរោងហេដ្ឋារចនាសម្ព័ន្ធ/សំណង់ ។ TSU មានភារកិច្ចមួយទៀតគឺ ការប្រមូល/រក្សាទុកពតិមានលើកំរិតថ្លៃបច្ចុប្បន្ននៃទំនិញនិងសេវាដែលជាប់ទាក់ទងនឹងការសាងសង់ និងលើអ្នកម៉ៅការមានគុណភាពល្អស្រាប់ដែលមានសិទ្ធិដេញថ្លៃចុះកិច្ចសន្យា, ព្រមទាំងទិន្នន័យផ្សេងទៀតដែលជាប់ទាក់ទងនឹងគំរោងហេដ្ឋារចនាសម្ព័ន្ធ/សំណង់ ។

### *៦.២.៣.៤ ផ្នែកហិរញ្ញវត្ថុ (FU)*

FU ត្រូវដំណើរការក្រោមការគ្រប់គ្រងរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរតនាគារខេត្ត ។ FU មានភារកិច្ចផ្តល់ការគាំទ្រដល់រដ្ឋបាលកំរិតខេត្ត និងឃុំ រួមទាំង ExCom ខ្លួនឯងផ្ទាល់, លើគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានសមស្រប រួមទាំងសេវាកម្មនៃការឃ្លាំមើល និងវាយតំលៃផង ។

### ***៦.២.៤ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង (POLA)***

POLA គឺជាអង្គភាពរបស់ក្រសួងជំនាញ និងស្ថិតនៅក្រោម DOLA ផ្ទាល់ ។ ដូចបានលើករួចហើយ អង្គភាពនេះត្រូវបានបង្កើតឡើងស្របតាមការផ្តល់សិទ្ធិអំណាចនៅក្នុងប្រកាសអភិបាលខេត្ត និងប្រកាសផែនការអភិវឌ្ឍន៍ឃុំ ។ ប្រកាសផែនការអភិវឌ្ឍន៍ឃុំ ចែងថា POLA មានភារកិច្ចណែនាំទៅឃុំអំពីអ្វីដែលត្រូវអនុវត្តដើម្បីគោរពតាមដំណើរការធ្វើផែនការអភិវឌ្ឍន៍ ហើយ POLA ត្រូវផ្តល់នូវច្រកទំនាក់ទំនងតែមួយសំរាប់ការទាក់ទងទាំងអស់របស់ឃុំជាមួយរដ្ឋបាលខេត្ត ។

ភារកិច្ច POLAក្នុងការផ្តល់ច្រកទំនាក់ទំនងតែមួយគឺផ្អែកលើសេចក្តីចែងថា "មុនធ្វើលទ្ធកម្មការងារ ទំនិញ និងសេវាកម្មសំរាប់អនុវត្តគំរោងណាមួយ មេឃុំ/ចៅសង្កាត់ត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្ត តាមរយៈ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង" ។ ប៉ុន្តែដូចបានលើករួចហើយ រឿងនេះមិនបានអនុវត្តក្នុងការពិតជាក់ស្តែងទេ ។

---

[៣៥] ឧទាហរណ៍មួយក្នុងរឿងនេះគឺ LAU សហការជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្ត ផ្តល់ការបណ្តុះបណ្តាលដល់ PFT និង DFT អំពីនីតិវិធីនៃប្រព័ន្ធមូលនិធិឃុំ ។

ដូចបានបញ្ជាក់រួចហើយ, POLA នៅពេលនេះមិនមែនជាការិយាល័យមួយទេ ប៉ុន្តែជាកន្លែងទំនាក់ទំនងកណ្តាលដែលត្រូវបានតែងតាំងឡើងសំរាប់ DOLA នៅក៏រិតខេត្ត ។ គេអាចស្មានត្រូវថា ការប្រើពាក្យ "អង្គភាព" បានបង្កការភ័ន្តច្រឡំខ្លះៗ ។

តួនាទីជាក់ស្តែងរបស់ POLA ព្រមទាំងអន្តរកម្មជាមួយ និងការមើលខុសត្រូវទៅលើ LAU នៅមិនទាន់ច្បាស់ទេ ។ ការអនុវត្តន៍ប្រព័ន្ធនេះតាមរយៈខ្សែរយៈទំនាក់ទំនង មានលក្ខណៈខុសប្លែកគ្នាពីខេត្តមួយទៅខេត្តមួយ ប៉ុន្តែវាហាក់ដូចដំណើការបាន ។ កង្វះភាពច្បាស់លាស់អំពីអង្គភាពទាំងនេះ នឹងត្រូវដោះស្រាយតាមរយៈការតាក់តែងច្បាប់រៀបចំអង្គការ, ដូច្នេះនៅពេល បច្ចុប្បន្ន មិនចាំបាច់មានការកែតំរូវជាបណ្តោះអាសន្នសំរាប់មួយរយៈពេលខ្លី នៅក្នុងប្រព័ន្ធច្បាប់សព្វថ្ងៃទេ ។

### ៦.២.៥ រដ្ឋបាលក៏រិតស្រុក

តួនាទី និងមុខងាររបស់រដ្ឋបាលក៏រិតស្រុក រួមទាំង តួនាទី និងមុខងាររបស់អភិបាលស្រុក គឺកំណត់មិនបានច្បាស់ល្អទេ ដូចបានពន្យល់រួចហើយក្នុងផ្នែកទី២[៣៦] ។ ក្រសួងជំនាញផ្សេងៗមានការិយាល័យក៏រិតស្រុក ដោយអភិបាលស្រុកមានតួនាទីជាអ្នកសំរបសំរួល ។ អភិបាលស្រុក និងការិយាល័យជាបណ្តាញក្រសួងជំនាញក៏រិតស្រុក ធ្វើប្រតិបត្តិការដោយផ្អែកលើការបញ្ជាដោយផ្ទាល់ពីថ្នាក់ខេត្ត ដោយមានសិទ្ធិអំណាចស្វយ័តដ៏តិចតួច ។

ជាប្រពៃណី អភិបាលស្រុកធ្វើការត្រួតពិនិត្យមួយចំនួនទៅលើក្រុមប្រឹក្សាឃុំ ដោយមានអភិបាលស្រុកធ្វើជាអធិបតីក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ បើតាមសេចក្តីថែងក្នុងច្បាប់ ។ ប៉ុន្តែ វាមិនច្បាស់លាស់សោះថា តើអភិបាលស្រុកនៅបន្តមានឥទ្ធិពលប៉ុណ្ណា ។ បច្ចុប្បន្ន ជាបន្ថែមលើតួនាទីជាអ្នកសំរបសំរួលរបស់ខ្លួន អភិបាលស្រុកប្រហែលដើរតួនាទីសំខាន់ធ្វើជាច្រកបញ្ជូនពត៌មានពីថ្នាក់ឃុំ ទៅថ្នាក់ខេត្ត ដោយអភិបាលស្រុកជាច្រើនតែងកោះហៅមេឃុំទាំងអស់មកចូលរួមប្រជុំប្រចាំសប្តាហ៍ ។

តួនាទី និងមុខងារនៃរដ្ឋបាលក៏រិតស្រុក គួរបញ្ជាក់ឱ្យច្បាស់លាស់នៅពេលអនុម័តច្បាប់រៀបចំអង្គការ ។

### ៦.២.៦ រដ្ឋបាលក៏រិតឃុំ

ក្រុមប្រឹក្សាឃុំដែលទើបជាប់ឆ្នោតថ្មី និងរចនាសម្ព័ន្ធផ្សេងៗនៅក្នុងឃុំ គឺប្រព័ន្ធបច្ចុប្បន្ននៅក៏រិតឃុំ ។ នៅពេលនេះ រចនាសម្ព័ន្ធមានលក្ខណៈត្រង់ៗងាយយល់ និងមិនស្មុគស្មាញ ប៉ុន្តែវានឹងរីកលូតលាស់ទៅតាមពេលវេលា ដោយសារការបង្កើតគណៈកម្មាធិការជំនួយការផ្សេងៗដោយមេឃុំ[៣៧] ការធ្វើប្រតិភូកម្មមុខងារភ្នាក់ងារពីក្រសួងជំនាញនានាទៅឱ្យក្រុមប្រឹក្សាឃុំ និង ការជួលបុគ្គលិកបន្ថែមដើម្បីអនុវត្តភារកិច្ចបន្ថែមផ្សេងៗ ។

បច្ចុប្បន្នក្រុមប្រឹក្សាឃុំមានសមាជិកពី ៥ ទៅ ១១នាក់ ផ្អែកទៅតាមភូមិសាស្ត្រ និងប្រជាសាស្ត្ររបស់ឃុំ ។ ប្រធានក្រុមប្រឹក្សាឃុំ គឺជាមេឃុំដែលចាត់ចែងការងារប្រចាំថ្ងៃជាច្រើនដូចជា ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ, ការតែងតាំងគណៈកម្មការជំនួយការផ្សេងៗ, រាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីបញ្ហាផ្សេងៗ, និងគ្រប់គ្រងស្មៀនឃុំ ។ ក្រុមប្រឹក្សាឃុំអាចធ្វើប្រតិភូកម្មភារកិច្ចជាក់លាក់មួយចំនួនទៅឱ្យមេឃុំ លើកលែងតែការងារដូចតទៅ: ការអនុម័តគំរោងថវិកាឃុំ, ការកំណត់អត្រាសំរាប់ការប្រមូលចំណូលពន្ធនៅមូលដ្ឋាន ចំណូលមិនមែនពន្ធ និងប្រាក់កំរៃសេវាផ្សេងៗ, ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងបទប្បញ្ញត្តិ និងសេចក្តីសំរេចផ្សេងៗរបស់ឃុំ, ការអនុមតិផែនការអភិវឌ្ឍន៍ឃុំ និងបញ្ហាផ្សេងទៀតតាមការកំណត់របស់ MoI ។

---

[៣៦] ពាក្យថា ចៅហ្វាយស្រុក ឬអភិបាលស្រុក ត្រូវបានប្រើផ្លាស់ប្តូរគ្នាបាន ។ នៅក្នុងឯកសារនេះ គេប្រើពាក្យអភិបាលស្រុក ។

[៣៧] គេអាចមើលឃើញថា ទៅអនាគត គណៈកម្មាធិការមួយចំនួននឹងអាចតំរូវឡើងដោយច្បាប់ ជាការបន្ថែមទៅលើ គណៈកម្មាធិការកសាងផែនការនិងថវិកា ដែលបានកំណត់នាពេលថ្មីៗនេះ ។

នៅក្រោមមេឃុំ គឺមានជំទប់ទី១ និង ជំទប់ទី២ ដែលបំពេញតួនាទីជាអ្នកជំនួយការឱ្យមេឃុំ ។ ជំទប់ទី១ ជួយមេឃុំលើបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ហើយជំទប់ទី២ ជួយលើបញ្ហារដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ។

ដូចបានលើករួចហើយ ច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្នបានកំណត់ថា មេឃុំត្រូវបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា ដែលមានភារកិច្ចជួយមេឃុំ ក្នុងការកសាងនិងអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ, ផែនការវិនិយោគ និងថវិកាប្រចាំឆ្នាំ ។ គណៈកម្មាធិការកសាងផែនការនិងថវិកា មានប្រធានម្នាក់គឺមេឃុំ និងមានសមាជិកជា សមាជិកក្រុមប្រឹក្សាឃុំ ៣នាក់ទៀត, តំណាងអាជ្ញាធរភូមិ ២នាក់ដែលជ្រើសរើសដោយក្រុមប្រឹក្សាឃុំ, ប្រជាពលរដ្ឋក្នុងឃុំពី ២-៤នាក់ ដែលជ្រើសរើសដោយមេឃុំ និងស្មៀនឃុំដែលបំពេញតួនាទីជាលេខាធិការ ។

ក្រៅពីគណៈកម្មាធិការកសាងផែនការ និងថវិកា, អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់បានកំណត់ពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម ។ សមាសភាពគណៈកម្មាធិការនេះ រួមមាន មេឃុំ (ឬតំណាងរបស់គាត់) ជាប្រធាន, សមាជិកក្រុមប្រឹក្សាឃុំ ២នាក់ផ្សេងទៀតជាសមាជិក, ស្មៀនឃុំជាលេខាធិការ, និងបុគ្គលឯទៀតៗដែលប្រធានបានអញ្ជើញឱ្យមកធ្វើជាអ្នកសង្កេតការណ៍ ។ បច្ចុប្បន្ន មេឃុំមានសិទ្ធិបង្កើតគណៈកម្មការ និងអនុគណៈកម្មការបន្ថែម ដោយផ្អែកលើតំរូវការរបស់ឃុំ ប៉ុន្តែមិនទាន់មានការណែនាំច្បាស់លាស់ពីរបៀបបង្កើតវាទេ ។

ក្នុងការទ្រទ្រង់ដល់ក្រុមប្រឹក្សាឃុំ គឺមានស្មៀនឃុំដែលតែងតាំងដោយក្រសួងមហាផ្ទៃ ។ ស្មៀនឃុំដើរតួនាទីចំបងធ្វើជាលេខាធិការឱ្យក្រុមប្រឹក្សា ហើយគ្មានសិទ្ធិធ្វើសេចក្តីសំរេច ឬសិទ្ធិដាក់វិន័យលើក្រុមប្រឹក្សាទេ ។ ស្មៀនឃុំទទួលខុសត្រូវផ្តល់ពត៌មានឱ្យក្រុមប្រឹក្សាឃុំ ពីការតំរូវផ្សេងៗនៅក្នុងច្បាប់ ហើយក៏ដើរតួមួយកំរិតជាអ្នកប្រឹក្សាក្នុងមូលដ្ឋានដែរ ។ ស្មៀនឃុំទទួលបន្ទុកលើរាល់លិខិតចេញ/ចូល ដោយធានាថា លិខិតចូលត្រូវបានទទួលនិងយល់បានយ៉ាងច្បាស់ ហើយលិខិត/ឯកសារចេញគឺមានទំរង់សមស្រប និងមានលក្ខណៈត្រឹមត្រូវ/ស្របច្បាប់[៣៨] ។ ទិដ្ឋភាពមួយទៀតទាក់ទិននឹងខ្សែរយៈប្រស្រ័យទាក់ទង គឺស្មៀនឃុំអាចទាក់ទងផ្ទាល់ជាមួយក្រសួងមហាផ្ទៃនៅកំរិតជាតិ ដោយមានទាំងលើបញ្ហាសំខាន់ៗចំពោះឃុំផង ។ មានច្រើននាក់បានទិតៀនថា ក្រុមប្រឹក្សាឃុំត្រូវជាប់ផុងក្នុងប្រព័ន្ធខ្សែរយៈទាក់ទងដែលគោរពឋានានុក្រមហួសពេក គឺក្រុមប្រឹក្សាឃុំអាចទាក់ទងជាមួយកំរិតជាតិតែតាមរយៈសាលាខេត្ត ។ ស្មៀនឃុំ ដែលមានលទ្ធភាពរាយការណ៍ដោយផ្ទាល់ទៅក្រសួងមហាផ្ទៃ បើសិនក្រុមប្រឹក្សាឃុំស្នើឱ្យធ្វើដូច្នេះ, គឺជាច្រកមួយសំរាប់ជៀសវាងខ្សែរយៈឋានានុក្រមខាងលើ[៣៩] ។

ក្រៅពីអង្គភាពនានានៅកំរិតឃុំដែលបានលើករួចហើយ ក្នុងអនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំបានថា ក្រុមប្រឹក្សាឃុំត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំម្នាក់ជានារី ដើម្បីឱ្យទទួលបន្ទុកកិច្ចការនារី និងកុមារ។ ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាឃុំត្រូវតែងតាំងនារីមួយរូប (នៅក្នុងឃុំ) ធ្វើជាជំនួយការ (នៃសមាជិកក្រុមប្រឹក្សាឃុំដែល) ទទួលបន្ទុកកិច្ចការនារី និងកុមារ ។

ពួកក្រុមប្រឹក្សាឃុំអាចធ្វើការជាមួយគ្នា និងធ្វើកិច្ចព្រមព្រៀងរួមគ្នាជាមួយក្រុមប្រឹក្សាឃុំឯទៀតៗ ប៉ុន្តែ ប្រកាសដែលបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាច្រើនដែលធ្វើការជាមួយគ្នា គឺមិនទាន់បានអនុម័តចេញនៅឡើយទេ ហើយសព្វថ្ងៃ UNDP កំពុងធ្វើការសិក្សាខាងគោលនយោបាយមួយនៅលើបញ្ហានេះ ។

[៣៨] នៅកម្ពុជា ពិធីការគឺជាប្រការសំខាន់ណាស់ ។ បច្ចុប្បន្ន POLA កំពុងតាក់តែងសេចក្តីណែនាំលំអិតស្តីពី ទំរង់សមស្របនៃលិខិតទាក់ទងពីក្រុមប្រឹក្សាឃុំ ទៅថ្នាក់ផ្សេងទៀត ដូចជា អភិបាលស្រុក និង អភិបាលខេត្ត ជាដើម ។

[៣៩] សូមអានមាត្រា៥ នៃ ប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ/សង្កាត់ ។

### *៦.២.៧ រដ្ឋបាលកំរិតភូមិ*

ដោយរដ្ឋធម្មនុញ្ញ មិនបានទទួលស្គាល់ភូមិថាជាកំរិតមួយនៅក្នុងរដ្ឋអំណាច ដូច្នេះរចនាសម្ព័ន្ធភូមិ គឺគ្រាន់តែជាសាខាខាងរដ្ឋបាលរបស់ឃុំប៉ុណ្ណោះ ។ បើសិនគេចង់ផ្តល់ឱ្យភូមិនៅកម្ពុជានូវសិទ្ធិអំណាចពិត១ខាងនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ដើម្បីឱ្យភូមិក្លាយទៅជាអង្គភាពរដ្ឋបាលស្វយ័ត ដូចដែលគេបានធ្វើរួចហើយសំរាប់ក្រុមប្រឹក្សាឃុំ, រដ្ឋធម្មនុញ្ញគឺត្រូវតែធ្វើវិសោធនកម្មជាចាំបាច់ ។

ប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិបច្ចុប្បន្ន អនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំតែងតាំង មេភូមិដែលដើរតួជាច្រកផ្តល់ពត៌មាន និងធ្វើទំនាក់ទំនងរវាងក្រុមប្រឹក្សា (រួមទាំងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា) និងភូមិ ។ មេភូមិតែងតាំងអនុប្រធានភូមិម្នាក់ និង សមាជិកភូមិម្នាក់ ។ យោងតាមមាត្រា ២៦ នៃអនុក្រឹត្យស្តីពីវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ, ក្នុងចំណោមអ្នកដឹកនាំភូមិទាំងបីនាក់ ត្រូវតែមានម្នាក់យ៉ាងតិចចុះជួបប្រជុំជាមួយអ្នកភូមិ ឱ្យបាន ១ដង/សប្តាហ៍ នៅទីកន្លែងដែលបានកំណត់[៤០] ។

បច្ចុប្បន្ន ច្បាប់ដែលចែងពីនីតិវិធីសំរាប់ ការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងសមាជិកភូមិ, ព្រមទាំងវិធានជាប់ទាក់ទងនឹងនីតិវិធីធ្វើការងារ និងបំពេញភារកិច្ចរបស់មេភូមិ គឺមិនទាន់មានប្រកាសឱ្យប្រើទេ។

រចនាសម្ព័ន្ធមួយទៀតដែលមានក្នុងភូមិមួយចំនួន (មិនមែនទាំងអស់ទេ) គឺគណៈកម្មការអភិវឌ្ឍន៍ភូមិ (VDC) ។ VDC ច្រើនតែជាអង្គភាពផ្សារភ្ជាប់នឹងគំរោង ដែលបានដំណើរការដោយមានកំរិតប្រសិទ្ធភាពខុស១គ្នា ។ រចនាសម្ព័ន្ធនេះអាចផ្លាស់ប្តូរចេញបាន តាមរយៈច្បាប់/បទប្បញ្ញត្តិដូចបានបង្ហាញពីខាងដើម ដើម្បីឱ្យក្រុមប្រឹក្សាឃុំ អាចមានរចនាសម្ព័ន្ធរដ្ឋបាលដ៏សក្តិសិទ្ធិនៅកំរិតភូមិ ដែលសមស្របល្អសំរាប់តួនាទី ភារកិច្ច និងមុខងារជាទូទៅរបស់ខ្លួន ហើយរដ្ឋាភិបាលគួរពិនិត្យរឿងនេះឱ្យបានហ្មត់ចត់មុនពេលដាក់អនុវត្តច្បាប់ផ្សេង១ដូចបញ្ជាក់ខាងលើ ។

## ៧. តួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ

LAMC និង អនុក្រឹត្យស្តីពីវិមជ្ឈការតួនាទី ភារកិច្ច និងមុខងារ ទៅឱ្យក្រុមប្រឹក្សាឃុំ, បានចែងដោយត្រួស១ ពីតួនាទីជាទូទៅដែលទូលំទូលាយខ្លាំងណាស់របស់ក្រុមប្រឹក្សាឃុំ ។ LAMC កំណត់តួនាទីទាំងនេះដូចតទៅ:[៤១]

១. ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈ

២. រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

៣. លើកទឹកចិត្តឱ្យមានការបង្កើតផាសុកភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ

៤. ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

៥. ការពារថែរក្សា បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ

៦. សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក

៧. បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

---

[៤០] ដោយសារ *ប្រកាស* ជាប់ទាក់ទិននានាមិនទាន់បានអនុម័ត ដូច្នេះគេមិនអាចរំពឹងថា បទប្បញ្ញត្តិបែបនេះនឹងត្រូវបានដាក់អនុវត្ត ។

[៤១] មាត្រា ៤៣ នៃ LAMC ។

អនុក្រឹត្យស្តីពីវិមជ្ឈការតួនាទី ភារកិច្ច និងមុខងារ ដែលត្រូវផ្តល់បន្ថែមនូវសេចក្តីលំអិត និងការកំណត់ភារកិច្ចនានាដូចខាងលើ, គឺមិនបានផ្តល់ការបំភ្លឺអ្វីច្រើនទេ ដោយគ្រាន់តែរៀបរាប់ដដែលឡើងវិញ និងបន្ថែមចំណុចដូចខាងក្រោម៖

១. លើកស្ទួយ និងសំរបសំរួលក្នុងការអភិវឌ្ឍន៍ក្នុងឃុំ ដោយត្រូវរកប្រភពជំនួយឥតសំណង និងគៀងគរសមត្ថភាព និងធនធាន

២. សំរបសំរួល និងលើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យក្នុងឃុំ ។

ការផ្តល់សិទ្ធិអំណាចដ៏ទូលំទូលាយទាំងនេះដែលក្រុមប្រឹក្សាឃុំពិបាកយល់, បានបង្កើតនូវក្របខ័ណ្ឌមួយដែលគេអាចបន្ថែមចំណុចលំអិតផ្សេងៗជាក្រោយមកទៀត ។ ដូចមានចែងក្នុងមាត្រា ៦៣ នៃអនុក្រឹត្យ "ឃុំ សង្កាត់ មានសិទ្ធិជ្រើសរើស និង អនុវត្តសកម្មភាពណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចនៃមុខងារជាទូទៅ និងដែលស្ថិតនៅក្នុងកំរិតនៃធនធានដែលអាចមាន" ។

ទន្ទឹមគ្នានេះ មុខងារជាក់លាក់មួយចំនួនដែលក្រុមប្រឹក្សាឃុំទទួលស្គាល់ និងយល់ដឹង ត្រូវបានផ្តល់ទៅឱ្យ (ឬក៏ត្រូវបានចាត់ចែងជាប្រពៃណីដោយ) ឃុំរួចហើយ ។ តួនាទីទាំងនេះរួមមាន ការរៀបចំ ការអនុមតិ និងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ និងវិនិយោគរបស់ឃុំ, ភារកិច្ចចុះសៀវភៅអត្រានុកូលដ្ឋាន[៤២], ការចុះបញ្ជីអ្នកបោះឆ្នោត[៤៣], ការដោះស្រាយទំនាស់ដីក្រៅផ្លូវការ[៤៤], ការកាន់កាប់ថែរក្សាកំណត់ត្រា, ការផ្តល់ពត៌មានចាំបាច់ (ដំណឹង) នៅកំរិតភូមិ និងឃុំ, ការធ្វើតំណាងដើម្បីបង្ហាញសេចក្តីត្រូវការរបស់ឃុំ និងការកេណ្ឌប្រមូលជំនួយទ្រទ្រង់សហគមន៍ ។

សព្វថ្ងៃ កង្វះច្បាប់/បទប្បញ្ញត្តិសំខាន់ៗបានរារាំងក្រុមប្រឹក្សាឃុំក្នុងការមើលឃើញពីតួនាទីជាសក្តានុពលទាំងអស់របស់ខ្លួន ដូចជាលទ្ធភាពតាក់តែងដីកាឃុំជាដើម ដើម្បីគ្រប់គ្រងការងារនៅក្នុងឃុំ[៤៥] ។ ម្យ៉ាងទៀត ការកសាងសមត្ថភាពបន្ថែម នឹងជួយឱ្យឃុំអាចប្រើប្រាស់សក្តានុពលរបស់ខ្លួនបានពេញលេញ ប៉ុន្តែកិច្ចការនេះត្រូវប្រើពេលយូរ ។ សមាជិកក្រុមប្រឹក្សាឃុំមានទំលាប់ទទួលបញ្ជាពីថ្នាក់លើ ដោយសារកើ្តដំណែលវប្បធម៌ និងប្រវត្តិសាស្ត្រខាងនយោបាយ, ហើយការផ្លាស់ប្តូរមិនអាចធ្វើបានភ្លាមៗទេ ។ ដូចមានពាក្យនិយាយជាទូទៅនៅកម្ពុជា ថា *"មួយៗ"* ដែលមានន័យជាសំខាន់ថា អ្វីៗទាំងអស់ទៅតាមដំណើររបស់វា ។ បើគេរំពឹងច្រើនពេកក្នុងរយៈពេលខ្លីពេកពីក្រុមប្រឹក្សាឃុំ ប្រព័ន្ធវិមជ្ឈការអាចនឹងទទួលបរាជ័យ ។

## ៨. ការអធិប្បាយពីច្បាប់ និងបទប្បញ្ញត្តិវិមជ្ឈការបច្ចុប្បន្ន

ដូចបានបង្ហាញពីខាងដើម ប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិដែលបានអនុម័តជាប់ទាក់ទិននឹងវិមជ្ឈការ គឺធំទូលាយណាស់ ហើយអាចពិបាកយល់ ជាពិសេសចំពោះអ្នកគ្មានការបណ្តុះបណ្តាលខាងច្បាប់ ។ ម្យ៉ាងទៀត ការតាក់តែងមិនសុទ្ធតែបានច្បាស់

---

[៤២] ដូចមានបង្ហាញក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ។ គួរកត់សំគាល់ថា មានការចុះបញ្ជីតិចតួចណាស់ក្នុងការពិតជាក់ស្តែង ហើយមេឃុំយល់ ថា មុខងារនេះមិនសមឋានៈរបស់គាត់ទេ ។ ដំណោះស្រាយគឺអាចផ្តល់ជាធនធានដ៏ចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សាឃុំអាចជួលបុគ្គលិកម្នាក់ មកធ្វើការងារនេះ ។

[៤៣] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាឃុំនូវភារកិច្ចធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកបោះឆ្នោត ប៉ុន្តែពុំមានផ្តល់មូលនិធិបន្ថែមសំរាប់ការងារនេះទេ ។

[៤៤] អនុក្រឹត្យគណៈកម្មាធិការសុរិយោដីចែងថា តំណាងអាជ្ញាធរឃុំនានាគួរទទួលការអញ្ជើញឱ្យចូលរួមជាសមាជិក ចំពោះកិច្ចការរបស់គណៈកម្មការកំរិតស្រុកនានាដែលទទួលខុសត្រូវដោះស្រាយទំនាស់ដីធ្លីទាក់ទិននឹងអចលនទ្រព្យមិនទាន់បានចុះបញ្ជី ។ គេមិនដឹងច្បាស់ទេថាតើតួនាទីនេះនឹងទៅជាយ៉ាងណាក្នុងពេលអនាគត ។

[៤៥] នៅតំបន់ខ្លះ ឃុំបានតាក់តែង និងអនុវត្តដីកាឃុំរួចហើយ ។

លាស់ល្អរាល់លើកទេ ហើយជាទូទៅនៅមានគុណភាពទាបជាងក៏រិតស្តង់ដាក្នុងបណ្តាប្រទេសអភិវឌ្ឍន៍[៤៦] ។ ទោះយ៉ាងនេះក្តី គេគួរកត់សំគាល់ជាសំខាន់ថា ចំពោះអ្នកអនុវត្តជាក់ស្តែងនូវច្បាប់និងបទប្បញ្ញត្តិ គឺមានរបាយការណ៍តិចតួចណាស់ពីឧបសគ្គរាំងស្ទះផ្សេងៗដែលកើតចេញផ្ទាល់ពីបញ្ហាចោទនៅក្នុងច្បាប់ ។ រឿងនេះប្រហែលដោយសារច្បាប់នៅកម្ពុជា ច្រើនតែដាក់អនុវត្តតាមរយៈប្រកាស ។ និយាយឱ្យខ្លីមក ប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ន គឺអាចអនុវត្តបាន ។ បញ្ហាភាគច្រើនបំផុតដែលរាយការណ៍ឡើង គឺជាប់ទាក់ទិននឹងច្បាប់/បទប្បញ្ញត្តិសំខាន់ៗដែលសព្វថ្ងៃមិនទាន់មាន ។ ចំពោះបញ្ហាធំៗមួយចំនួនដែលបានរកឃើញនៅក្នុងច្បាប់/បទប្បញ្ញត្តិបានអនុម័តរួចហើយ គឺមានលើកមកពិភាក្សានៅក្នុងផ្នែក ៨.២ ខាងក្រោម ។

រឿងត្រូវប្រយ័ត្ន គឺការទាមទារឱ្យតាក់តែងឡើងវិញទាំងអស់នូវកំរងច្បាប់/បទប្បញ្ញត្តិដែលបានអនុម័តហើយ ដោយសារបញ្ហាចោទក្នុងការតាក់តែង ។ ទង្វើនេះនឹងស្រូបយកធនធានដ៏មានតំលៃនានាដែលគួរយកទៅប្រើនៅកន្លែងផ្សេងជាការប្រសើរ ពីព្រោះវាមិនប្រាកដទេថា ប្រព័ន្ធដែលត្រូវយកមកជំនួសអ្វីៗបានតាក់តែងហើយ វានឹងពិតជាបានល្អជាងមុន ហើយវាអាចអន់ជាងមុនទៅទៀតក៏ថាបាន ។

អាចមានតំរូវការធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិ យោងតាមសេចក្តីសំរេចបន្តអាណត្តិឱ្យ NCSC ឬក៏ត្រូវផ្ទេរតួនាទីនិងភារកិច្ចរបស់វា ទៅឱ្យស្ថាប័នរដ្ឋអចិន្ត្រៃយ៍មួយទៀត ។ ការចេញច្បាប់ផ្សេងៗទៀត ក៏អាចទាមទារការធ្វើវិសោធនកម្មខ្លះដែរ ដូចជា ការចេញច្បាប់រៀបចំអង្គការស្តីពីរដ្ឋបាលខេត្ត និងស្រុក ជាដើម ។ បើសិនជា LAMC ត្រូវធ្វើវិសោធនកម្ម ដែលទាមទារការអនុវត្តន៍ដំណើរការដ៏វែងមួយខាងផ្លូវច្បាប់ ដូចបានលើកឡើងនៅក្នុងផ្នែក ៥.១ ស្រាប់, ដូច្នេះគួរមានការប្រឹងប្រែងតឹមប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិក្នុងពេលជាមួយគ្នា ដើម្បីធានាឱ្យវាស៊ីសង្វាក់គ្នានិងច្បាស់លាស់ល្អ ជាបន្ថែមទៅលើការបញ្ចូលមេរៀនផ្សេងៗដែលរៀនសូត្របាន ។ ដំណើរការតាក់តែងនិងអនុម័តច្បាប់ឡើងវិញបែបនេះ ប្រហែលត្រូវធ្វើឡើងនៅឆ្នាំ២០០៦ នៅមុនការបោះឆ្នោតលើកក្រោយក្នុងឆ្នាំ២០០៧ ។

## *៨.១ បញ្ហាទាក់ទិននឹងការបកស្រាយច្បាប់*

បញ្ហាមួយ (មានច្រើនទៀត) ដែលទាក់ទិននឹងការបកស្រាយច្បាប់/បទប្បញ្ញត្តិដែលមានស្រាប់នៅពេលនេះ គឺជំនាញការច្បាប់ផ្សេងគ្នា អាចមានការបកស្រាយខុសគ្នាដោយយោងតាមសេចក្តីសន្និដ្ឋានដែលគេចង់បាន ។ នេះជាតួនាទីរបស់អ្នកច្បាប់និងអ្នកតស៊ូមតិជាទូទៅក្នុងពិភពលោក ។ ក្នុងបរិបទកម្ពុជា មានការទទួលស្គាល់ជាទូទៅនូវគោលការណ៍ថា អង្គភាពរដ្ឋដែលមានសមត្ថកិច្ចក្នុងរឿងជាក់លាក់អ្វីមួយ គឺមានការទទួលខុសត្រូវបកស្រាយន័យក្នុងច្បាប់/បទប្បញ្ញត្តិក្នុងរឿងនោះ ។ ឧទាហរណ៍ ក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំនង់ (MLMUPC) អាចប្រកាសថា ខ្លួនជាអង្គភាពតែមួយគត់ដែលអាចបកស្រាយន័យក្នុងច្បាប់ភូមិបាល ។ ដូចគ្នាដែរ MoI អាចជជែកវែកញែកថា ច្បាប់/បទប្បញ្ញត្តិជាប់ទាក់ទងនឹងក្រុមប្រឹក្សាឃុំ គួរតែទុកឱ្យ MoI ធ្វើការបកស្រាយ ។ រឿងនេះអាចស្មុគស្មាញខ្លាំង ពីព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងជជែកវែកញែកថា ការបកស្រាយបទប្បញ្ញត្តិច្បាប់ជាប់ទាក់ទងនឹងហិរញ្ញវត្ថុឃុំ គឺជាការទទួលខុសត្រូវរបស់ខ្លួន ។ល។

នៅចុងបញ្ចប់ បើសិនមានទំនាស់លើការបកស្រាយច្បាប់/បទប្បញ្ញត្តិ អង្គចៅក្រម និងតុលាការ គួរមានតួនាទីជាអាជ្ញាកណ្តាលចុងក្រោយ ដើម្បីអារកាត់លើអត្ថន័យ និងគោលបំណង ។ ជាអកុសល ផ្នែកតុលាការនៅទន់ខ្សោយច្រើន ហើយកម្ពុជាមិនទាន់មានបង្កើតយន្តការអ្វីមួយច្បាស់ទេ សំរាប់ដោះស្រាយបណ្តឹងតវ៉ាខាងរដ្ឋបាលអំពីបញ្ហាចោទខាងការបកស្រាយច្បាប់[៤៧] ។

---

[៤៦] ច្បាប់/បទប្បញ្ញត្តិបានអនុម័តហើយ មានលក្ខណៈស្របទៅតាមកំរិតគុណភាពនៃការតាក់តែងច្បាប់ដែលឃើញមានជាទូទៅនៅកម្ពុជា ។

[៤៧] កំណែទំរង់តុលាការដែលជាប់ទាក់ទិននឹងវិមជ្ឈការ មានសិក្សាលំអិតថែមទៀតនៅក្នុងផ្នែក១១ ខាងក្រោម ។

បច្ចុប្បន្ន ការបកស្រាយ និងការអនុវត្តន៍ច្បាប់នៅកម្ពុជា វាជារឿងឆន្ទៈនយោបាយ ជាជាងរឿងអ្វីផ្សេងទៀត ។ ទោះបីច្បាប់/បទប្បញ្ញត្តិ បានតាក់តែងល្អយ៉ាងណាក្តី ប៉ុន្តែគ្មានអ្វីធានាថានឹងអាចដាក់អនុវត្តតាមដូចពាក្យពេចន៍ដែលបានសរសេរនោះទេ ។ ពួកមន្ត្រីរាជការត្រូវតែធ្វើការបកស្រាយនិងអនុវត្តច្បាប់ ទៅតាមសេចក្តីណែនាំ និងការគាំទ្រពីថ្នាក់លើរបស់ខ្លួន ។

### ៨.២ បញ្ហាសំខាន់ៗដែលរកឃើញ

បញ្ហាចំបងៗមួយចំនួន ត្រូវបានរកឃើញនៅក្នុងប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ន[៤៨] ។ បញ្ហាមួយចំនួនមិនប៉ះពាល់ដល់ការអនុវត្តន៍ច្បាប់នៅពេលនេះទេ ប៉ុន្តែវាអាចបង្កការលំបាកជាក់ស្តែងនៅពេលអនាគត ។ បញ្ហាផ្សេងៗទៀត ដែលមិនបានរកឃើញនៅពេលពិនិត្យមើលច្បាប់/បទប្បញ្ញត្តិឡើងវិញ វានឹងផុសឡើងនៅពេលអនុវត្តន៍ ដោយសារតែការបកស្រាយដែលពួកអ្នកជាប់ទាក់ទិននៅក្នុងដំណើរការតាក់តែងច្បាប់មិនបានប្រមើលឃើញ ។

បញ្ហាគួរកត់សំគាល់ទី១ គឺជាប់ទាក់ទងនឹងការដាក់វិន័យ ឬការដកចេញនូវសមាជិកក្រុមប្រឹក្សាខ្លះ ឬដកក្រុមប្រឹក្សាទាំង មូលតែម្តង ។ កន្លងមក ស្ថានភាពនេះមិនដែលកើតមានទេ ប៉ុន្តែវាអាចចោទបញ្ហាទៅអនាគត ជាពិសេសបើសិនវាជាប់ទាក់ទិន នឹងការក្តោបក្តាប់អំណាចនយោបាយ ឬក៏នៅពេលដែលក្រុមប្រឹក្សាក្លាយជាកូនអុកនៅក្នុងការតតាំងគ្នាផ្សេងៗនៅកំរិតជាតិ ។

មាត្រា ១៦ នៃ LAMC ចែងថា សមាជិកក្រុមប្រឹក្សា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងក្រុមប្រឹក្សាឃុំ បើសិនសាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង/ស្ថាប័នមានសមត្ថកិច្ច[៤៩], ល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ ឬក៏ក្នុងករណីដែលក្រុមប្រឹក្សាទាំងមូលត្រូវរំលាយ ។ មាត្រា៥៨ ចែងថា ក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំចោលភ្លាម បើសិនក្រុមប្រឹក្សានោះធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងនយោបាយរដ្ឋាភិបាល ។ មាត្រា៨៤ ចែងថាសមាជិកក្រុមប្រឹក្សាឃុំអាចត្រូវទទួលវិន័យ បើសិនមិនបានគោរពតាមបទប្បញ្ញត្តិនៃ LAMC ហើយបើសិនជាក្រោយពេលទទួលវិន័យ ហើយសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំអាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ ដោយការបោះឆ្នោតអនុម័តតាមសំលេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំទាំងមូល ។ អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំក្នុងជំពូក ៤ ដែលចែងពីការដាក់វិន័យ និងការដេញចេញសមាជិកក្រុមប្រឹក្សាឃុំ, បានផ្តល់ការបំភ្លឺតិចតួចណាស់ពីស្តង់ដាសំរាប់ការដេញចេញ ឬការរំលាយចោល ។ មាត្រា ២៤ នៃប្រកាសអភិបាលខេត្តចែងថាអភិបាលខេត្តត្រូវរាយការណ៍ទៅ MoI នៅពេលក្រុមប្រឹក្សាឃុំ មិនបានអនុវត្តតាម LAMC ឬប្រព្រឹត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងគោលនយោបាយរបស់រដ្ឋាភិបាល, ដែលអាចនាំឱ្យមានសេចក្តីសំរេចពីរដ្ឋមន្ត្រីដើម្បីរំលាយក្រុមប្រឹក្សា ។

បញ្ហាចោទក្នុងបទប្បញ្ញត្តិទាំងនេះ គឺការកំណត់លក្ខខណ្ឌស្តង់ដាមិនទាន់ច្បាស់លាស់ ។ អ្វីទៅដែលជាការបាត់សម្បទាវិជ្ជាជីវៈ? តើអ្វីទៅដែលចាត់ទុកជាសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬផ្ទុយនឹងគោលនយោបាយរបស់រដ្ឋាភិបាល? ម្យ៉ាងទៀត គ្មានបទប្បញ្ញត្តិអ្វីសំរាប់ឱ្យសមាជិកក្រុមប្រឹក្សា ឬក្រុមប្រឹក្សា ធ្វើការជំទាស់តាមផ្លូវរដ្ឋបាល ឬក៏ប្តឹងតវ៉ានឹងសេចក្តីសំរេចទាំងនេះទៅតុលាការទេ[៥០] ។ គេអាចមើលឃើញដោយងាយថា បទប្បញ្ញត្តិស្តីពីការដេញចេញ និងការរំលាយ អាចយកទៅប្រើដោយ

---

[៤៨] បញ្ហាទាក់ទិននឹងរចនាសម្ព័ន្ធផ្សេងៗដែលបង្កើតឡើងដើម្បីទ្រទ្រង់វិមជ្ឈការ មានអធិប្បាយរួចហើយនៅក្នុងផ្នែកទី៦ ដូច្នេះគ្មានលើកឡើងម្តងទៀតទេនៅក្នុងផ្នែកនេះ ។

[៤៩] ក្នុង LAMC និងវិធាន/បទប្បញ្ញត្តិគាំទ្រនានា ពុំមានចែងពីលក្ខខណ្ឌស្តង់ដានៃការបាត់បង់សម្បទាវិជ្ជាជីវៈទេ ។

[៥០] មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការ

រំលោភបាន ប៉ុន្តែលទ្ធភាពអាចមានហេតុការណ៍បែបនេះគឺគ្រាន់តែជាការគិតគូរពិចារណាប៉ុណ្ណោះ ។

បញ្ហាចោទផងដែរស្តីពីការគោរពតាមឋានានុក្រមរឹងកំព្រឹសពេក ទាក់ទិននឹងខ្សែរយៈទំនាក់ទំនងចុះឡើង[៥១] ។ ការទាក់ទងពីក្រុមប្រឹក្សាឃុំ ទៅ MoI ឬទៅអង្គភាពថ្នាក់ជាតិផ្សេងទៀត ត្រូវតែឆ្លងសាលាខេត្ត ។ បើសិនការទាក់ទងនោះជាប់ទាក់ទិននឹងការតវ៉ាអំពីសាលាខេត្ត រឿងនេះអាចបង្កជាបញ្ហាយ៉ាងងាយ ។ មាត្រា ៥ នៃប្រកាសស្មៀនឃុំចែងថា ស្មៀនឃុំអាចធ្វើសេចក្តីរាយការណ៍ផ្ទាល់ទៅ MoI អំពីបញ្ហាមួយចំនួនដែលពាក់ព័ន្ធចំពោះឃុំ និងក្រុមប្រឹក្សាឃុំ ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ ។ ដូច្នេះមាត្រានេះបានផ្តល់មធ្យោបាយមួយសំរាប់ចៀសវាងអំពីការតំរូវថា ទំនាក់ទំនងទាំងអស់ត្រូវធ្វើតាមរយៈសាលាខេត្ត ។ លើសពីនេះ ច្រកទំនាក់ទំនងក្រៅផ្លូវការតែងតែមានជានិច្ច ដែលអាចជួយឱ្យចៀសផុតពីការគោរពពិធីការរឹងកំព្រឹសនៃឋានានុក្រមរដ្ឋាភិបាល ។

បញ្ហាដ៏ធ្ងន់ធ្ងរមួយនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាប់ទាក់ទិននឹងហិរញ្ញវត្ថុឃុំ ទើបនឹងផុសចេញមកក្នុងពេលថ្មីៗ ។ ជំពូកទី៧ នៃ LAMC មានបទប្បញ្ញត្តិជាលក្ខណៈទូទៅមួយចំនួនទាក់ទិននឹងហិរញ្ញវត្ថុឃុំ ដោយមានសេចក្តីចែងថា ការណែនាំលំអិតផ្សេងៗ នឹងត្រូវបំពេញបន្ថែមដោយអនុក្រឹត្យ ។ មាត្រា ៣ នៃអនុក្រឹត្យមូលនិធិឃុំចែងថា ចំណូលមូលនិធិទាំងឡាយណាដែលមិនបានផ្ទេរក្នុងឆ្នាំ (ទៅឱ្យឃុំ) ត្រូវយោងទៅឆ្នាំបន្ទាប់ ។ មាត្រា ២២ និង ២៣ នៃអនុក្រឹត្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំចែងថា មូលនិធិអភិវឌ្ឍន៍ដែលមិនបានប្រើនៅចុងឆ្នាំសារពើពន្ធ ត្រូវបានរតនាគារខេត្តដាក់បញ្ចូលទៅក្នុងគណនីមូលនិធិបំរុងមួយ ហើយទឹកប្រាក់នៅក្នុងគណនីនោះអាចប្រើប្រាស់សំរាប់តែដោះស្រាយចំណាយមូលធននៅក្នុងឆ្នាំបន្ទាប់ៗទៀត ។ មូលហេតុ នៃការយោងទៅមុខនូវចំនាយមូលធន ឬមូលនិធិអភិវឌ្ឍន៍ គឺដោយសារក្រុមប្រឹក្សាឃុំអនុវត្តការងារតាមផែនការវិនិយោគ ៣ឆ្នាំរំកិល ហេតុនេះក្រុមប្រឹក្សាត្រូវមានលទ្ធភាពបត់បែនបានខ្លះ ក្នុងការចាត់ចែងមូលនិធិសំរាប់ចំនាយមូលធនដែលបានមកពី ថវិកាជាតិ ។ ជាការគួរឱ្យសោកស្តាយ MEF មិនទទួលស្គាល់ពាក្យពេចន៍ក្នុងអនុក្រឹត្យនានាដែលគាំទ្រដល់ប្រព័ន្ធនេះទេ ដោយ សំអាងថាច្បាប់ថវិកាឆ្នាំ២000 បានកំណត់ឱ្យបង្វិលរាល់មូលនិធិមិនបានប្រើប្រាស់ទាំងអស់ ទៅរតនាគារជាតិវិញនៅចុងឆ្នាំ សារពើពន្ធ ។ នេះជាស្ថានការណ៍ដែលការិយាធិបតេយ្យនៅក្នុងក្រសួងមួយ បានបកស្រាយច្បាប់តាមបែបបទដែលមិនគាំទ្រ ប្រព័ន្ធវិមជ្ឈការ ។ តើក្រុមប្រឹក្សាឃុំអាចតាក់តែង និងអនុវត្តផែនការវិនិយោគ៣ឆ្នាំរំកិលយ៉ាងណាកើត បើមូលនិធិវិនិយោគមានសំរាប់តែក្នុងឆ្នាំ ដែលវាត្រូវបានផ្ទេរទៅដល់រតនាគារខេត្ត, ជាពិសេសបើសិនពិចារណាពីការពិតជាក់ស្តែងដែលថា ការធ្វើផែនការ លទ្ធកម្ម និងកិច្ចសន្យារដ្ឋបាល មិនមែនសុទ្ធតែជាក់បញ្ចូលបានទាំងមូលទៅក្នុងគំរោងថវិកាសំរាប់រយៈ១ឆ្នាំនោះទេ? អាចមានដំណោះស្រាយពីរសំរាប់បញ្ហានេះ ១) នៅក្នុង LAMC ត្រង់ចំណុចនេះ ត្រូវប្រើពាក្យពេចន៍ឱ្យបានរឹងប៉ឹងថែមទៀត ហើយរយៈតាមនេះបញ្ហាកំលាំងពាក្យពេចន៍ក្នុងអនុក្រឹត្យ ទល់នឹងកំលាំងពាក្យពេចន៍ក្នុងនៅក្នុងច្បាប់ នឹងត្រូវបានដោះស្រាយ ២) ការប្តេជ្ញាខាងនយោបាយពិតៗរបស់រដ្ឋាភិបាលចំពោះដំណើរការវិមជ្ឈការ នាំឱ្យមានការបកស្រាយមួយបែបផ្សេងទៀតនូវច្បាប់ និងបទប្បញ្ញត្តិនានា ពីសំណាក់ការិយាធិបតេយ្យនៅក្នុង MEF ។

បញ្ហាចុងក្រោយនេះបង្ហាញថា បញ្ហាពិតៗនៅក្នុងច្បាប់ដែលប៉ះពាល់ដល់ការអនុវត្តន៍ អាចមើលមិនឃើញភ្លាមៗទេគឺទាល់តែកន្លងមួយរយៈពេលទៅទើបអាចមើលឃើញ ហើយក៏ត្រូវធ្វើការដោះស្រាយ ។

---

ខូចខាតជាសមត្ថកិច្ចរបស់តុលាការ" ។ ជាអកុសល នៅក្នុងច្បាប់ បទប្បញ្ញត្តិដែលចែងពីរឿងនេះមានខ្លឹមសារស្រពិចស្រពិលណាស់ ដែលធ្វើឱ្យពិបាកដល់ការប្តឹងតវ៉ាថា មានការរំលោភច្បាប់ ។

[៥១] នេះជាបញ្ហាមានលើកឡើងជារឿយៗ ហើយវាបញ្ជាក់គាំទ្រដល់ចំណុចមួយដែលបានលើកឡើងរួចហើយថា មនុស្សផ្សេងគ្នាដែលផ្តល់មតិគឺអាចមានការសន្និដ្ឋានខុសគ្នា នៅពេលធ្វើការបកស្រាយច្បាប់ ។

### *៨.៣ ច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗនៅខ្វះខាតសព្វថ្ងៃ*

ច្បាប់និងបទប្បញ្ញត្តិដែលត្រូវអនុម័តដើម្បីទ្រទ្រង់ដល់វិមជ្ឈការគឺមានមួយបញ្ជីយ៉ាងវែង[៥២] ហើយក្នុងនេះឯកសារច្បាប់ដែលគេសំគាល់ថាសំខាន់ៗបំផុតមានដូចខាងក្រោម ។ ឯកសារគោលនយោបាយក៏បានដាក់បញ្ចូលដែរ ដោយសារគេគួរផ្សារភ្ជាប់វាជាមួយនឹងការតាក់តែងច្បាប់និងបទប្បញ្ញត្តិ ។

មានជំហានធំៗជាច្រើនដែលត្រូវអនុវត្តនៅក្នុងការកសាងប្រព័ន្ធវិមជ្ឈការ ។ ទី១ គឺការកសាងឯកសារគោលនយោបាយ មួយដ៏ច្បាស់លាស់ទាក់ទិននឹងអភិបាលកិច្ចក្រុមប្រឹក្សាឃុំ ដែលអាចយកមកប្រើដើម្បីបញ្ជាក់ពីភារកិច្ច តួនាទី និងការទទួលខុស ត្រូវរបស់តួអង្គផ្សេងៗតាំងពីថ្នាក់ជាតិទៅដល់អាជ្ញាធរកឹរិតភូមិ ។ បន្ទាប់មកឯកសារនេះអាចយកមកប្រើដើម្បីធ្វើវិសោធនកម្ម ឬតាក់តែងឡើងវិញនូវច្បាប់មានស្រាប់នានា ហើយក៏អាចប្រើប្រាស់ដើម្បីបកស្រាយពីគោលបំណងនៃច្បាប់ដែរ[៥៣] ។ ចងភ្ជាប់គ្នាមិនអាចកាត់ផ្តាច់បានជាមួយនឹងការកសាងឯកសារគោលនយោបាយនេះ គឺការកសាងឯកសារគោលនយោបាយច្បាស់លាស់មួយសំរាប់ការតាក់តែងច្បាប់រៀបចំអង្គការ ។ រចនាសម្ព័ន្ធ ភារកិច្ច តួនាទី និងការទទួលខុសត្រូវដែលត្រូវកំណត់សំរាប់អាជ្ញាធរកឹរិតខេត្ត និងស្រុក នឹងប៉ះពាល់ទៅដល់ប្រព័ន្ធច្បាប់និងបទប្បញ្ញត្តិដែលបានដាក់អនុវត្តហើយដើម្បីទ្រទ្រង់ដល់ក្រុមប្រឹក្សាឃុំ ។ ដោយមូលហេតុនេះ ឯកសារគោលនយោបាយពីរត្រូវតាក់តែងឡើង ដោយផ្សារភ្ជាប់ទៅការតាក់តែងឡើងវិញនូវ LAMC ព្រមទាំងវិធាននិងបទប្បញ្ញត្តិផ្សេងៗសំរាប់គាំទ្រវា ។ នេះជាការងារមួយធំធេងណាស់ដែលត្រូវមានការសំរបសំរួលយ៉ាងប្រយ័ត្នប្រយែងក្នុងចំណោមអ្នកមានសិទ្ធិអំណាច និងអ្នកជាប់ពាក់ព័ន្ធនានា ។

នៅពេលនេះ រដ្ឋាភិបាលលើកផែនការថា ឯកសារគោលនយោបាយសំរាប់ច្បាប់រៀបចំអង្គការត្រូវតាក់តែង និងអនុម័តឱ្យបានមុនដំណាច់ឆមាសទី១ ឆ្នាំ២០០៥ ហើយច្បាប់ពិតប្រាកដ ត្រូវតាក់តែងនិងអនុម័តនៅឆ្នាំ២០០៦ ឱ្យបានមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំលើកក្រោយ[៥៤] ។ បច្ចុប្បន្ន មិនទាន់មានផែនការតាក់តែងឯកសារគោលនយោបាយច្បាស់លាស់មួយស្តីពីអ្វីដែលត្រូវធ្វើទាក់ទិននឹងប្រព័ន្ធបច្ចុប្បន្ននៃច្បាប់សំរាប់គ្រប់គ្រងក្រុមប្រឹក្សាឃុំ ។ ការគួបឯកសារគោលនយោបាយទាំងពីរចូលគ្នាអាចជាគំនិតល្អ ពីព្រោះបញ្ហាផ្សេងៗវាជាប់ទាក់ទងគ្នាចុះឡើងយ៉ាងជិតស្និទ្ធ, ហើយបន្ទាប់មកត្រូវតាក់តែងច្បាប់រៀបចំអង្គការតែមួយដែលមានដាក់បញ្ចូល LAMC ផងដែរ ។ គេត្រូវយកចិត្តទុកដាក់លើបញ្ហានេះ ។

មានបញ្ហាត្រូវដោះស្រាយជាច្រើនទៀត នៅពេលគិតគូរអំពី ច្បាប់និងបទប្បញ្ញត្តិសំខាន់ៗដែលនៅខ្វះខាតសព្វថ្ងៃ ។ បញ្ហាមួយគឺ កង្វះច្បាប់ស្តីពីការកំណត់ ប្រភេទ អត្រា និង របៀបរបបនៃការប្រមូលចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកំរៃសេវា ផ្សេងៗសំរាប់ក្រុមប្រឹក្សាឃុំ[៥៥] ។ តាមមតិជាច្រើន ការតាក់តែងច្បាប់នេះមិនទាន់បានធ្វើក្នុង២-៣ឆ្នាំខាងមុខដូច្នេះត្រូវតែដាក់ អនុវត្តរចនាសម្ព័ន្ធបណ្តោះអាសន្នមួយចំនួន ។ បញ្ហាបារម្ភចំបងមួយទាក់ទិននឹងរឿងនេះ គឺការធ្វើសុខដុមនីយកម្មហិរញ្ញវត្ថុនៅ គ្រប់កំរិតនៃរដ្ឋាភិបាល: តើមានចំណូលអ្វីខ្លះដែលឃុំ ខេត្ត និងក្រសួងជំនាញនានាត្រូវប្រមូលយក ដែលមិនមែនជារបស់ រតនាគារជាតិ? តើចំណូលផ្សេងៗត្រូវបែងចែក បើកផ្តល់

---

[៥២] សូមអានឧបសម្ព័ន្ធ ខ ដែលរួមមានទាំងបញ្ជីមួយនៃច្បាប់ និងបទប្បញ្ញត្តិ ដែលមិនទាន់អនុម័ត ។

[៥៣] សូមអានផ្នែកទី ៤ ស្តីពីការកសាងគោលនយោបាយ ។

[៥៤] ក្រុមការងារបានបង្កើតឡើងនៅក្នុងក្រសួងមហាផ្ទៃ ដើម្បីព្រាងគោលនយោបាយស្តីពីច្បាប់អង្គការ និងសំរាប់ច្បាប់នេះផងដែរ ។ ប៉ុន្តែជាការគួរឱ្យសោកស្តាយ គេឃើញក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល កំពុងធ្វើព្រាងគោលនយោបាយស្តីពីច្បាប់អង្គការនេះដូចគ្នាដែរ ។ ចាំបាច់ត្រូវមានការសហការរវាងកិច្ចប្រឹងប្រែងទាំងពីរនេះក្នុងពេលនេះដែរ ។

[៥៥] ដែលតំរូវឱ្យមានតាមមាត្រា ៧៤ នៃច្បាប់រដ្ឋបាលឃុំ ។

និងរាយការណ៍យ៉ាងណាឱ្យបានសមស្រប? តើសិទ្ធិអំណាចធ្វើសេចក្តី សំរេចត្រូវមានលក្ខណៈវិមជ្ឈការប៉ុណ្ណា ទាក់ទិននឹងការប្រើប្រាស់មូលនិធិទាំងនេះ?

បញ្ហាមួយដែលងាយដោះស្រាយក្នុងរយៈពេលខ្លី គឺការតាក់តែង ប្រកាស ស្តីពីបែបបទ និងនីតិវិធីនៃការជ្រើសរើស ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការមេភូមិ, និងរបៀបរបបធ្វើការងារ និងភារកិច្ចរបស់មេភូមិ ។ ច្បាប់ និងបទប្បញ្ញត្តិនានា អាចពង្រីកបានយ៉ាងច្រើននូវសមត្ថភាពរបស់អ្នកភូមិក្នុងការយល់ដឹងពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ និង ទទួលបានដំណោះស្រាយចំពោះចំណុចព្រួយបារម្ភរបស់ពួកគេនៅកំរិតឃុំ ។ លើសពីនេះទៀត ច្បាប់ទាំងនេះ នឹងលុបបំបាត់ ចំណុចស្រពិចស្រពិលទាក់ទិននឹងគណៈកម្មការអភិវឌ្ឍន៍ភូមិដែលមានបង្កើតនៅតាមតំបន់មួយចំនួន ។

បញ្ហាសំខាន់ត្រូវដោះស្រាយមួយទៀត ដែលមានសិក្សាលំអិតក្នុងផ្នែក១០.១.១ គឺការអនុម័តអនុក្រឹត្យស្តីពីកំរៃវដ្ឋបាល សំរាប់ក្រុមប្រឹក្សាឃុំដែលអនុវត្តមុខងារទីភ្នាក់ងារផ្ទេរមកពីបណ្តាក្រសួងផ្សេងៗ ស្របតាមការតំរូវក្នុងមាត្រា៧៦ នៃ LAMC ។

បញ្ហាផ្សេងៗទៀតដែលអាចដោះស្រាយក្នុងរយៈពេលខ្លី គឺសេចក្តីណែនាំដល់ក្រុមប្រឹក្សាឃុំស្តីពី ការជួលប្រើបុគ្គលិក ទៅតាមតំរូវការ, ការតាក់តែងជីកាឃុំ, ការបង្កើតគណៈកម្មាធិការនានាដើម្បីជួយអនុវត្តភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ, ហើយនិង តួនាទី និងការទទួលខុសត្រូវរបស់ឃុំច្រើនដែលធ្វើការជាមួយគ្នា ។ នេះជាឯកសារច្បាប់សាមញ្ញៗគួរសម ដែលសព្វថ្ងៃមានតំរូវ ការខ្ពស់ក្នុងការងាររបស់អាជ្ញាធរឃុំ ហើយគ្មានហេតុផលអ្វីដែលថា គេមិនគួរតាក់តែង/អនុម័តវាចេញនៅឆ្នាំក្រោយនោះទេ ។

### ៨.៤ ការពិនិត្យឡើងវិញនូវ ច្បាប់ និងបទប្បញ្ញត្តិរបស់ NCSC

យោងតាមមាត្រា៨៨ នៃ LAMC, NCSC មានការទទួលខុសត្រូវផ្ទៀងផ្ទាត់មើលពីភាពស៊ីសង្វាក់គ្នា និងភាពផ្សារភ្ជាប់ គ្នាល្អ នៃឯកសារច្បាប់ទាំងអស់ដែលចេញដោយរដ្ឋាភិបាល ។ មាត្រា ៤ និង ៧ នៃរាជក្រឹត្យ NCSC បានបំភ្លឺ និងពង្រីកដែន សមត្ថកិច្ចថែមទៀតដោយចែងថា NCSC ត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាអន្តរក្រសួង ដើម្បីពិនិត្យមើលនូវបញ្ហារួម សំ ដៅសំរេចឱ្យបាននូវកិច្ចព្រមព្រៀងស្តីពីប្រតិបត្តិការ និងការទទួលខុសត្រូវរបស់ក្រសួងនីមួយៗ ដែលជាប់ទាក់ទងនឹងវិមជ្ឈការ, ពិនិត្យ និងរួមយោបល់លើខ្លឹមសារច្បាប់ និងបទប្បញ្ញត្តិដែលកំពុងស្ថិតនៅជាធរមាន ដើម្បីស្នើយោបល់អំពីការធ្វើវិសោធនកម្ម ឬការកែសំរួលឱ្យសមស្រប សំរាប់គាំទ្រការអនុវត្តន៍នយោបាយវិមជ្ឈការ, ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិ នានា ដែលមានការពាក់ព័ន្ធដល់ការងារឃុំ, កំណត់នូវទំនាក់ទំនងរវាងរដ្ឋាភិបាល ជាមួយរដ្ឋបាលខេត្ត ស្រុក និងក្រុមប្រឹក្សាឃុំ, និងស្នើយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិបន្ថែម ស្របតាមនីតិវិធីជាធរមាន[៥៦] ។

សិទ្ធិអំណាចដែលបានផ្តល់ឱ្យ NCSC ក្នុងបញ្ហាច្បាប់ មានលក្ខណៈទូលំទូលាយណាស់ ប៉ុន្តែបទប្បញ្ញត្តិមិនបានចែងច្បាស់ ទេពីនីតិវិធី និងកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋជាប់ទាក់ទិន ក្នុងការអនុវត្តតាមការណែនាំរបស់ NCSC ។ មាត្រា១២ នៃរាជក្រឹត្យ NCSC ចែងថា NCSC អាចស្នើអញ្ជើញរដ្ឋមន្ត្រីនៃក្រសួង ឬប្រធាននៃស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល ឱ្យចូលរួមក្នុងកិច្ចប្រជុំ NCSC ឬផ្តល់ពត៌មាន ឬផ្តល់កិច្ចសហប្រតិបត្តិជួយដល់ការងាររបស់ NCSC ។ សេចក្តីចែងនេះ ហើយនិងបទប្បញ្ញត្តិផ្សេងទៀត បានធ្វើឱ្យ NCSC ក្លាយជាអង្គភាពយុទ្ធសាស្រ្តឈានមុខគេក្នុងការផ្តល់វេទិកាពិគ្រោះយោបល់ និងសំរបសំរួល ដើម្បីទទួលបាន ការព្រមព្រៀង និងកុងសង់ស៊ុសលើបញ្ហាច្បាប់, ប៉ុន្តែយន្តការសំរាប់ដោះស្រាយទំនាស់នៅពេលវាផុសឡើងគឺមិនទាន់មានទេ ។

---

[៥៦] មាត្រា៧៣ នៃអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ ចែងថា "ក្នុងអាណត្តិរបស់ខ្លួន NCSC ទទួលខុសត្រូវក្នុងការសំរបសំរួលជាមួយក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីកំណត់ និងបែងចែកភារកិច្ចដាក់លាក់រវាងរដ្ឋបាល ថ្នាក់កណ្តាល ថ្នាក់ខេត្ត ស្រុក និងឃុំ សង្កាត់" ។ សេចក្តីចែងនេះ និងពាក្យពេចន៍នៅក្នុងរាជក្រឹត្យ NCSC បង្ហាញថា NCSC គឺមានតួនាទី ត្រូវបំពេញនៅក្នុងការកសាងគោលនយោបាយវិសហមជ្ឈការ ។

ជាបន្ថែមលើរាជក្រឹត្យ NCSC, អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងមុខងារ ទៅឱ្យក្រុមប្រឹក្សាឃុំ ក៏បានចែងពីសិទ្ធិអំណាចរបស់ NCSC ដែរ ។ មាត្រា ៥៥ ចែងថា "ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងផ្ទេរប្រតិភូកម្មអំណាច ឬការទទួលខុសត្រូវ... ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែស្នើសុំអនុញ្ញាតជាមុនពី NCSC" ។ មុខងាររបស់ NCSC នេះមិនត្រូវបានអនុវត្តទេ ។ ម្យ៉ាងទៀតសិទ្ធិអំណាចជាក់ស្តែង ឬសមត្ថភាពរបស់ NCSC ដើម្បីញ៉ាំងឱ្យមានការផ្លាស់ប្តូរនៅក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលបានតាក់តែង និងអនុម័តហើយ គឺមានចោទបញ្ហា ។

សរុបមក NCSC មិនបានបំពេញតួនាទីរបស់ខ្លួនទាក់ទិននឹងការពិនិត្យមើលឡើងវិញជាប្រព័ន្ធនូវ ច្បាប់ និងបទប្បញ្ញត្តិស្តីពីវិមជ្ឈការ ហើយនិងក្រុមប្រឹក្សាឃុំ ដោយសារ NCSC ត្រូវផ្តោតលើបញ្ហាជាអាទិភាពផ្សេងៗទៀត ។ មានការព្រួយបារម្ភពិតៗដែរថា NCSC អាចពុំមានសមត្ថភាពសំរាប់បំពេញមុខងារពិនិត្យច្បាប់ឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយទេ ។

ចំណុចចុងក្រោយគឺ តួនាទីនៃអង្គភាពអចិន្ត្រៃយ៍របស់រដ្ឋដែលមានអាណត្តិធានានូវភាពស៊ីសង្វាក់គ្នានៃច្បាប់/បទប្បញ្ញត្តិត្រូវតែបង្កើតឡើង ហើយប្រហែលនៅក្នុងក្រសួងយុត្តិធម៌ ។ រហូតដល់ពេលនោះ NCSC ត្រូវធានាថា ភារកិច្ចក្នុងអាណត្តិរបស់ខ្លួនត្រូវតែបំពេញឱ្យបាន ។ ដោយហេតុថា ការងារពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិ នៅតែមានតំរូវការនៅក្រោយអាណត្តិកំណត់ដោយច្បាប់របស់ NCSC នោះទៀត, ដូច្នេះត្រូវតែមានបទប្បញ្ញត្តិច្បាប់ដើម្បី ឬមួយពន្យាអាណត្តិរបស់ NCSC ឬមួយប្រគល់ភារកិច្ចនេះទៅឱ្យអង្គភាពមួយដែលមានលក្ខណៈអចិន្ត្រៃយ៍ជាង ។ ទោះយកជំរើសណាក៏ដោយ ក៏សេចក្តីចែងមួយចំនួនក្នុងច្បាប់/បទប្បញ្ញត្តិបច្ចុប្បន្ន នឹងត្រូវធ្វើវិសោធនកម្ម ដើម្បីដោះស្រាយបញ្ហាវត្តមានបន្តរបស់NCSC ឬការបញ្ចប់ស្ថាប័ននេះ ។

## ៩. ការកំណត់ព្រំដែនឃុំឡើងវិញ

ព្រំដែនបច្ចុប្បន្ននៃឃុំនានា វាជាប់ទាក់ទងនឹងប្រវត្តិសាស្ត្រ ហើយត្រូវបានទទួលស្គាល់ និងដាក់អនុវត្ត នៅមុនពេលអនុម័ត LAMC ។ បញ្ហាចោទ គឺឃុំមួយចំនួនតូចខ្លាំងពេកមិនអាចដំណើរការបានសមស្របជាអង្គភាពអភិបាលកិច្ចពាក់កណ្តាលស្វយ័តទេ ដូច្នេះមានការទទួលស្គាល់ថា ព្រំដែនឃុំត្រូវតែកំណត់ឡើងវិញ ។ ក្នុង LAMC មាន ២មាត្រាដែលចែងពីបញ្ហាកំណត់ព្រំដែនឃុំឡើងវិញ ។ មាត្រា ៦ ចែងថា "ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុង ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវសំរេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រីផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ" ។ សព្វថ្ងៃ មិនទាន់មានការផ្លាស់ប្តូរព្រំដែនទេ ដូច្នេះមិនទាន់ចាំបាច់មានអនុក្រឹត្យ ឬរាជក្រឹត្យស្តីពីបញ្ហានេះឡើយ ។

មាត្រា ៨ នៃ LAMC ចែងថា ក្នុងករណីដែល "ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និង ការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ដោយសារមានការផ្លាស់ប្តូរចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់, ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ នឹងមានប្រសិទ្ធិភាពនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់សំរាប់អាណត្តិក្រោយ" ។ សេចក្តីចែងនេះមានគោលដៅធានា កុំឱ្យមានការជ្រៀតជ្រែកនៅក្នុងអាណត្តិសព្វថ្ងៃរបស់ក្រុមប្រឹក្សាឃុំនានាដែលជាប់ឆ្នោត ។

ភារកិច្ចមួយនៅក្នុងអាណត្តិរបស់ NCSC គឺ "សិក្សាស្រាវជ្រាវ និងកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់... "[៥៧] ។ សេចក្តីសំរេចស្តីពីការបង្កើតអនុគណៈកម្មការនានាចំណុះឱ្យ NCSC បានបង្កើតអនុគណៈកម្មការនគររូបនីយកម្ម និងព្រំប្រទល់ឃុំសង្កាត់ ។ ភារកិច្ចរបស់អនុគណៈកម្មការពហុក្រសួងនេះ រួមមាន ការសិក្សា និងពិនិត្យឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ផ្តល់អនុសាសន៍ដើម្បីរៀបចំគំរោងកែសំរួលព្រំប្រទល់ឃុំ សង្កាត់ និងបង្កលក្ខណៈដល់ឃុំ សង្កាត់ អាចកសាងអភិវឌ្ឍន៍ឱ្យមាន

[៥៧] រាជក្រឹត្យ NCSC មាត្រា៤, ចំណុច៧ ។

ប្រសិទ្ធភាព និងចីរភាព[៥៨] ។ អនុគណៈកម្មការនេះបានប្រជុំតែ ២ដងប៉ុណ្ណោះ មកទល់សព្វថ្ងៃ ។

[៥៨] សេចក្តីសំរេចស្តីពី អនុគណៈកម្មការ NCSC មាត្រា៤ ។

នាបច្ចុប្បន្ន អនុគណៈកម្មការនេះធ្វើបានតែសេចក្តីព្រាងលិខិតមួយមាន ៣ទំព័រ ស្តីពីដំណើរការដែលត្រូវប្រើដើម្បីតាក់តែងរចនាការសិក្សា និងរៀបចំលក្ខណៈវិនិច្ឆ័យសំរាប់ការកំណត់ព្រំប្រទល់ឡើងវិញ ។ នៅមិនទាន់បានធ្វើការសិក្សាណាមួយទេ ហើយក៏គ្មានបានបង្កើតលក្ខណៈវិនិច្ឆ័យណាមួយដែរ ដូច្នេះនិយាយឱ្យស្រួលស្តាប់គឺគ្មានបានធ្វើអ្វីគួរឱ្យកត់សំគាល់ទេក្នុងពេលកន្លងមក ។ មានការឯកភាពគ្នាថា ស្របតាមសេចក្តីថែងនៅក្នុង LAMC អាណត្តិបច្ចុប្បន្នរបស់ក្រុមប្រឹក្សាឃុំគឺមិនត្រូវជ្រៀតជ្រែកទេ ហើយគោលដៅធំបំផុតគឺត្រូវកំណត់ព្រំប្រទល់ឃុំឡើងវិញឱ្យហើយ មុនការបោះឆ្នោតលើកក្រោយ ។ នេះជាបញ្ហាទាក់ទិននឹងនយោបាយ ដូច្នេះគេពិបាកកំណត់បានថាតើវានឹងមានដំណើរការយ៉ាងណា រីឯច្បាប់ និងបទប្បញ្ញត្តិបច្ចុប្បន្នក៏គ្មានផ្តល់ការណែនាំអ្វីដែរ ។

## ១០. វិសហមជ្ឈការ

នៅពេលបច្ចុប្បន្ន គេអាចធ្វើការវិភាគផ្នែកច្បាប់បានតិចតួចណាស់អំពីវិសហមជ្ឈការ ។ នៅពេលនេះ មិនទាន់មានគោលនយោបាយរបស់រដ្ឋាភិបាលច្បាស់លាស់ទេសំរាប់ណែនាំពីវិសហមជ្ឈការ ហើយឯកសារច្បាប់ដែលត្រូវមានផលប៉ះពាល់ខ្លាំងបំផុតទៅលើវិសហមជ្ឈការ ពោលគឺច្បាប់រៀបចំអង្គការស្តីពីអាជ្ញាធរខេត្ត និងស្រុក បច្ចុប្បន្នមិនទាន់បានតាក់តែងទេ ។ ទោះយ៉ាងនេះក្តី គេអាចលើកមតិជាទូទៅមួយចំនួនស្តីពីស្ថានភាពបច្ចុប្បន្ន ហើយនិងបែបបទដែលច្បាប់បានអនុម័តហើយ នឹងត្រូវអនុម័ត ឬក៏អាចត្រូវបានអនុម័ត, វាអាចប៉ះពាល់ដល់ប្រព័ន្ធច្បាប់/បទប្បញ្ញត្តិមានស្រាប់ដែលទាក់ទងនឹងវិសហមជ្ឈការ ។

នៅកម្ពុជា វិសហមជ្ឈការមានសមាសធាតុពីរគឺ វិសហមជ្ឈការនៅក្នុងក្រសួងនានា រួមទាំងការធ្វើប្រតិភូកម្មមុខងារជាភ្នាក់ងារពីក្រសួងទៅឃុំ និង វិសហមជ្ឈការពីអាជ្ញាធរថ្នាក់មជ្ឈិម/ជាតិ ទៅអាជ្ញាធរថ្នាក់ខេត្ត និងស្រុក ។

### *១០.១ វិសហមជ្ឈការក្នុងក្រសួងជំនាញ*

ដោយសារសព្វថ្ងៃមិនទាន់មានគោលនយោបាយច្បាស់លាស់ ឬច្បាប់ សំរាប់ណែនាំពីវិសហមជ្ឈការនៅតាមបណ្តាក្រសួងជំនាញ, វិសហមជ្ឈការនៅតាមក្រសួងនីមួយៗ គឺពឹងផ្អែកទាំងស្រុងទៅលើការប្តេជ្ញាចិត្តរបស់ពួកអ្នកត្រួតត្រាលើក្រសួងនោះ ។ ក្រសួងផ្សេងៗអាចពិពណ៌នាបានថា សឹងតែដូចកោះដាច់ចេញពីគ្នា ដោយមានកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលតិចតួចណាស់រវាងក្រសួងទាំងនោះ ដោយសារការប្រឹងប្រែងរក្សាអំណាច និងការត្រួតត្រាលើធនធានហិរញ្ញវត្ថុ ។ សមត្ថភាពក្នុងក្រសួងជំនាញ នៅតាមការិយាល័យថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត និងស្រុក) គឺនៅអន់ខ្សោយជាទូទៅ ។ ការធ្វើប្រតិភូកម្មទៅឱ្យថ្នាក់ក្រោមៗទាំងនេះ ច្រើនតែទាក់ទិននឹងការអនុវត្តន៍ការងារ និងភារកិច្ច តាមការចង្អុលទិស និងការត្រួតពិនិត្យពីថ្នាក់ជាតិ ដោយគ្មានបានទទួលសិទ្ធិអំណាចធ្វើសេចក្តីសំរេចលើកិច្ចការ ឬក៏សិទ្ធិត្រួតត្រាលើថវិកាដែលជាប់ទាក់ទិនទេ ហើយនេះជាទ្រង់ទ្រាយមួយដ៏ទន់ខ្សោយខ្លាំងណាស់នៃវិសហមជ្ឈការ ។

លក្ខណៈច្បាប់មួយដែលនឹងបង្កបញ្ហាទៅអនាគត នៅពេលវិសហមជ្ឈការមានការវិវត្តន៍នៅក្នុងក្រសួងជំនាញ គឺរឿងដែនសមត្ថកិច្ចត្រួតគ្នារវាងក្រសួងនានា ។ ការត្រួតគ្នាទាំងនេះ អាចមានផលប៉ះពាល់ដល់អាជ្ញាធរថ្នាក់ជាតិ ខេត្ត ស្រុក និងរហូតដល់ថ្នាក់ឃុំ ដោយបង្កើតភាពមិនច្បាស់លាស់ និងអប្រសិទ្ធិភាពនៅក្នុងវិស័យផ្តល់សេវា និងធ្វើផែនការនៅមូលដ្ឋាន ។ ឧទាហរណ៍ មួយដ៏ច្បាស់នៃការត្រួតដែនសមត្ថកិច្ច គឺអាចឃើញមាននៅក្នុងអនុក្រឹត្យនានាដែលថែងពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM), និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ។

មាត្រា៣ នៃអនុក្រឹត្យ MIME ថែងថា ភារកិច្ច និងកាតព្វកិច្ចក្រសួងនេះរួមមាន ការស្រាវជ្រាវលើបណ្តាញចែកចាយថាមពលវារីអគ្គិសនី (hydropower) និងប៉ាន់ស្មានពីសក្តានុពលរបស់វាដើម្បីកសាងគំរោងផលិតកម្មថាមពលអគ្គិសនី, និងរៀបចំ និងអនុវត្តប្រព័ន្ធចែកចាយទឹកស្អាតនៅក្នុងទីក្រុង និងតំបន់ទីប្រជុំជន ។ មាត្រា៣ នៃអនុក្រឹត្យ MOWRAM ថែងថា ភារកិច្ច និង

កាតព្វកិច្ចក្រសួងនេះរួមមាន ការរៀបចំផែនការសំរាប់ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការអភិរក្សធនធានទឹក ដើម្បីបំរើដល់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅតាមតំបន់ជនបទ និងទីក្រុង ។ លើសពីនេះ មាត្រា១១ ចែងថា នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹកនៅក្នុង MOWRAM មានភារកិច្ចរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រដើម្បីបំរើគោលដៅអភិវឌ្ឍន៍ផ្សេងៗ រួមមាន វារីអគ្គិសនី ការគ្រប់គ្រងទឹកជំនន់ និងការស្រោចស្រព ហើយគំរោងនានាដែលបំរើផលិតកម្មវារីអគ្គិសនី ត្រូវមានអាទិភាពទី១ ។ MIME និង MOWRAM មានដែនសមត្ថកិច្ចត្រួតគ្នាទៅលើ ការផ្គត់ផ្គង់ទឹកស្អាត និងបញ្ហាផលិតកម្មវារីអគ្គិសនី ។ បញ្ហានេះបានចោទបញ្ហារួចហើយនៅក្រុងព្រះសីហនុ ដោយគំរោងទីជម្រាលក្បាលឆាយ កំពុងជួបការលំបាកក្នុងការកំណត់ថា តើក្រសួងណាទទួលខុសត្រូវលើបញ្ហាផ្សេងៗទាក់ទិននឹងការអភិវឌ្ឍន៍អាងទឹក និងប្រព័ន្ធសំអាតទឹក ដើម្បីផ្គត់ផ្គង់ទឹកស្អាតដល់ក្រុងព្រះសីហនុនៅពេលអនាគត ។

នៅអនាគត ការត្រួតដែនសមត្ថកិច្ចគ្នារវាងក្រសួងជំនាញផ្សេងៗ គឺត្រូវតែដោះស្រាយ ។ រដ្ឋាភិបាលបានបង្ហាញថាខ្លួនមានសមត្ថភាពដោះស្រាយការត្រួតគ្នាទាំងនេះតាមការចេញច្បាប់នៅពេលឱកាសមកដល់ ។ ការអនុម័តច្បាប់ស្តីពីព្រៃឈើនាពេលថ្មីៗ បានលុបបំបាត់ការត្រួតសមត្ថកិច្ចរវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និង MIME ។ មាត្រា១០៧ នៃច្បាប់ស្តីពីព្រៃឈើ ចែងថា "រោងចក្រ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើទាំងឡាយដែលបានដែលបានបង្កើតឡើង និងកំពុងដំណើរការក្រោមប្រកាសអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ។ ការត្រួតគ្នាទាំងនេះ ក៏អាចជំរះចេញបានដែរនៅក្នុងគណៈរដ្ឋមន្ត្រី តាមរយៈការធ្វើវិសោធនកម្មលើអនុក្រឹត្យនានាស្តីពីមុខងារ និងតួនាទីនៃក្រសួងផ្សេងៗ ។

ការសំរបសំរួល កិច្ចសហប្រតិបត្តិការ និងការត្រួតពិនិត្យ រវាងមន្ទីរជំនាញនានានៅក៏រិតខេត្ត និងស្រុក អាចដោះស្រាយបានយ៉ាងសក្តិសិទ្ធិដោយអភិបាលខេត្ត និងសាលាខេត្ត ប៉ុន្តែត្រូវមានការធ្វើប្រតិភូកម្មសិទ្ធិអំណាចមួយយ៉ាងច្បាស់ ដែលលក្ខណៈជាកាតព្វកិច្ច និងទទួលបានការគោរពតាមពីសំណាក់ក្រសួងជំនាញនានា ។ បញ្ហានេះនឹងមានបកស្រាយលំអិតថែមទៀត នៅក្នុងផ្នែក១០.២ ស្តីពីវិសហមជ្ឈការខេត្ត និងស្រុក ។

បញ្ហាធ្ងន់ធ្ងរមួយដែលត្រូវទទួលស្គាល់ និងដោះស្រាយ គឺការធ្វើប្រតិភូកម្មមុខងារភ្នាក់ងារពីក្រសួងជំនាញនានា ទៅឱ្យក្រុមប្រឹក្សាឃុំ ។ ការបារម្ភចំបងៗគឺ ការផ្តល់មូលនិធិដ៏សមស្របទៅឱ្យក្រុមប្រឹក្សាឃុំដើម្បីអនុវត្តមុខងារទាំងនេះ, សមត្ថភាពក្រុមប្រឹក្សា ដើម្បីអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្ម, និងការបន្សុីគ្នាយ៉ាងល្អនូវ វិធាន និងបទប្បញ្ញត្តិដែលប្រគល់មុខងារផ្សេងៗ ជាមួយនឹង ច្បាប់/បទប្បញ្ញត្តិនានាដែលមានស្រាប់ ។

### *១០.១.១ ការប្រគល់មុខងារភ្នាក់ងារទៅឱ្យក្រុមប្រឹក្សាឃុំ*

LAMC បានកំណត់ដោយផ្ទាល់នូវការប្រគល់មុខងារភ្នាក់ងារដោយរដ្ឋ ឬក្រសួងនានា ទៅឱ្យក្រុមប្រឹក្សាឃុំ ។ មាត្រា៤២ នៃ LAMCចែងថា ឃុំមាន "តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ" ។ មាត្រា ៤៤ បញ្ជាក់បន្ថែមលើបញ្ហានេះដោយចែងថា អាជ្ញាធររដ្ឋ ឬក្រសួងជំនាញនានា "អាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សំភារៈ និងថវិកាសំរាប់អនុវត្ត" ។ ចំណុចសំខាន់គួរកត់សំគាល់ក្នុងសេចក្តីចែងទាំងនេះ គឺការធ្វើប្រតិភូកម្មសិទ្ធិអំណាច ដែលបើសិនជាបានធ្វើជាក់ស្តែងមែន ត្រូវតែមានអមដោយការកសាងសមត្ថភាពដ៏ចាំបាច់ និងការផ្តល់ថវិកាដើម្បីអនុវត្តការធ្វើប្រតិភូកម្មនេះឱ្យបានសមស្រប ។ លើសពីនេះទៀត មាត្រា៥៥ នៃអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ ចែងថា "ក្រសួង ឬស្ថាប័នមួយរបស់រដ្ឋាភិបាលដែលមានបំណងផ្ទេរអំណាច ឬការទទួលខុសត្រូវ... ទៅឱ្យក្រុមប្រឹក្សាឃុំ ត្រូវតែស្នើសុំអនុញ្ញាតជាមុនពី NCSC" ។

មាត្រា៧៦ នៃ LAMC ដោះស្រាយបញ្ហាបែងចែកថវិកាសំរាប់អនុវត្តមុខងារភ្នាក់ដោយចែងថា ឃុំនានាមានសិទ្ធិទទួលបាននូវប្រាក់កំរៃចំពោះការអនុវត្តន៏មុខងារភ្នាក់ងារ ជាបន្ថែមពីលើចំណូលធម្មតារបស់ឃុំដែលបានមកពីថវិកាជាតិ ។ រដ្ឋាភិបាល ឬក្រសួងជាប់ទាក់ទិន ត្រូវផ្តល់កំរៃសមស្របដល់ឃុំដែលបានអនុវត្តតួនាទីជាភ្នាក់ងារ ហើយបើការធ្វើប្រតិភូកម្មមុខងារនេះមានលក្ខណៈជាអចិន្ត្រៃយ៏ រដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលវែងសំរាប់ទ្រទ្រង់ដល់ការធ្វើប្រតិភូកម្មឱ្យឃុំ ។ វិធានលំអិតទាក់ទិននឹងការផ្តល់កំរៃទាំងនេះទៅឱ្យឃុំ ត្រូវកំណត់ឡើងដោយអនុក្រឹត្យ (ប៉ុន្តែអនុក្រឹត្យនេះមិនទាន់បានតាក់តែងនៅឡើយទេ) ។

កន្លងមក មានការធ្វើប្រតិភូកម្មមុខងារភ្នាក់តិចតួចណាស់ទៅឱ្យក្រុមប្រឹក្សាឃុំ ។ ករណីពិសេសមួយក្នុងបញ្ហានេះគឺការអនុមតិ អនុក្រឹត្យសម្បទានដីសង្គមកិច្ច ដែលមានការធ្វើប្រតិភូកម្មមុខងារចំបងមួយពី MLMUPC ទៅឱ្យក្រុមប្រឹក្សាឃុំ និងដែលឆ្លុះបញ្ចាំងពីបញ្ហាមួយចំនួននៅក្នុងប្រព័ន្ធបច្ចុប្បន្ន[៥៩] ។ អនុក្រឹត្យនេះបង្កើតប្រព័ន្ធមួយនៃកម្មវិធីសម្បទានដីសង្គមកិច្ចនៅមូលដ្ឋាន ដែលក្រុមប្រឹក្សាឃុំទទួលខុសត្រូវ ចាប់ផ្តើមដំណើរការ, បង្កើតផែនការសម្បទានដីសង្គមកិច្ច, អនុវត្តផែនការ, និងពិនិត្យផែនការឡើងវិញប្រចាំឆ្នាំ ។ ក្នុងការរៀបចំផែនការ ក្រុមប្រឹក្សាត្រូវកំណត់ពីដីដែលត្រូវទុកសំរាប់ប្រើប្រាស់ក្នុងរឿងនេះ និងរៀបរាប់ឱ្យច្បាស់ថា តើត្រូវប្រើប្រាស់ដីយ៉ាងដូចម្តេច តើហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះដែលគេនឹងត្រូវការជាចាំបាច់ ឬក៏ដែលមានស្រាប់ហើយ ដើម្បីអនុវត្តផែនការឱ្យបានសមស្រប ។ ត្រូវបញ្ជាក់ផងដែរពី អ្នកដែលនឹងត្រូវទទួលបានដីនៅក្នុងផែនការនេះ (ដំណើរការដាក់ពាក្យសុំ និងជ្រើសរើសអ្នកត្រូវទទួលបានដី គឺក្រុមប្រឹក្សាឃុំត្រូវធ្វើឱ្យហើយ មុននឹងដាក់ស្នើផែនការនេះឡើងដើម្បីសុំការយល់ព្រមពីគណៈកម្មការចែកចាយការប្រើប្រាស់ដីខេត្ត/ក្រុង), នីតិវិធីលំអិតដែលត្រូវប្រើដើម្បីកំណត់ថាអ្នកណាគួរទទួលបានដី, ខ្លឹមសារត្រួសៗនៃផែនការ និងលក្ខខណ្ឌសំរាប់ការបែងចែក និងការកាន់កាប់ដី, ការវាយតំលៃពីផលប៉ះពាល់ខាងបរិស្ថាន និងសង្គមកិច្ច, ព្រមទាំងត្រូវបំពេញតាមការតំរូវផ្សេងៗដែលកំណត់ឡើងដោយ គណៈកម្មការជាតិសំរាប់សម្បទានដីសង្គមកិច្ច[៦០] ។

ដោយមិនចាំបាច់ចូលដល់ចំណុចលំអិតផង គេអាចមើលឃើញច្បាស់ថា ដំណើរការនេះស្មុគស្មាញណាស់ដែលទាមទារធនធានយ៉ាងច្រើនជា ពេលវេលា ថវិកា និងសមត្ថភាព ។ អាចនៅមានបញ្ហាចោទច្រើនទៀតទាក់ទិនទៅនឹងបែបបទដែលដំណើរការធ្វើផែនការ និងអនុម័តយល់ព្រមដែលមានចែងនៅក្នុងអនុក្រឹត្យសម្បទានដីសង្គមកិច្ច ត្រូវផ្សារភ្ជាប់ទៅនឹងដំណើរការធ្វើផែនការអភិវឌ្ឍន៏របស់ឃុំ ។ អនុក្រឹត្យមិនបានចែងពីបញ្ហាកំរៃភ្នាក់ងារ ឬការកសាងសមត្ថភាពទេ ហើយ NCSC ក៏មិនបានពិនិត្យមើលអនុក្រឹត្យនេះឡើងវិញដែរថា តើវាស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់/បទប្បញ្ញត្តិផ្សេងៗទៀតឬទេ[៦១] ។

បើសិនមានក្រសួងជំនាញជាច្រើនចាប់ផ្តើមផ្តល់មុខងារភ្នាក់ងារដ៏ច្រើនៗទៅឱ្យក្រុមប្រឹក្សាឃុំ ប្រព័ន្ធការងារអាចជួបវិបត្តិគាំងដំណើរការ ដោយសារកង្វះសមត្ថភាព កង្វះមូលនិធិ ការបន្សុីបញ្ចូលគ្នាមិនបានល្អ ឬការប្រទាំងប្រទើសគ្នាជាមួយច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ ។ NCSC និងក្រសួងមហាផ្ទៃ ត្រូវតែពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ននូវការធ្វើប្រតិភូកម្មទាំងនេះ ហើយអនុក្រឹត្យស្តីពីកំរៃ ភ្នាក់ងារ ត្រូវតែដាក់អនុវត្ត ។

---

[៥៩] អនុក្រឹត្យ បានបង្កើតយន្តការមួយសំរាប់ឱ្យរដ្ឋាភិបាលអាចផ្តល់ "ដីឯកជនរបស់រដ្ឋ" ជាអំណោយដល់មេគ្រួសារក្រីក្រនានាដែលបំពេញបានតាមលក្ខខណ្ឌកំណត់, ហើយយោងតាមកាលៈទេសៈជាក់ស្តែង កំពុងខ្វះខាតដីសំរាប់ស្នាក់នៅ ឬធ្វើកសិកម្មតាមគ្រួសារ ។ សម្បទានដីសង្គមកិច្ច ផ្តល់តែសិទ្ធិប្រើប្រាស់ និងកាន់កាប់ប៉ុណ្ណោះក្នុងដំណាក់កាលដំបូង ប៉ុន្តែវាអាចក្លាយជាសិទ្ធិជាម្ចាស់កម្មសិទ្ធិមានប័ណ្ណកម្មសិទ្ធិ បើសិនអ្នកទទួលបានដីអាចបំពេញតាមលក្ខណៈវិនិច្ឆ័យដែលកំណត់នៅក្នុងកម្មវិធីអស់រយៈពេល ៥ឆ្នាំ។

[៦០] មាត្រា៩, អនុក្រឹត្យសម្បទានដីសង្គមកិច្ច ។

[៦១] សូមអានផ្នែក៨.៤ ស្តីពីការពិនិត្យច្បាប់ និងបទប្បញ្ញត្តិដោយ NCSC ឡើងវិញ ។

## *១០.២ វិសហមជ្ឈការនៅថ្នាក់ខេត្ត និងស្រុក*

ដូចបានលើករួចហើយ ច្បាប់រៀបចំអង្គការស្តីពីអាជ្ញាធរខេត្ត និងស្រុក មិនទាន់បានតាក់តែងទេ ។ ដោយសារពុំមានឯកសារច្បាប់ដ៏សំខាន់នេះ រចនាសម្ព័ន្ធបណ្តោះអាសន្នជាច្រើនត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់គោលគំនិតនៃវិសហមជ្ឈការ និងវិមជ្ឈការ ដូចជា ប្រកាសអភិបាលខេត្ត និងប្រកាស PRDC ជាដើម ។

ក្រៅពីឯកសារច្បាប់ទាំងពីរដែលទើបបានបង្ហាញ ក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងសកម្មភាពនៅកំរិតខេត្ត និងស្រុក គឺនៅខ្វះខាត និងចាស់ហួសសម័យខ្លះហើយ ។ ច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗដែលកំពុងអនុវត្តសព្វថ្ងៃមានជាអាទិ៍ ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធអង្គការចាត់តាំងនៃរដ្ឋបាលខេត្ត-ក្រុង ដែលអនុម័តនៅឆ្នាំ១៩៩៤, និង ច្បាប់ស្តីពី ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង ដែលអនុម័តនៅឆ្នាំ១៩៩៨ (ច្បាប់ថវិកាខេត្ត) ។

នៅពេលនេះ មានការភាន់ច្រឡំមួយចំនួននៅក្នុងបណ្តាអង្គភាពខាងគោលនយោបាយពីរឿងថា តើអ្នកណាទទួលបន្ទុកតាក់តែងគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីវិសហមជ្ឈការ និង ច្បាប់រៀបចំអង្គការ ។ CAR ហាក់ដូចយល់ឃើញថា រឿងនេះគឺជាការទទួលខុសត្រូវរបស់ខ្លួន ។ ក្នុងពេលជាមួយគ្នា ក្រសួងមហាផ្ទៃបានបង្កើតក្រុមការងារមួយដើម្បីរៀបចំឯកសារគោលនយោបាយ ហើយបច្ចុប្បន្នកំពុងពិគ្រោះយោបល់ជាមួយបណ្តាខេត្ត ដោយមានផែនការកសាងឯកសារគោលនយោបាយឱ្យបាននៅឆ្នាំ២០០៤, តាក់តែងច្បាប់រៀបចំអង្គការឱ្យចប់សព្វគ្រប់នៅឆ្នាំ២០០៥ និងអនុមតិវាចេញនៅឆ្នាំ២០០៦ ឱ្យបានមុនការបោះឆ្នោតឃុំលើកក្រោយនៅដើមឆ្នាំ២០០៧ ។

បច្ចុប្បន្ននេះ មានការពិភាក្សាយ៉ាងច្រើនក្នុងជួររដ្ឋាភិបាលអំពីតួនាទីរបស់អាជ្ញាធរខេត្តនៅក្នុងវិសហមជ្ឈការ និងការសំរបសំរួលតាមខ្សែផ្តេកជាមួយក្រសួងនានា ។ ប្រហែលនឹងមានបង្កើតក្នុងរូបភាពណាមួយនូវ អង្គភាពសំរបសំរួលពហុក្រសួងដឹកនាំដោយអភិបាលខេត្ត គឺស្រដៀងគ្នានឹង ExCom PRDC សព្វថ្ងៃ ប៉ុន្តែរឿងថា តើអភិបាលខេត្តនឹងទទួលបានសិទ្ធិអំណាចជាក់ស្តែងប៉ុណ្ណាសំរាប់ត្រួតពិនិត្យ និងធ្វើសេចក្តីសំរេចអារកាត់ គឺមិនអាចទស្សន៍ទាយបានទេនៅពេលនេះ ។ ការសំរេចចុងក្រោយ ក្នុងបញ្ហានេះ វាជាប់ទាក់ទិននឹងឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តចំពោះវិសហមជ្ឈការរបស់រដ្ឋាភិបាល ។ អ្វីដែលច្បាស់លាស់ គឺការអនុមតិច្បាប់រៀបចំអង្គការនឹងមានផលប៉ះពាល់ទៅលើច្បាប់/បទប្បញ្ញត្តិមានស្រាប់ដែលជាប់ទាក់ទងនឹងវិសហមជ្ឈការ ហើយដំណើរការនេះត្រូវមានការពិចារណា និងការសំរបសំរួលយ៉ាងយកចិត្តទុកដាក់ ។

ច្បាប់រៀបចំអង្គការ នឹងត្រូវតាក់តែងឡើងដោយផ្សារភ្ជាប់ជាមួយ ការលុបចោល ការធ្វើវិសោធនកម្ម និងការអនុមតិច្បាប់/បទប្បញ្ញត្តិផ្សេងៗទៀត ។ ឧទាហរណ៍ ច្បាប់រៀបចំអង្គការ ត្រូវគិតគូរអំពីរចនាសម្ព័ន្ធហិរញ្ញវត្ថុនៅកំរិតខេត្ត និងស្រុក, ហើយតាមនេះ ច្បាប់ថវិកាខេត្តឆ្នាំ១៩៩៨ ត្រូវតែកែតំរូវឡើងវិញ, រីឯច្បាប់ស្តីពីប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំនូលពន្ធ ចំនូលមិនមែនពន្ធ និងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំ ត្រូវតែតាក់តែងតាមបែបបទណាមួយដែលមិនប្រឆាំងគ្នាជាមួយឯកសារច្បាប់ផ្សេងៗទៀត ។ ប្រកាសអភិបាលខេត្តសំរាប់ជួយគាំទ្រឃុំសព្វថ្ងៃ នឹងត្រូវដាក់បញ្ចូលទៅក្នុងច្បាប់រៀបចំអង្គការ ហើយប្រកាស PRDC ក៏ដូច្នោះដែរ[៦២] ។ ម្យ៉ាងទៀត LAMC និង ច្បាប់/បទប្បញ្ញត្តិសំរាប់គាំទ្រវា នឹងត្រូវធ្វើវិសោធនកម្មដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលនៅកំរិតខេត្ត ស្រុក ដែលជាលទ្ធផលនៃការអនុមតិច្បាប់រៀបចំអង្គការ ប៉ុន្តែវិសោធនកម្មទាំងនេះត្រូវធ្វើព្រមគ្នានឹងការតាក់តែងនិងអនុមតិច្បាប់រៀបចំអង្គការ ។

បើសិនច្បាប់រៀបចំអង្គការត្រូវតាក់តែងនៅឆ្នាំ២០០៥ ហើយបញ្ជូនទៅរដ្ឋសភាដើម្បីអនុម័តនៅឆ្នាំ២០០៦ ដូច្នេះច្បាប់

[៦២] ប្រកាសទាំងពីរនេះនឹងអស់សុពលភាពនៅពេល ច្បាប់រៀបចំអង្គការ ត្រូវបានអនុម័តហើយ ។

និងបទប្បញ្ញត្តិឯទៀតៗ ក៏ត្រូវធ្វើវិសោធកម្មនៅពេលនោះដែរ ដើម្បីឱ្យមានស្រេចបាច់នូវប្រព័ន្ធច្បាប់/បទប្បញ្ញត្តិស៊ីសង្វាក់គ្នាល្អ សំរាប់ដាក់អនុវត្តនៅពេលចាប់ផ្តើមអាណត្តិបន្ទាប់នៃក្រុមប្រឹក្សាឃុំនាឆ្នាំ២០០៧។ ដូច្នេះនឹងមានការងារច្រើនក្នុងពេលខាងមុខ សំរាប់គណៈរដ្ឋមន្ត្រី (ពិនិត្យឡើងវិញ និងអនុម័តច្បាប់ ឬវិសោធនកម្មលើច្បាប់ មុនពេលដាក់ជូនទៅរដ្ឋសភា, ហើយនិងពិនិត្យឡើងវិញ និងអនុម័តអនុក្រឹត្យថ្មីៗ ព្រមទាំងធ្វើវិសោធនកម្មអនុក្រឹត្យដែលមានស្រាប់នានា), សំរាប់រដ្ឋសភា និងក្រសួងជាប់ពាក់ព័ន្ធជាច្រើនទៀត[៦៣] ។ បើសិនដំណើរការតាក់តែង និងធ្វើវិសោធនកម្ម មិនបានសំរបសំរួល និងអនុវត្តសមស្របទេ វាអាចមានបញ្ហាទំនាស់ និងភាពមិនស៊ីសង្វាក់គ្នាធំៗក្នុងឯកសារច្បាប់ ដែលនឹងបង្កការច្របូកច្របល់ និងការពិបាកដល់ការអនុវត្តន៍នៅក្នុងអាណត្តិក្រោយ ។ ភាពធ្ងន់ធ្ងរនៃបញ្ហានេះ ហើយនិងទំហំកិច្ចប្រឹងប្រែងដែលត្រូវដាក់បញ្ចូលទៅក្នុងដំណើរការនេះ គឺត្រូវតែបញ្ជាក់ហើយបញ្ជាក់ទៀតទើបបាន ។

## ១១. កំណែទំរង់តុលាការជាប់ទាក់ទងនឹងវិមជ្ឈការ

អំណាចតុលាការ ត្រូវគេមើលឃើញថា នៅទន់ខ្សោយជាងគេក្នុងចំណោមអំណាចទាំង ៣ នៅកម្ពុជា : សមត្ថភាពរបស់ប្រព័ន្ធតុលាការនៅទាបខ្លាំងណាស់, ប្រជាជនមានទំនុកចិត្តតិចតួចបំផុតថា តុលាការអាចដោះស្រាយបានដោយសមស្របនូវការព្រួយបារម្ភរបស់ខ្លួន, គ្មានការបែងចែកដាច់រវាងអំណាចតុលាការ និងអំណាចនីតិប្រតិបត្តិ, អំពើពុករលួយក្នុងប្រព័ន្ធតុលាការត្រូវបានគេរាយការណ៍ថា មានកំរិតខ្ពស់... ។ រដ្ឋាភិបាលបានប្តេជ្ញាពង្រឹងអំណាចនេះ និងបានឈានទៅមុខមួយជំហានដ៏សំខាន់តាមការអនុមតិគោលនយោបាយកំណែទំរង់ប្រព័ន្ធតុលាការ និងច្បាប់ នៅឆ្នាំ២០០៣ ។ គោលនយោបាយនេះមានគោលដៅជាយុទ្ធសាស្ត្រធំៗ ៧:

១. កែលំអកិច្ចការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល

២. ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់

៣. ផ្តល់ពតិមានផ្នែកច្បាប់ និងតុលាការ

៤. លើកកំពស់គុណភាពដំណើរការតាមផ្លូវច្បាប់ និងសេវាកម្មជាប់ទាក់ទិន

៥. ពង្រឹងសេវាកម្មតុលាការ គឺមាន អំណាចតុលាការ និងសេវាកម្មអយ្យការ

៦. ដាក់បញ្ចូលនូវវិធីផ្សេងៗទៀតសំរាប់ដោះស្រាយទំនាស់

៧. ពង្រឹងបណ្តាស្ថាប័នខាងច្បាប់ និងតុលាការ ក្នុងការបំពេញអាណត្តិរបស់ខ្លួន ។

ក្នុងកំណែទំរង់តុលាការ មាន ៣វិស័យដែលអាចមានផលប៉ះពាល់ខ្លាំងដល់វិមជ្ឈការ: ការផ្តល់លទ្ធភាពទទួលបានពតិមានខាងច្បាប់, ការផ្តល់មធ្យោបាយច្បាស់លាស់ឱ្យក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅក្នុងឃុំ ដើម្បីដើម្បីប្តឹងតវ៉ានឹងសេចក្តីសំរេចផ្នែករដ្ឋបាល និងការបង្កើតយន្តការសមស្របមួយសំរាប់ពិនិត្យឡើងវិញនូវច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នា និងចៀសវាងទំនាស់ ។

នៅពេលនេះ មានតំរូវការពិតៗដើម្បីកែលំអការទទួលបានពតិមានពីអ្វីដែលច្បាប់និងបទប្បញ្ញត្តិផ្សេងៗបានចែងជាក់ស្តែង ។ មន្ត្រីរាជការនៅកំរិតខេត្ត ស្រុក និងឃុំ ជារឿយៗមិនសូវបានដឹងពីខ្លឹមសារនៃច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងដល់

[៦៣] សូមអានផ្នែក៥.១ ដែលបូកសរុបត្រួសៗពីដំណើរការដ៏វែងជាប់ទាក់ទិននឹងការអនុមតិច្បាប់ និង អនុក្រឹត្យ ។

តួនាទី សិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួនទេ ហើយប្រជាពលរដ្ឋធម្មតាក៏មានស្ថានភាពដូច្នេះដែរ ។ ការកសាងសមត្ថភាពក្នុងវិស័យច្បាប់ គួរមានអាទិភាពជាបន្ទាន់ក្នុងរយៈពេលខ្លី មធ្យម និងវែង ដោយសារប្រព័ន្ធច្បាប់នៅកម្ពុជានឹងមានការផ្លាស់ប្តូរឥតឈប់ឈរ និងរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ ។

គួរដាក់អនុវត្តប្រព័ន្ធច្បាស់លាស់មួយ ដែលតាមនេះក្រុមប្រឹក្សាឃុំអាចប្តឹងតវ៉ាសេចក្តីសំរេចខាងរដ្ឋបាលរបស់អង្គភាពរដ្ឋផ្សេងៗដែលប៉ះពាល់ដល់ពួកគេ ។ ប្រព័ន្ធនេះ គួរមានបញ្ចូលទាំងនីតិវិធីប្តឹងតវ៉ាតាមផ្លូវរដ្ឋបាលនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល, និងនីតិវិធីប្តឹងតវ៉ាតាមផ្លូវតុលាការ បើសិនការព្រួយបារម្ភរបស់ពួកគេមិនត្រូវបានដោះស្រាយនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល។ នេះជាប្រព័ន្ធដ៏ធំទូលាយមួយរបស់រដ្ឋាភិបាលដែលត្រូវបង្កើតឡើង និងដែលទាមទារនូវឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តលះបង់ពេលវេលា និងថាមពល ។

យន្តការអចិន្ត្រៃយ៍សំរាប់ពិនិត្យច្បាប់ឡើងវិញ ចាំបាច់ត្រូវតែបង្កើតឡើង ។ ក្នុងពេលសព្វថ្ងៃ NCSC មានអាណត្តិពិនិត្យ ឡើងវិញនូវច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ដែលមានផលប៉ះពាល់ទៅលើ តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ ប៉ុន្តែអាណត្តិនេះ មិនបានអនុវត្តទេ ហើយ NCSC ក៏មិនមែនជារចនាសម្ព័ន្ធអចិន្ត្រៃយ៍ដែរ ។ លើសពីនេះ មានការចោទសំនួរជាក់ស្តែងមួយថាតើ NCSC មានសមត្ថភាពអនុវត្តតួនាទីពិនិត្យច្បាប់ឡើងវិញជាលក្ខណៈបច្ចេកទេសឬទេ។ ហើយនៅទីបំផុត អង្គភាពអចិន្ត្រៃយ៍ក្នុងជួររដ្ឋាភិបាលដែលមានសមត្ថភាពអនុវត្តមុខងារនេះ គឺនឹងត្រូវបង្កើតជាចាំបាច់ ដែលប្រហែលជានៅក្នុងក្រសួងយុត្តិធម៌ ។

## ១២. ការគ្រប់គ្រងធនធានធម្មជាតិ/ការប្រើប្រាស់ដី និងវិមជ្ឈការ

រចនាសម្ព័ន្ធបច្ចុប្បន្ននៃវិមជ្ឈការ បានគាំទ្រដល់គោលគំនិតថា ក្រុមប្រឹក្សាឃុំនឹងដើរតួនាទីមួយនៅក្នុងការប្រើប្រាស់ ដី និងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ (NREM), ថ្វីបើក្នុងករណីជាច្រើនក្រុមប្រឹក្សាអនុវត្តបានតែត្រឹមតួនាទីសំរបសំរួល រីឯសិទ្ធិអំណាចធ្វើសេចក្តីសំរេចជាក់ស្តែងគឺស្ថិតនៅតាមបណ្តាក្រសួងដែលមានសមត្ថកិច្ចនៅលើវិស័យដ៏ជាក់លាក់នានា ។ គំរោងសាកល្បងនានាដែលផ្តោតលើការបញ្ជ្រាបការងារគ្រប់គ្រងប្រើប្រាស់ដី/ធនធានធម្មជាតិ ទៅក្នុងដំណើរការអភិវឌ្ឍន៍ឃុំ សព្វថ្ងៃកំពុងអនុវត្ត និងអភិវឌ្ឍន៍ ដោយកម្មវិធីសិលា ។ ខាងក្រោមនេះ គឺជាការពិនិត្យមើលត្រួសៗពីអ្វីៗដែលមានស្រាប់ សំរាប់គាំទ្រដល់កិច្ចប្រឹងប្រែងនេះ ។

### ១២.១ LAMC និង ច្បាប់និងបទប្បញ្ញត្តិដែលទាក់ទិននានា

LAMC និង ច្បាប់/បទប្បញ្ញត្តិដែលទាក់ទិននានា បានបង្កើតឱកាសមួយដ៏ច្បាស់លាស់មិនអាចប្រកែកបាន សំរាប់ការចូលពាក់ព័ន្ធរបស់ក្រុមប្រឹក្សាឃុំនៅក្នុងសកម្មភាពប្រើប្រាស់ដី/NREM ដោយមានការចូលរួម, ហើយដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ គឺជាមូលដ្ឋានដ៏រឹងមាំនៃឱកាសនេះ ។ ច្បាប់និងបទប្បញ្ញត្តិសំរាប់ការបង្កើត ការអនុវត្តន៍ ការវាយតម្លៃ (តាមរយៈការរៀបចំរបាយការណ៍ប្រចាំឆ្នាំ) និងការកែតំរូវតាមក្រោយនូវផែនការអភិវឌ្ឍន៍, បានបង្កើតរចនាសម្ព័ន្ធមួយដ៏ច្បាស់លាស់ដែល (បើសិនអនុវត្តបានត្រឹមត្រូវ) នឹងញ៉ាំងឱ្យមានសកម្មភាពដ៏មានសន្ទុះ និងមានប្រយោជន៍ពិតៗ នៃការធ្វើផែនការ NREM/ ការប្រើប្រាស់ដី ដោយមានការចូលរួមនៅកំរិតឃុំ និងភូមិ ។ លក្ខណៈដែលច្បាប់/បទប្បញ្ញត្តិមានសេចក្តីចែងយ៉ាងរឹងប៉ឹងពីការ ចូលពាក់ព័ន្ធយ៉ាងសកម្មរបស់ប្រជាជនក្នុងឃុំ សង្គមស៊ីវិល និងពួកអ្នកជាប់ពាក់ព័ន្ធដែលការយកចិត្តទុកដាក់នៅក្នុងដំណើរទាំង មូលនៃការធ្វើផែនការអភិវឌ្ឍន៍ឃុំ គឺបានបញ្ជាក់គាំទ្រដល់សេចក្តីសន្និដ្ឋាននេះ ។

ក្រៅពីតួនាទីដូចខាងលើ

ក្រុមប្រឹក្សាឃុំត្រូវបានប្រគល់រួចហើយនូវសិទ្ធិអំណាចតាមផ្លូវច្បាប់ដែលអាចយកទៅប្រើប្រាស់ដើម្បីចេញបទបញ្ជាទាក់ទិននឹងសកម្មភាពធ្វើផែនការប្រើប្រាស់ដី/NREM ។ ឃុំក៏ទទួលបានយន្តការផ្តល់ហិរញ្ញប្បទានមួយចំនួនសំរាប់អភិវឌ្ឍន៍សកម្មភាពនានា ដូចជា មូលនិធិឃុំជាដើម ដែលធានាថា នឹងមានថវិកាគ្រប់គ្រាន់សំរាប់សកម្មភាពអនុវត្តន៍ ។ ប៉ុន្តែគួរឱ្យសោកស្តាយ យន្តការសំរាប់ផ្តល់មូលនិធិជាច្រើនទាមទារនូវការអភិវឌ្ឍន៍ឱ្យបានសមស្របមួយក៏រិតទៀត (ដូចជាច្បាប់ស្តីពីប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំនូលពន្ធ ចំនូលមិនមែនពន្ធ និងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំជាដើម) ទើបអាចប្រើប្រាស់បានយ៉ាងពេញលេញនូវសិទ្ធិអំណាចធ្វើហិរញ្ញប្បទានដល់សកម្មភាពធ្វើផែនការប្រើប្រាស់ដី/NREMនេះ[៦៤] ។

### ១២.២ ច្បាប់ភូមិបាល និង ច្បាប់និងបទប្បញ្ញត្តិជាប់ទាក់ទិន

ច្បាប់ភូមិបាល និងបទប្បញ្ញត្តិដែលត្រូវបានអនុម័តក្រោយៗមកទៀត បានបង្កើតឱកាសល្អបន្ថែមសំរាប់ការចូលពាក់ព័ន្ធរបស់ក្រុមប្រឹក្សាឃុំនៅក្នុងការធ្វើផែនការប្រើប្រាស់ដី/NREM តាមការបញ្ជាក់បំភ្លឺពីបញ្ហាផ្សេងៗជាប់ទាក់ទងនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ, ការកំណត់ទ្រព្យសម្បត្តិឃុំ ដែលត្រូវបានគ្រប់គ្រង និងនៅទីបំផុតក្លាយជាកម្មសិទ្ធិរបស់សហគមន៍ប្រជាជនដើម, សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច, នីតិវិធីសំរាប់បង្កើតផែនទីសុរិយោដី ចុះបញ្ជីដី និងដោះស្រាយទំនាស់ដី ។ បញ្ហាទាំងអស់នេះអាចដាក់បញ្ចូលនៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ ប៉ុន្តែវិស័យខ្លះត្រូវមានការចូលពាក់ព័ន្ធដោយផ្ទាល់នៃក្រុមប្រឹក្សាឃុំ ។

ក្រុមប្រឹក្សាឃុំមានតួនាទីត្រូវបំពេញដោយផ្ទាល់នៅក្នុងនីតិវិធីដោះស្រាយទំនាស់ដីធ្លី, ការបង្កើតផែនទីសុរិយោដី, ការចុះបញ្ជីដីធ្លី (ទាំងជាលក្ខណៈប្រព័ន្ធ និងដោយចោះៗ), និងសម្បទានដីសង្គមកិច្ច ។ បទប្បញ្ញត្តិស្តីពីការធ្វើផែនការសម្បទានដីសង្គមកិច្ច មានសារៈសំខាន់ខ្លាំងណាស់: ក្រុមប្រឹក្សាឃុំផ្តួចផ្តើមគំនិតអនុវត្តដំណើរការនៅកំរិតមូលដ្ឋាន ដែលត្រូវមានឆ្លុះបញ្ចាំងនៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ, ដូច្នេះវាបង្កើតឱកាសល្អដើម្បីតួបដំណើរការទាំងពីរបញ្ចូលគ្នា ។ គេសង្ឃឹមថាច្បាប់ និងបទប្បញ្ញត្តិនានាជាប់ទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច (អាជីវកម្មកសិឧស្សាហកម្ម) នឹងបង្កើតឱ្យមានតួនាទីស្រដៀងគ្នា ហើយតាមនេះនឹងបង្កើនលទ្ធភាពរបស់ក្រុមប្រឹក្សាឃុំដើម្បីចូលពាក់ព័ន្ធយ៉ាងសកម្មក្នុងការធ្វើផែនការប្រើប្រាស់ដី/NREM ។

### ១២.៣ ច្បាប់និងបទប្បញ្ញត្តិទាក់ទិននឹងធនធានធម្មជាតិ និងបរិស្ថាន

ជាការគួរឱ្យស្តាយ ច្បាប់/សេចក្តីព្រាងច្បាប់ ដែលមានស្រាប់ ជាប់ទាក់ទងផ្ទាល់នឹងធនធានធម្មជាតិ/បរិស្ថាន ដូចជាច្បាប់ថ្មីស្តីពីព្រៃឈើ ជាដើម មានចែងតិចតួចណាស់ពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ ។ ប៉ុន្តែ ច្បាប់និងបទប្បញ្ញត្តិទាំងនេះ បានផ្តល់ឱកាសពិតៗ និងសេចក្តីណែនាំសំរាប់ក្រុមប្រឹក្សាឃុំ នៅក្នុងសកម្មភាពធ្វើផែនការប្រើប្រាស់ដី/NREM ។ ម្យ៉ាងទៀតអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅក្រុមប្រឹក្សាឃុំ អនុញ្ញាតឱ្យឃុំទទួលអនុវត្តសកម្មភាពអ្វីមួយដែលស្ថិតនៅខាងក្រៅដែនសមត្ថកិច្ចរបស់ខ្លួនបាន បើសិនមានការអនុញ្ញាតពិសេសពីក្រសួង ឬស្ថាប័នរដ្ឋ ដូចជា ក្រសួងកសិកម្ម ឬក្រសួងបរិស្ថានជាដើម ដោយផ្អែកលើការសំរបសំរួលរបស់ក្រសួងមហាផ្ទៃ និងត្រួតពិនិត្យដោយ NCSC ។ នៅមានឱកាសល្អៗច្រើនទៀតដើម្បីបង្កើតតួនាទី និងភារកិច្ចច្បាស់លាស់សំរាប់ក្រុមប្រឹក្សាឃុំក្នុងវិស័យនេះ តាមរយៈច្បាប់/បទប្បញ្ញត្តិដែលមិនទាន់អនុម័ត ។

### ១២.៤ ចន្លោះប្រហោងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិមានស្រាប់

បច្ចុប្បន្ន មានចន្លោះប្រហោងជាច្រើននៅក្នុងប្រព័ន្ធច្បាប់ ដែលប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមប្រឹក្សាឃុំដើម្បីចូលពាក់ព័ន្ធយ៉ាងពេញលេញក្នុងការធ្វើផែនការប្រើប្រាស់ដី/NREM ។ ឧទាហរណ៍ ច្បាប់/បទប្បញ្ញត្តិទាក់ទិននឹងការគ្រប់គ្រងដីរដ្ឋ សម្បទានដីសេដ្ឋកិច្ច ដីរបស់សហគមន៍ប្រជាជនដើម និងព្រៃឈើសហគមន៍ គឺត្រូវធ្វើការអភិវឌ្ឍជាចាំបាច់ ។ រឿងនេះមិនមែន

---

[៦៤] ក្នុងនេះគឺមានទាំង ច្បាប់ស្តីពីការប្រមូលចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំ និងអនុក្រឹត្យស្តីពីកំរៃរដ្ឋបាលសំរាប់ក្រុមប្រឹក្សាឃុំ ។

មានន័យថា សកម្មភាពប្រើប្រាស់ដី/NREM ដ៏គួរឱ្យកត់សំគាល់និងសក្តិសិទ្ធិ គឺមិនអាចអនុវត្តក្នុងពេលបច្ចុប្បន្នបាននោះទេ ។

### *១២.៥ ការបង្កើតរចនាសម្ព័ន្ធរដ្ឋាភិបាលជាទូទៅ*

ទិដ្ឋភាពជាវិជ្ជមានមួយនៃច្បាប់/បទប្បញ្ញត្តិដែលបានតាក់តែង និងអនុម័តក្នុងរយៈបីឆ្នាំកន្លងមក គឺវាបានបង្កើតរចនាសម្ព័ន្ធ ភារកិច្ច និងនីតិវិធីដ៏ច្បាស់លាស់របស់រដ្ឋ ដែលរលូនគ្នាល្អក្នុងទូទាំងប្រទេស ។ តួនាទីរបស់តួអង្គនានា ដូចជា មេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ អភិបាលខេត្ត អភិបាលស្រុក គណៈកម្មការស៊ីរិយោដី នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មន្ទីរផែនការខេត្ត គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត (រួមទាំងផ្នែករដ្ឋបាលមូលដ្ឋាន និងបុគ្គលិកទ្រទ្រង់បច្ចេកទេសនៅក្រោមឱវាទ) គណៈកម្មការខេត្តបែងចែកដីប្រើប្រាស់ ក្រុមការងាររបស់ស្រុក... ត្រូវបានចែងត្រួស១នៅក្នុងច្បាប់ ។ រចនាសម្ព័ន្ធនេះបានជួយដល់ក្រុមប្រឹក្សាឃុំដែលជាប់ទាក់ទិនក្នុងការធ្វើផែនការប្រើប្រាស់ដី/NREM ព្រមទាំងរដ្ឋាភិបាលទាំងមូលផង ក្នុងការកំណត់ពីតំរូវការ និងការបារម្ភផ្សេង១, ការចែករំលែកមតិយោបល់, ការចូលរួមវិភាគទាន/ការទទួលបានជំនួយផ្នែកបច្ចេកទេស, ការដោះស្រាយទំនាស់, ការឃ្លាំមើលដំសក្តិសិទ្ធិ និងការវាយតំលៃកម្មវិធី ។ រឿងនេះនឹងនាំឱ្យមានការកែលំអជាប្រចាំដល់ប្រព័ន្ធរដ្ឋាភិបាល និងការអភិវឌ្ឍន៍ថែមទៀតនូវច្បាប់/បទប្បញ្ញត្តិ ។ រចនាសម្ព័ន្ធច្បាប់បច្ចុប្បន្ន ជួយទ្រទ្រង់ដល់ការចូលពាក់ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ ក្នុងការធ្វើផែនការប្រើប្រាស់ដី/NREM ដោយមានការចូលរួម ហើយបើសិនអនុវត្តបានសមស្រប ប្រព័ន្ធនេះនឹងកាន់តែប្រែប្រួលល្អឡើងទៅតាមពេលវេលា ។

## ១៣. បញ្ហាគ្រប់គ្រងហិរញ្ញវត្ថុជាប់ទាក់ទិននឹងវិមជ្ឈការ

បញ្ហាធំបំផុតទាក់ទងនឹងសុខដុមនីយកម្មច្បាប់ និងការគ្រប់គ្រងហិរញ្ញវត្ថុជាប់ទាក់ទិននឹងវិមជ្ឈការ គឺពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុជាទូទៅនៅក្នុងប្រទេស ។ ច្បាប់ស្តីពីប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំនូលពន្ធ ចំនូលមិនមែនពន្ធ និងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំ មិនអាចកសាងដាច់តែឯងបានទេ គឺត្រូវតាក់តែងឡើងដោយផ្សារភ្ជាប់ទៅនឹងប្រព័ន្ធប្រមូលចំនូលវិសហមជ្ឈការនៅកំរិតខេត្ត និងស្រុក ដើម្បីជៀសវាងបញ្ហាប្រមូលពន្ធច្រើនហួស ឬប្រមូលពន្ធត្រួតគ្នាទៅលើប្រជាជន ។ ម្យ៉ាងទៀត ប្រព័ន្ធទូទៅនៃការប្រមូល និងការបែងចែកចំណូល ត្រូវតែផ្សារភ្ជាប់យ៉ាងប្រយ័ត្នប្រយែងជាមួយនឹងការប្រមូលចំណូល និងការបើកផ្តល់ថវិកាដ៏សក្តិសិទ្ធិដោយរតនាគារជាតិ ។

## ១៤. ការកសាងសមត្ថភាពដើម្បីគាំទ្រដល់វិមជ្ឈការ

សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំដើម្បីអនុវត្តអាណត្តិថ្មី១របស់ខ្លួន មានចោទបញ្ហាច្បាស់ណាស់ ដោយបច្ចុប្បន្នមានរបាយការណ៍ជាច្រើនបង្ហាញថា សមត្ថភាពជាទូទៅនៅទាបណាស់ ។ សមត្ថភាពនៅក្នុងក្រុមប្រឹក្សាឃុំ និងនៅក្នុងបណ្តាអង្គភាពរដ្ឋដែលជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ គឺត្រូវតែកែលំអបន្តជាប់រហូតនៅក្នុងរយៈពេលខាងមុខ ។ ការកសាងសមត្ថភាពនេះ ត្រូវគ្របដណ្តប់លើវិស័យជាច្រើន (ច្បាប់ ហិរញ្ញវត្ថុ គណនេយ្យ ការចុះកិច្ចសន្យា អភិបាលកិច្ច ការចូលរួមជាសាធារណៈ ការធ្វើផែនការអភិវឌ្ឍន៍...) ។ ការគាំទ្រដល់ការកសាងសមត្ថភាពក្នុងពេលសព្វថ្ងៃទទួលបានជាសំខាន់ពីកម្មវិធីសិលា និងរចនាសម្ព័ន្ធគាំទ្រជាប់ទាក់ទិននានា ប៉ុន្តែក៏មានការគាំទ្រពីគំរោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ-សង្កាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងគំនិតផ្តួចផ្តើមរបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេង១ និងសង្គមស៊ីវិលដែរ ។

ក្នុងទស្សនៈខាងច្បាប់ យន្តការដើម្បីធានាថាមុខងារភ្នាក់ងារបានធ្វើប្រតិភូកម្មនានាត្រូវមានទាំងការកសាងសមត្ថភាពដ៏ចាំបាច់ផង គឺត្រូវតែប្រើប្រាស់ឱ្យសមស្របទៅអនាគត ។ ម្យ៉ាងទៀត រចនាសម្ព័ន្ធអចិន្ត្រៃយ៍នានារបស់រដ្ឋាភិបាលសំរាប់គាំទ្រឃុំ និងធានាឱ្យមានការកែលំអបន្តជាប់រហូត និងយូរអង្វែងនូវសមត្ថភាព, ត្រូវតែដាក់បញ្ចូលទៅក្នុងច្បាប់រៀបចំអង្គការស្តីពីអភិបាលកិច្ចខេត្តនិងស្រុក ដើម្បីជំនួសរចនាសម្ព័ន្ធបណ្តោះអាសន្ននានាដែលបានអនុវត្តកន្លងមកតាមគំនិតផ្តួចផ្តើមរបស់សិលា ដូចជា អង្គភាពគ្រប់គ្រងផ្សេង១ដែលស្ថិតនៅក្រោមឱវាទ PRDC ExCom ជាដើម ។

## ១៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ផ្អែកលើការពិនិត្យជាទូទៅនៅខាងលើ គេអាចរកឃើញគំហើញបឋមជាច្រើន និងអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

រដ្ឋាភិបាល កំពុងអនុវត្តកំណែទំរង់វិមជ្ឈការ ដើម្បីផ្ទេរអំណាចទៅឱ្យអាជ្ញាធរជាប់ឆ្នោតពាក់កណ្តាលស្វយ័តនៅកំរិតឃុំ/សង្កាត់ និងឈានទៅបង្កើនតួនាទីរបស់ខេត្ត និងក្រុង ក្នុងឋានៈជាអង្គភាពមជ្ឈិមដែលត្រូវបានធ្វើវិសហមជ្ឈការ ។ នៅខែមីនា ២០០១, RGC បានចាប់ផ្តើមការសាកល្បងដំណាក់កាលមួយនៃការធ្វើវិមជ្ឈការរដ្ឋអំណាចតាមការអនុមតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (LAMC) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់, ដែលបន្តដោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅខែកុម្ភៈ ២០០២ ។ មុខងារ សិទ្ធិអំណាចចំណាយ និងធនធានជាច្រើន ត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរមូលដ្ឋាន ហើយអភិបាលខេត្តនានាបានទទួលភារកិច្ចជួយគាំទ្រ និងធ្វើការត្រួតពិនិត្យលើក្រុមប្រឹក្សាឃុំ/សង្កាត់។ ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងនេះ ច្បាប់និងបទប្បញ្ញត្តិជាច្រើន ត្រូវបានអនុម័តចេញក្នុងរយៈពេលមួយដ៏ខ្លី ។ តើច្បាប់និងបទប្បញ្ញត្តិទាំងនេះវាស៊ីសង្វាក់គ្នាយ៉ាងណាជាមួយនឹងច្បាប់ដែលមានស្រាប់ និង តើការប្រឹងប្រែងធ្វើវិមជ្ឈការសព្វថ្ងៃរបស់រដ្ឋាភិបាល វាស៊ីសង្វាក់គ្នាប៉ុណ្ណាជាមួយនឹងរចនាសម្ព័ន្ធទាំងនេះ, គឺសុទ្ធតែជាចំណុចផ្តោតនៅក្នុងរបាយការណ៍ ។ គេអាចធ្វើការសង្កេតពីដំបូង១ជាច្រើន តាមរយៈការវិភាគលើស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ។

១. គួរលើកសរសើរដល់រដ្ឋាភិបាលដែលបានអនុម័តច្បាប់ និងបទប្បញ្ញត្តិជាច្រើន ក្នុងរយៈពេលមួយដ៏ខ្លីបែបនេះ ដើម្បីជួយគាំទ្រដល់វិមជ្ឈការ ។

២. នៅពេលតាក់តែងសេចក្តីព្រាងច្បាប់សំខាន់១ គឺមិនទាន់មានអនុម័តឯកសារខាងគោលនយោបាយអ្វីនៅឡើយ ដូច្នេះពុំមានសេចក្តីណែនាំអ្វីច្បាស់លាស់ទេ សំរាប់ការតាក់តែងច្បាប់ ។ សរុបមក LAMC ក៏បានក្លាយជាឯកសារគោលនយោបាយមួយ។ រឿងនេះ គួបផ្សំនឹងរយៈពេលដ៏ខ្លីផង បានធ្វើឱ្យប្រព័ន្ធច្បាប់មានលក្ខណៈស្មុគស្មាញបន្តិច ហើយវិធាននិងបទប្បញ្ញត្តិផ្សេង១មានចំណុចត្រួតគ្នាយ៉ាងច្រើន និងមានខ្លឹមសារមិនច្បាស់លាស់ ដោយសារការតាក់តែងមានលក្ខណៈទន់ខ្សោយ ។ ប៉ុន្តែច្បាប់ និងបទប្បញ្ញត្តិទាំងនេះ មានគុណភាពប្រហាក់ប្រហែលគ្នានឹងកំរិតគុណភាពដែលឃើញមានជាធម្មតានៅកម្ពុជា, ហើយអាចដាក់អនុវត្តបាន ។

៣. ទោះបីមានបញ្ហាចោទមួយចំនួននៅក្នុងប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិក្តី ក៏វាមិនឃើញមានផលប៉ះពាល់អ្វីធ្ងន់ធ្ងរទៅលើការអនុវត្តនៅនៅផ្ទាល់កន្លែងទេ ដោយសារមានការប្រើប្រកាសសំរាប់ដាក់អនុវត្តនីច្បាប់។ ប៉ុន្តែដល់យូរ១ទៅ នៅពេលមានបញ្ហាផុសឡើង គេចាំបាច់ត្រូវតែដោះស្រាយវា ។

៤. ល្បឿនវិមជ្ឈការសព្វថ្ងៃ ហាក់ដូចជាបានស្របគ្នានឹងបំណងរបស់រដ្ឋាភិបាល ហើយបើតាមយោបល់របស់អ្នកធ្វើអត្ថាធិប្បាយជាច្រើននាក់ គឺហាក់ដូចមានល្បឿនសមស្របល្អហើយទៅតាមបរិបទខាងវប្បធម៌ និងសមត្ថភាពនៅកម្ពុជា ។

៥. មុនដល់អាណត្តិលើកក្រោយនៃក្រុមប្រឹក្សាឃុំ គេត្រូវតាក់តែងគោលនយោបាយច្បាស់លាស់សំរាប់ណែនាំដល់ការព្រាងច្បាប់និងបទប្បញ្ញត្តិថ្មី១ និងការធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ ទាំងក្នុងផ្នែកវិមជ្ឈការដែលជាប់ទាក់ទិននឹងក្រុមប្រឹក្សាឃុំ និងក្នុងផ្នែកវិសហមជ្ឈការដែលជាប់ទាក់ទិននឹងអាជ្ញាធរកំរិតខេត្ត និងស្រុក (ច្បាប់រៀបចំអង្គការ) ។ ការតាក់តែងគោលនយោបាយទាំងនេះ ត្រូវតែធ្វើឱ្យបានសមស្របជាមួយគ្នាទៅវិញទៅមក ពីព្រោះវិមជ្ឈការ និងវិសហមជ្ឈការ ជំពាក់ជំពិនគ្នាខ្លាំងណាស់មិនអាចកាត់ផ្តាច់ពីគ្នាបានទេ ។

៦. បើគិតដល់ចន្លោះប្រហោងក្នុងច្បាប់បច្ចុប្បន្ន ចំណុចលេចធ្លោបំផុតគឺ កង្វះច្បាប់រៀបចំអង្គការសំរាប់អាជ្ញាធរកំរិតខេត្ត និងស្រុក ។ ក្រៅពីនេះ ច្បាប់សំខាន់១ដែលចាំបាច់ត្រូវដាក់អនុវត្តក្នុងរយៈពេលខ្លី និងមធ្យម រួមមានៈ ច្បាប់

និងបទប្បញ្ញត្តិស្តីពីការកំនត់ ប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំនូលពន្ធ ចំនូលមិនមែនពន្ធ និងកំរៃសេវាសំរាប់ក្រុមប្រឹក្សាឃុំ (ច្បាប់នេះត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌ ការធ្វើសុខដុមនីយកម្មការគ្រប់គ្រងសារពើពន្ធនៅគ្រប់កំរិតនៃរដ្ឋាភិបាល), ច្បាប់ស្តីពីកំរៃរដ្ឋបាល សំរាប់មុខងារទីភ្នាក់ងារដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សាឃុំ, នីតិវិធីសំរាប់ការជ្រើសរើស ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងរបៀបរបបធ្វើការងារ និងភារកិច្ចរបស់មេភូមិ, សេចក្តីណែនាំសំរាប់ឱ្យក្រុមប្រឹក្សាឃុំជ្រើសជួលបុគ្គលិកតាមតំរូវការ, ការតាក់តែងដីកាឃុំ, ការបង្កើតគណៈកម្មាធិការផ្សេងៗសំរាប់ជួយដល់ក្រុមប្រឹក្សាឃុំក្នុងការអនុវត្តន៍ភារកិច្ច និងតួនាទី និងការទទួលខុសត្រូវរបស់ឃុំច្រើនដែលធ្វើការជាមួយគ្នា ។

៧. បញ្ហាពន្យាអាណត្តិរបស់ NCSC ត្រូវលើកយកមកដោះស្រាយក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីវិមជ្ឈការ ។ បើសិនត្រូវពន្យាអាណត្តិនេះ, LAMC និងបទប្បញ្ញត្តិជាប់ទាក់ទិនផ្សេងៗ ក៏ត្រូវធ្វើវិសោធនកម្មតាមនោះដែរ ។

៨. ត្រូវមានការពិនិត្យឡើងវិញជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយលើប្រព័ន្ធថវិកា/ហិរញ្ញវត្ថុ បើសិនគេចង់ឱ្យក្រុមប្រឹក្សាឃុំអាចចាប់ផ្តើមរកចំណូលពន្ធបានពិតៗ ដែលមិនមែនត្រឹមតែជាកំរៃសេវាដូចមានចែងនៅក្នុង LAMC នោះទេ ។ ត្រូវមានប្រព័ន្ធដ៏ច្បាស់លាស់មួយថា តើចំណូលប្រភេទណាត្រូវប្រមូលដោយរតនាគារជាតិ ឬខេត្ត ឬឃុំ ដើម្បីចៀសវាងបញ្ហាប្រមូលពន្ធច្រើនហួស ឬប្រមូលពន្ធត្រួតគ្នា ។

៩. គេនៅមិនទាន់បានធ្វើអ្វីសោះក្នុងរឿងកំនត់ព្រំដែនឃុំឡើងវិញ ប៉ុន្តែទិសដៅគឺត្រូវដោះស្រាយបញ្ហានេះឱ្យរួចរាល់នៅមុនពេលបោះឆ្នោតឃុំ/សង្កាត់លើកក្រោយនាឆ្នាំ២០០៧ ។

១០. ការតាក់តែងច្បាប់រៀបចំអង្គការ នឹងមានផលប៉ះពាល់ដោយជៀសមិនរួច ទៅលើច្បាប់និងបទប្បញ្ញត្តិមានស្រាប់នានាដែលជាប់ទាក់ទិននឹងវិមជ្ឈការ ។ យោងតាមព្រឹត្តិការណ៍ និងបញ្ហាផ្សេងទៀត ដែលមានផលប៉ះពាល់ដល់ច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ន គេប្រហែលចាំបាច់ត្រូវតាក់តែងឡើងវិញឱ្យបានសព្វគ្រប់នូវ LAMC ព្រមទាំងអនុក្រឹត្យ និងប្រកាសសំរាប់គាំទ្រនានា ។ បើដូច្នោះមែន បញ្ហានេះត្រូវដោះស្រាយយ៉ាងប្រុងប្រយ័ត្ន ដោយមានឯកសារគោលនយោបាយច្បាស់លាស់សំរាប់ជួយតំរង់ទិសដល់ការតាក់តែងច្បាប់។ បើសិនគោលដៅគឺត្រូវអនុម័តច្បាប់រៀបចំអង្គការឱ្យបានមុនការបោះឆ្នោតឃុំលើកក្រោយ (រដ្ឋាភិបាលបានប្រកាសថា មានគោលដៅនេះមែន) ដូច្នេះការតាក់តែង LAMC ឡើងវិញ ក៏ត្រូវតែបញ្ចប់ឱ្យបានមុនពេលបោះឆ្នោតឃុំលើកក្រោយដែរ។ បញ្ហាទាំងពីរ នេះជំពាក់វាក់វិនគ្នាបេះមិនដាច់ ហើយត្រូវដោះស្រាយក្នុងពេលជាមួយគ្នា ។ រឿងនេះត្រូវការកិច្ចសំរបសំរួល និងសហប្រតិបត្តិការរវាងអង្គភាពកសាងគោលនយោបាយសំខាន់ៗដែលជាប់ទាក់ទិន (NCSC, CAR, MoI, និងសិលា) ព្រមទាំងការប្តេជ្ញាចិត្តខាងនយោបាយដ៏ខ្លាំងក្លាពីសំណាក់រដ្ឋាភិបាល ។

១១. ច្បាប់រៀបចំអង្គការគួរដោះស្រាយបញ្ហាការសំរបសំរួលវិសហមជ្ឈការតាមខ្សែផ្តេក រវាងក្រសួងជំនាញនានានៅកំរិតខេត្ត និងស្រុក ។

១២. NCSC ពុំមានពេលវេលាដើម្បីពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិដែលប៉ះពាល់ដល់ក្រុមប្រឹក្សាឃុំ ដូចជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ដែលទើបអនុម័តហើយថ្មីៗ ជាដើមនោះទេ។ បញ្ហាចោទគឺ មុខងារទីភ្នាក់ងារត្រូវបានធ្វើប្រតិភូកម្ម ដោយគ្មានការដាក់អនុវត្តន៍យន្តការដ៏ចាំបាច់នានាដើម្បីធានាថា ធនធានដ៏ចាំបាច់ផ្សេងៗ (សមត្ថភាព និង ហិរញ្ញវត្ថុ) ក៏ត្រូវបានផ្តល់ឱ្យដែរ ។

១៣. ក្រុមប្រឹក្សាឃុំ ត្រូវបំពេញតួនាទីដ៏សំខាន់មួយក្នុងការគ្រប់គ្រងការប្រើប្រាស់ ដី និងធនធានធម្មជាតិ ថ្វីបើក្នុងពេលបច្ចុប្បន្ន ពួកគេមិនទាន់មានសិទ្ធិអំណាចធ្វើសេចក្តីសំរេចអារកាត់ដោយផ្ទាល់នៅក្នុងវិស័យខ្លះៗ ដូចជា ខាង

ព្រៃឈើ ជាដើមក្តី ។

# ឯកសារយោង

(2003) *Problems and Concerns of Commune Councillors: Results from the DOLA Letter Box at Commune Seminar*

Ayers, D. (2001), *Review of Literature on Decentralisation* (Phnom Penh, CCSP)

Blunt, P. (2003), *Contextual Analysis for Strategic Management of Capacity Building for Decentralisation and Deconcentration in the Kingdom of Cambodia* (Phnom Penh, ADB Commune Council Development Project)

CAR (2003), *Draft Discussion Paper on Deconcentration Policies and Strategies*

Council of Minister, *Sub-decree on Community Forestry Management* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Forest Concession Management* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Interior* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Environment* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Land Management, Urban Planning and Construction* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Agriculture, Forestry and Fisheries* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Industry, Mines and Energy* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Water Resources and Meteorology* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Economy and Finance* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Rural Development* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Ministry of Planning* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Organisation and Functioning of Cadastral Commission* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on SEILA Task Force* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on Social Land Concessions* (Phnom Penh: Council of Minister)

Council of Minister, *Sub-decree on the Creation of the Council for Administrative Reform* (Phnom Penh: Council of Minister)

Evans, H. (2003), *Report on Deconcentration*

Flam, S. (2003), *Draft Legal Review and Analysis of the Body of Decentralization Law* (Phnom Penh, GTZ)

Kingdom of Cambodia, *Constitution of the Kingdom of Cambodia, revised 1999* (Phnom Penh: Kingdom of Cambodia)

Kingdom of Cambodia, *Law on Environmental Protection and Natural Resources Management* (Phnom Penh: Kingdom of Cambodia)

Kingdom of Cambodia, *Law on Financial Regime and Property of Municipalities and Provinces* (Phnom Penh: Kingdom of Cambodia)

Kingdom of Cambodia, *Law on Forestry* (Phnom Penh: Kingdom of Cambodia)

Kingdom of Cambodia, *Law on Land* (Phnom Penh: Kingdom of Cambodia)

Kingdom of Cambodia, *Law on the Organisation and Functioning of the Council of Ministers* (Phnom Penh: Kingdom of Cambodia)

Royal Government of Cambodia, *Cambodian Millennium Development Goals* (Phnom Penh: RGC)

Royal Government of Cambodia, *Governance Action Plan* (Phnom Penh: RGC)

Royal Government of Cambodia, *National Forestry Policy* (Phnom Penh: RGC)

Royal Government of Cambodia, *National Poverty Reduction Strategy* (Phnom Penh: RGC)

Royal Government of Cambodia, *Policy on Judicial and Legal Reform* (Phnom Penh: RGC)

Royal Government of Cambodia, *Policy Paper on Social Land Concessions* (Phnom Penh: RGC)

Royal Government of Cambodia, *Prakas on Organisation and Functioning of Forestry Administration* (Phnom Penh: RGC)

Royal Government of Cambodia, *Prakas on Structures, Roles and Responsibilities of the PRDC* (Phnom Penh: RGC)

Royal Government of Cambodia, *Prakas on the Roles, Responsibilities and Organisational Structure of the Provincial and Municipal Administrations* (Phnom Penh: RGC)

Royal Government of Cambodia, *Second Five Year Socio-Economic Development Plan* (Phnom Penh: RGC)

Siphana, S. (2001), *Compendium of Cambodian Laws* (Phnom Penh)

Smoke, P. (2003), *Report on Fiscal Decentralisation and Deconcentration*

Tolvanen, J. P. (2003), "Report of Legal Registration Advisors Mission"

Wehrmann, B. and Rathmony, S. (2002), *Recommendations for Decentralisation of Land Management and Land Administration: The Future Role of Commune Councils, Strategy Paper and Action Plan* (Phnom Penh, GTZ)

## ឧបសម្ព័ន្ធ ក

# ក្រាហ្វិកដែនអនុវត្តឯកសារច្បាប់ ធៀបនឹងរយៈពេលអនុម័ត



## ឧបសម្ព័ន្ធ ខ

# បញ្ជីច្បាប់ និងបទប្បញ្ញត្តិ[៦៥]

### ១. ច្បាប់ និងបទប្បញ្ញត្តិដែលបានអនុម័ត ដើម្បីគាំទ្រដល់កំណែទំរង់វិមជ្ឈការ

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ ១៨ មករា ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ចុះថ្ងៃ ១២ មករា ២០០១
- រាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ ចុះថ្ងៃ ១២ មករា ២០០១
- អនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ចុះថ្ងៃ ៣ កក្កដា ២០០១
- អនុក្រឹត្យស្តីពីការកែសំរួល មាត្រា៨ និង មាត្រា៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ចុះថ្ងៃ ២៤ មិថុនា ២០០២
- អនុក្រឹត្យស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ ២៤ មិថុនា ២០០២
- អនុក្រឹត្យស្តីពីការកំណត់ថ្លៃជាវក្រដាសអគ្រានុកូលដ្ឋាន និងថ្លៃតែមប្រិសារពើពន្ធ ចុះថ្ងៃ ២៤ មិថុនា ២០០២
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់/ចុះថ្ងៃ ២៥ កុម្ភៈ ២០០២
- អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ ២៥ មីនា ២០០២
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងថវិកាឃុំ/សង្កាត់ ចុះថ្ងៃ០២ មេសា ២០០២
- អនុក្រឹត្យស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ៣០ មេសា ២០០១
- ប្រកាស ស្តីពីការបង្កើតប្រព័ន្ធគណនេយ្យសំរាប់មូលនិធិឃុំ ចុះថ្ងៃ១០ មេសា ២០០២
- ប្រកាស ស្តីពីគណនីបន្ថែមនៅក្នុងប្លង់គណនីរដ្ឋ ចុះថ្ងៃ១០ មេសា ២០០២
- ប្រកាស ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ/សង្កាត់ ចុះថ្ងៃ១៩ ធ្នូ ២០០១
- ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចក្នុងការចាត់ចែងដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដល់អភិបាលខេត្ត ក្រុង ចុះថ្ងៃ១៨ កុម្ភៈ ២០០២
- ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាច ដល់អភិបាលខេត្ត/ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ១៨ កុម្ភៈ ២០០២
- ប្រកាស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ចុះថ្ងៃ០៧ ឧសភា ២០០២

---

[៦៥] បញ្ជីខាងក្រោមនេះ បានចងក្រងដោយ Leon Bernard និង ឡុង បញ្ញោវុធ ។

- ប្រកាស ស្តីពីទំរង់ និងខ្លឹមសារនៃមូលនិធិឃុំ ចុះថ្ងៃ២៥ មេសា ២០០២
- ប្រកាសអន្តរក្រសួងស្តីពីការសំរួលមាត្រា ២៩ នៃ ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ចុះថ្ងៃ២៦ សីហា ២០០២
- ប្រកាស អន្តរក្រសួងស្តីពីការប្រើប្រាស់សេចក្តីណែនាំពីដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគ៣ឆ្នាំ រំកិល(២០០៣-២០០៥) ចុះថ្ងៃ០៧ កុម្ភៈ ២០០២
- ប្រកាស អន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ចុះថ្ងៃ០៧ កុម្ភៈ ២០០២
- ផែនការសកម្មភាពទី១ របស់ NCSC សំរាប់អនុវត្តវិមជ្ឈការ ចុះថ្ងៃ២០ កញ្ញា ២០០១
- សេចក្តីសំរេចអំពីការបង្កើតអនុគណៈកម្មការនានាចំណុះ NCSC ចុះថ្ងៃ២៨ កញ្ញា ២០០១
- សេចក្តីសំរេចស្តីពីការកែតំរូវលើសេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ និងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ២១ កុម្ភៈ២០០២
- សេចក្តីសំរេចស្តីពីគោលការណ៍សំរាប់ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីគាំទ្រការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់តាមបែបវិមជ្ឈការ ចុះថ្ងៃ២៩ មេសា២០០២
- សេចក្តីសំរេចស្តីពីការបង្កើតប្រព័ន្ធគាំទ្រដល់ការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ក្នុងខេត្ត/ក្រុងចំនួន ៧ (ក្រុងភ្នំពេញ ក្រុងព្រះសីហានុ ក្រុងកែប ខេត្តកណ្តាល ខេត្តកោះកុង ខេត្តស្ទឹងត្រែង ខេត្តរតនគិរី) ចុះថ្ងៃ២៦ សីហា ២០០២
- សេចក្តីណែនាំស្តីពីការបំពេញលក្ខខណ្ឌ ដើម្បីទទួលបានធនធានមូលនិធិឃុំ/សង្កាត់ សំរាប់ការផ្ទេរលើកទី៣ ក្នុងឆ្នាំ២០០២ ចុះថ្ងៃ១៨ កញ្ញា ២០០២
- សេចក្តីណែនាំស្តីពីការរៀបចំកិច្ចប្រជុំលើកដំបូង ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និង ប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ព្រមទាំងការចាប់ផ្តើមបំពេញការងារបន្ទាប់ពីកិច្ចប្រជុំលើកដំបូង និង ឧបសម្ព័ន្ធដោយមានឧទាហរណ៍នៃបទបញ្ជាផ្ទៃក្នុងសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ១៨ កុម្ភៈ ២០០២
- សេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ១៨ កុម្ភៈ ២០០២
- សេចក្តីណែនាំស្តីពីកិច្ចដំណើរការ និងយុទ្ធសាស្ត្រក្នុងការបណ្តុះបណ្តាលលើការកសាងផែនការ និងការចាត់ចែងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ចុះថ្ងៃ២៩ មេសា ២០០២
- សេចក្តីណែនាំស្តីពីការចាត់ចែង និងប្រើប្រាស់សៀវភៅដៃ "តើអ្វីខ្លះដែលលោកអ្នកចង់ដឹងអំពីវិមជ្ឈការ និងគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ នៅប្រទេសកម្ពុជា" ចុះថ្ងៃ០៦ ឧសភា ២០០២
- សេចក្តីណែនាំស្តីពីការប្រើប្រាស់ទំរង់ការឃុំ និងការរៀបចំសំរាប់ឆ្នាំ២០០៣ ចុះថ្ងៃ២៩ កក្កដា ២០០២
- សេចក្តីណែនាំដើម្បីអនុវត្តសេចក្តីសំរេចរបស់ NCSC ស្តីពីការបង្កើតប្រព័ន្ធគាំទ្រដល់ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងខេត្ត ក្រុងចំនួន ៧ ចុះថ្ងៃ០៥ កញ្ញា ២០០២
- សេចក្តីណែនាំស្តីពីការរៀបចំ និងការអនុវត្តន៍មូលនិធិឃុំ សង្កាត់ ចុះថ្ងៃ២៩ មេសា ២០០២
- សេចក្តីជូនដំណឹងអំពីប្រាក់ឧបត្ថម្ភជូនប្រធានភូមិ ស្មៀនឃុំ និងមន្ទីរផែនការខេត្ត ចុះថ្ងៃ២៥ កក្កដា ២០០២
- សេចក្តីជូនដំណឹងអំពីការដកប្រាក់បៀវត្សរ៍របស់ក្រុមប្រឹក្សាឃុំ ចុះថ្ងៃ១២ កក្កដា ២០០២

- សេចក្តីជូនដំណឹងអំពីការតែងតាំងគណនេយ្យករឃុំ ចុះថ្ងៃ២៧ មិថុនា ២០០២
- សេចក្តីជូនដំណឹងអំពីការផ្តល់មូលនិធិវិនិយោគឃុំ ដែលស្ថិតក្នុងប្រភេទ ឃុំ "ក" និងការកំណត់មូលនិធិឃុំ ចុះថ្ងៃ២១ មិថុនា ២០០២

## ២. ច្បាប់និងបទប្បញ្ញត្តិមិនទាន់បានអនុម័តដើម្បីគាំទ្រដល់កំណែទំរង់វិមជ្ឈការ តាមការកំណត់ក្នុង LAMC

- សេចក្តីណែនាំអំពីបែបបទ និងនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការភូមិ ( មាត្រា ៣០)
- សេចក្តីណែនាំអំពីរបៀបរបបធ្វើការងារ និងភារកិច្ចរបស់មេភូមិ ( មាត្រា ៣១)
- សេចក្តីណែនាំអំពីទំរង់ និងបែបបទ ដើម្បីឱ្យឃុំ/សង្កាត់អាចរៀបចំដីកាឃុំ ( មាត្រា ៥០)
- ច្បាប់ស្តីពីការកំណត់ប្រភេទ អត្រា និងរបៀបរបបនៃការប្រមូលចំណូលពន្ធ ចំណូលមិនមែនពន្ធ និងកំរៃសេវាផ្សេងៗ ( មាត្រា ៧៤)
- អនុក្រឹត្យស្តីពីការរៀបចំប្រាក់កំរៃផ្សេងៗដល់ឃុំ ចំពោះការអនុវត្តន៍នូវតួនាទីជាភ្នាក់ងារ ( មាត្រា ៧៦)
- អនុក្រឹត្យស្តីពីការធ្វើវិភាជន៍ធនធានប្រចាំឆ្នាំទៅឱ្យឃុំ/សង្កាត់តាមរយៈមូលនិធិឃុំ ( មាត្រា ៧៨)
- អនុក្រឹត្យស្តីពីរបៀបរបបចាត់ចែងវិធាននៃការប្រើប្រាស់ និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ/សង្កាត់ ( មាត្រា ៧៨)
- អនុក្រឹត្យស្តីពីនីតិវិធីចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ឃុំ/សង្កាត់ ( មាត្រា ៨១)

# បញ្ជីឯកសារពិភាក្សារបស់ ទបសអ


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេនិងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍកម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីជីលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរថ្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូឌី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២000) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) *ជំនួយបច្ចេកទេសនិងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុង សេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១0.000រៀល ។

១៦. ស៊ុក បូរ័ក្ស (ធ្នូ ២000) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទី ពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.000រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២00១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវ ចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២00១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២0. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២00២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២១. Bhargavi Ramamurthy ស៊ុក-បូរ័ក្ស, Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២00២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.000រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២00២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការ លក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (ខែកញ្ញា ឆ្នាំ២00២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា:* ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១0.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ខែធ្នូ ឆ្នាំ២00២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.000រៀល ជាអង់គ្លេសតំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ខែធ្នូ ឆ្នាំ២00២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរតំលៃ ៨.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (ខែកញ្ញា ឆ្នាំ២00៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.000រៀល

អង់គ្លេស ៥ដុល្លារ ។

២៧. ឃឹម-ជា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈមការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. ឃឹម-ជា និង Bruce McKenney (ខែវិច្ឆិកា ឆ្នាំ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទឹងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ ដុល្លារ ។

៣០. Caroline Hughes និង គីម សេតារា (ខែមិថុនា ឆ្នាំ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣.៥០ដុល្លារ ។